


Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# ការវិភាគអំពី ការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់អនុវត្ត
# គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
## បញ្ហាប្រឈម ឱកាស និងហិរញ្ញប្បទាន

រៀបចំដោយ ៖ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

ខែកញ្ញា ឆ្នាំ២០១៥

ស្រាវជ្រាវដោយ ៖ អ៊ូ ស៊ីវហួច និង ឈាត ស្រ៊ាង ( ទីប្រឹក្សា )

ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ..... 5

**តារាងពាក្យកាត់** ..... 7

**សេចក្តីផ្តើម** ..... 8

សេចក្តីសង្ខេបអំពីគោលបំណងនៃរបាយការណ៍ និងលទ្ធផលរកឃើញសំខាន់ៗ ..... 8

វិធីសាស្រ្ត និងវិសាលភាពនៃរបាយការណ៍ ..... 9

**គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព** (SDGs) ..... 10

តើមានអ្វីខុសឆ្គងសម្រាប់ SDGs? ..... 13

**កម្ពុជា ៖ ការប្តូរពី** CMDGs **ទៅជា** SDGs ..... 14

CMDGs ៖ តើកម្ពុជាអនុវត្តបានកម្រិតណាហើយ? ..... 14

SDGs និង កម្ពុជា ..... 17

SDGs ៖ **បញ្ហាប្រឈម និងឱកាស សម្រាប់កម្ពុជា** ..... 18

**ហិរញ្ញប្បទាន** SDGs ៖ **តាមរយៈអ្នកណា**? ..... 27

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រមូលចំណូលពន្ធដែលជាធនធានក្នុងស្រុក ..... 28

កំណើនសេដ្ឋកិច្ច/វិស័យឯកជន ..... 30

ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ..... 34

SDGs **កម្ពុជា** (CSDGs) ៖ **សមាសភាពសំខាន់ៗ និងអនុសាសន៍** ..... 39

**សេចក្តីសន្និដ្ឋាន** ..... 43

**ឯកសារយោង** ..... 44

**បញ្ជីឧបសម្ព័ន្ធ** ..... 47

ឧបសម្ព័ន្ធ ០១ ៖ បញ្ជីរាយឈ្មោះអ្នកផ្តល់បទសម្ភាសន៍ ..... 47

ឧបសម្ព័ន្ធ ០២ ៖ សហគមសេដ្ឋកិច្ចអាស៊ាន និងការជាប់ទាក់ទងសម្រាប់កម្ពុជា ..... 48

ឧបសម្ព័ន្ធ ០៣ ៖ កម្ពុជាកំពុងប្រែក្លាយជាប្រទេសដែលមានចំណូលសេដ្ឋកិច្ចមធ្យមកម្រិតទាបត្រឹមឆ្នាំ២០១៥ ..... 50

## ខ្លឹមសារសង្ខេប

គោលដៅអភិវឌ្ឍន៍សហវត្សរ៍ (MDGs) ត្រូវបានបង្កើតឡើងជាមួយគោលបំណងសំខាន់បំផុត គឺដើម្បីកាត់បន្ថយភាពក្រីក្ររបស់ពិភពលោកឱ្យបាន ៥០% នៅត្រឹមចុងខែធ្នូ ឆ្នាំ២០១៥។ របៀបវារៈនៃការអភិវឌ្ឍ ក្រោយគោលដៅអភិវឌ្ឍន៍សហវត្សរ៍ បានដាក់ចេញជាគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នឹងបន្តដើម្បីសម្រេច/គោលដៅ (មិនសម្រេច) អភិវឌ្ឍន៍សហវត្សរ៍ ហើយតម្រូវឱ្យរដ្ឋាភិបាលទាំងអស់ រួមទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការរួមគ្នា ដើម្បីសម្រេចឱ្យបានទស្សនៈវិស័យរបស់ប្រទេសនីមួយៗ លើការអភិវឌ្ឍសម្រាប់ទាំងអស់គ្នា រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថានប្រកបដោយនិរន្តរភាព។

តើប្រទេសកម្ពុជាបានត្រៀមខ្លួនដល់កម្រិតណា ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព? របាយការណ៍ការស្រាវជ្រាវនេះបានបង្ហាញថា ប្រទេសកម្ពុជាមានសមត្ថភាពគ្រាន់បើជាងមុន តាមបែបផែនជាច្រើន លើការងារកៀរគរធនធាន មានការយល់ដឹងប្រសើរអំពីអ្វីដែលអាចសម្រេចបាន និងអ្វីដែលមិនអាចសម្រេចបាន (អាទិភាពទៅលើកំណើនសេដ្ឋកិច្ច និងមានតិចតួចទៅលើការងារអភិបាលកិច្ច) លើការងារអភិវឌ្ឍន៍ប្រទេស និងមានភាពជាម្ចាស់ច្រើនជាងមុន លើរបៀបវារៈអភិវឌ្ឍន៍នៅក្នុងស្ថានភាព ដែលដៃគូអភិវឌ្ឍន៍មិនមានការសម្របសម្រួលគ្នា និងមានការប្រកួតប្រជែង។ អាស្រ័យហេតុនេះនៅក្នុងបរិបទរបស់ខ្លួន ប្រទេសកម្ពុជាមានជំហរសម្រាប់អនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) បានប្រសើរជាងការអនុវត្តគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDGs) កាលពី១៥ ឆ្នាំមុន។ បញ្ហាប្រឈមដ៏ធំសម្រាប់ប្រទេសកម្ពុជា គឺការចរចាជាមួយស្ថាប័នអន្តរជាតិ សម្រាប់ការអនុវត្តផ្នែកនយោបាយដែលអាចឱ្យរដ្ឋាភិបាលកម្ពុជាអនុវត្តនូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់ខ្លួន ដែលអាចសម្រេចបាននៅក្នុងស្ថានភាព របស់ប្រទេសកម្ពុជា និងមិនបង្កើតឱ្យមានឧបសគ្គដល់កំណើនសេដ្ឋកិច្ច។

នៅក្នុងអត្ថបទលំអិត យើងបានលើកឡើងនូវបញ្ហាប្រឈមចំនួន ៦ និងឱកាសចំនួន ៥។ បន្ទាប់មកទៀតយើងបានវាយតម្លៃទៅលើប្រភពចំនួន ៣ ដែលអាចផ្តល់ហិរញ្ញប្បទានដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព រួមទាំងមានការលើកឡើងនូវយោបល់សំខាន់ៗ សម្រាប់ជាគំនិតពិចារណាក្នុងការធ្វើមូលដ្ឋានីយកម្មនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សម្រាប់ប្រទេសកម្ពុជា។

**បញ្ហាប្រឈមះ ទីមួយ** កំណើនសេដ្ឋកិច្ចដែលខ្ពស់ និងជាប់ៗគ្នារបស់ប្រទេសកម្ពុជាក្នុងរយៈពេលពីរទស្សវត្សរ៍កន្លងមកនេះ បានប៉ះពាល់ដល់បរិស្ថាន នេះបានន័យថា ប្រទេសកម្ពុជាជួបការលំបាកហើយពុំអាចសម្រេចបានកំណើនសេដ្ឋកិច្ច ដែលមាននិរន្តរភាពបរិស្ថាន នៅក្នុង

គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនោះឡើយ។ **ទីពីរ** វត្ថុបំណងស្នូលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពគឺការពង្រឹងស្ថានប័នរដ្ឋ អភិបាលកិច្ចល្អ និងនីតិរដ្ឋ។ នាពេលបច្ចុប្បន្ននេះ យើងទទួលស្គាល់ច្រើនជាងមុនដែលថា កម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ដែលបានឆ្លងកាត់អំពើប្រល័យពូជសាសន៍ និងសង្គ្រាមជាច្រើនទសវត្សរ៍ ដែលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ថាប័នផ្លូវការទាំងអស់។ នៅពេលដែលមានសម្ពាធ និងការប្រឹងប្រែងខ្លាំង ក្នុងការពង្រឹងស្ថាប័នមួយដែលខ្លាំង និងមានអព្យាក្រិតយ៉ាងលឿននោះ អាចនឹងមានហានិភ័យ ដល់សន្តិភាព និងស្ថេរភាព ដែលរកបានដោយលំបាក។ ហើយបញ្ហានេះអាច នឹងនាំឱ្យមានដំណើរដើរថយក្រោយនៃការអភិវឌ្ឍ។ **ទីបី** ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដោយផ្អែកលើគោលដៅចំនួន ១៧ និងមាន១៦៩ ចំណុចគោលដៅ ដែលបានស្នើឡើងអាចនឹងធ្វើឱ្យមានបញ្ហាប្រឈមខ្លាំងដល់រដ្ឋាភិបាលដែលមិនទាន់មានចំនួនមន្ត្រី ដែលមានសមត្ថភាពគ្រប់គ្រាន់នៅឡើយ។ **ទីបួន** ផែនការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាឯកសារដូចគ្នានៅលើក្រដាស ប៉ុន្តែខុសគ្នាសម្រាប់ការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ ក្នុងការសម្រេចបានផែនការអភិវឌ្ឍន៍ប្រទេសកម្ពុជា ការសម្រេចបានកំណើន និងការកាត់បន្ថយភាពក្រីក្រមានសារៈសំខាន់ជាងអភិបាលកិច្ច។ **ទីប្រាំ** ប្រទេសកម្ពុជានៅតែត្រូវធ្វើការច្រើនជាងមុន ដើម្បីកែលម្អក្រុមប្រជាជនស្ថិតក្នុងស្ថានភាព "ជិតក្រ" និងក្រុមប្រជាជនដែលស្ថិតក្នុងស្ថានភាព "ភាពក្រីក្រថ្មី" ដើម្បីឱ្យពួកគេទាំងនោះទទួលបានផ្លែផ្កាពីកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា។ **ទីប្រាំមួយ** ការសម្របសម្រួលរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនៅតែមានភាពទន់ខ្សោយ ឬខ្វះខាតនៅឡើយ។

**ឱកាសៈ** **ទីមួយ** គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៅតែជាវេទិកាមួយជាយុទ្ធសាស្ត្រ ដែលល្អសម្រាប់ការកៀរគរធនធាន។ **ទីពីរ** ខណៈដែលអភិបាលកិច្ចកំពុងនៅពីក្រោយអាទិភាពកំណើន និងការកាត់បន្ថយភាពក្រីក្រ យើងក៏បានមើលឃើញអំពីសញ្ញានៃការកែលម្អអភិបាលកិច្ចផងដែរ។ **ទីបី** រដ្ឋាភិបាលបានបង្ហាញនូវសមត្ថភាពប្រសើរជាងមុន ក្នុងរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន និងការគ្រប់គ្រងដែលមានលក្ខណៈប្រែប្រួល សម្រាប់ទំនាក់ទំនងក្នុងចំណោមម្ចាស់ជំនួយចាស់ និងម្ចាស់ជំនួយថ្មី។ **ទីបួន** ប្រទេសកម្ពុជាអាចនឹងទទួលបានអត្ថប្រយោជន៍ពីសហគមន៍សេដ្ឋកិច្ចអាស៊ាន បើទោះបីជា ត្រូវការធ្វើកំណែទម្រង់លើបញ្ហាជាច្រើនក៏ដោយ។

**ការផ្តល់ហិរញ្ញប្បទានលើគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពៈ** **ទីមួយ** ដោយស្ថិតនៅក្រោមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រទេសកម្ពុជាបានកែលម្អសមត្ថភាពរដ្ឋបាលការងារពន្ធរបស់ខ្លួន ជាលទ្ធផលចំណូលដែលទទួលបានពីការប្រមូលពន្ធមានការកើនឡើងក្នុងអំឡុងពេលថ្មីៗនេះ។ **ទីពីរ** ខណៈដែលប្រទេសកម្ពុជាជួបការលំបាកក្នុងការព្យាករណ៍អំពីនិន្នាការកំណើនសេដ្ឋកិច្ច សម្រាប់អំឡុងពេលទាំងស្រុងនៃគោលដៅអភិវឌ្ឍន៍ប្រកប ដោយ

និរន្តរភាពរដ្ឋាភិបាលបានបង្ហាញការប្តេជ្ញាចិត្ត និងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការរក្សានូវកំណើន សេដ្ឋកិច្ច។ ជាលទ្ធផល ប្រទេសកម្ពុជាអាចនឹងទទួលបានកំណើនយ៉ាងហោចណាស់ក៏ត្រឹមកម្រិត មធ្យមដែរសម្រាប់រយៈពេលមធ្យម។ **ទីបី** ប្រទេសកម្ពុជាអាចនឹងរក្សាបាននូវកម្រិតសមរម្យមួយនៃ ធនធានហិរញ្ញវត្ថុ ពីខាងក្រៅក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយសារតែ ប្រទេសកម្ពុជាមានទីតាំងល្អដែលទាក់ទាញប្រទេសចិន និងប្រទេសជប៉ុន ប្រកួតប្រជែងគ្នា ដើម្បី ទទួលបានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ម្ចាស់ជំនួយផ្សេងទៀត មានដូចជា សហភាពអឺរ៉ុប អាចនឹងនៅតែបន្តផ្តល់ការគាំទ្រដល់ប្រទេសកម្ពុជា និងដៃគូអង្គការមិនមែនរដ្ឋា ភិបាល ដើម្បីជួយដល់ប្រជាជនក្រីក្រ ដែលទទួលបានអត្ថប្រយោជន៍តិចតួចពីកំណើន សេដ្ឋកិច្ច។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់បរិបទកម្ពុជា៖** យើងបានផ្តល់នូវ យោបល់ជាច្រើនសម្រាប់ធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់ ប្រទេសកម្ពុជា។ **ទីមួយ** គោលដៅអភិវឌ្ឍន៍សហវត្សរ៍របស់ប្រទេសកម្ពុជា ដែលមិនទាន់ត្រូវបាន សម្រេចបាននៅឡើយ ត្រូវតែរក្សាទុកបន្តទៀតសម្រាប់ការអនុវត្ត។ **ទីពីរ** ការពង្រឹងស្ថាប័ន ប្រទេស កម្ពុជាបង្ហាញនូវការរីកចម្រើនមួយកម្រិត ដែលទាមទារចាំបាច់ឲ្យរាជរដ្ឋាភិបាលមានប្តេជ្ញាចិត្តខ្ពស់ ក្នុងការពង្រឹងស្ថាប័នបន្ថែមទៀត។ **ទីបី** គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលមានក្រៅ ពីនេះ ដែលផ្តោតសំខាន់ទៅលើនិរន្តរភាពបរិស្ថាន ប្រទេសកម្ពុជាត្រូវការធ្វើការស្រាវជ្រាវមុនពេល ដែលប្រទេសកម្ពុជាអាចព្រមព្រៀងទៅលើគោលដៅទាំងនោះ។

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ចំពោះអស់លោក/លោកស្រី ព្រមទាំងស្ថាប័ន ដែលបានចូលរួម និងជួយសម្រួលក្នុងការសិក្សាស្រាវជ្រាវ។

ជាបឋម យើងសូមថ្លែងអំណរគុណចំពោះការចូលរួមចំណែករបស់អស់លោក/លោកស្រី មកពីខាងវិស័យអភិវឌ្ឍន៍ រដ្ឋាភិបាល និងឯកជន។ ក្នុងវិស័យអភិវឌ្ឍន៍ មនុស្សដែលមានសារតាខុសៗគ្នា ត្រូវបានសម្ភាសន៍ ដូចជា ទីភ្នាក់ងារសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកវិភាគឯករាជ្យ។ ជាសរុប យើងបានសម្ភាសមនុស្ស ៨នាក់ មកពីវិស័យនេះ។ យើងក៏ទទួលបានព័ត៌មានដ៏មានប្រយោជន៍ពីការពិភាក្សាជាមួយតំណាងវិស័យឯកជន ៣រូប រួមមាន សហគ្រាសខ្នាតតូច-មធ្យម ក្រុមហ៊ុនធានារ៉ាប់រង និងសេវាពាណិជ្ជកម្ម។ យើងបានព្យាយាមសុំធ្វើការសម្ភាសតំណាងពីរដ្ឋាភិបាល ប៉ុន្តែដោយសារកម្រិតនៃការបដិសេធក្នុងការផ្តល់បទសម្ភាសមានកម្រិតខ្ពស់ យើងអាចគ្រាន់តែសម្ភាស ជាមួយតំណាងរដ្ឋាភិបាលតែមួយរូបប៉ុណ្ណោះ។ យើងសូមថ្លែងអំណរគុណចំពោះអ្នកចូលរួម ដែលបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ជាមតិយោបល់ និងព័ត៌មានដ៏មានតម្លៃ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ដែលមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះផងដែរ។ យើងសូមកោតសរសើរចំពោះការចូលរួមចំណែកពីអ្នកទាំងអស់គ្នា ដែលមកពីគ្រប់មជ្ឈដ្ឋានផ្សេងៗ។

ជាបន្ទាប់ យើងសូមអរគុណចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកនៃអង្គការ CCC ដែលបានផ្តល់ការគាំទ្រពិសេស ដើម្បីឱ្យគម្រោងនេះមានដំណើរប្រកបដោយភាពរលូន។ យើងសូមអរគុណចំពោះលោក សឿង សារឿន នាយកប្រតិបត្តិនៃអង្គការ CCC សម្រាប់ការគាំទ្រក្នុងការប្រមូលព័ត៌មានសំខាន់ៗសម្រាប់ធ្វើបទសម្ភាសក្នុងគម្រោងនេះ និងចំណាយពេលវេលារបស់លោកសម្រាប់បទសម្ភាសស្តីពីប្រធានបទដែលស្ថិតក្រោមការអង្កេតតាមដាន។ យើងក៏សូមថ្លែងអំណរគុណចំពោះការជួយគាំទ្ររបស់លោក ជេន សុជឿន និង លោក មី ណាក់ ដែលជាបុគ្គលិកអង្គការ CCC សម្រាប់ការចូលរួមយ៉ាងសកម្មក្នុងការផ្តល់ឯកសារពាក់ព័ន្ធថ្មីៗនឹងប្រធានបទដែលបានសិក្សា និងបានផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតសម្រាប់ធ្វើបទសម្ភាស។ យើងក៏សូមអរគុណចំពោះបុគ្គលិកអង្គការ CCC ដទៃទៀត ដែលចូលរួមចំណែកក្នុងគម្រោងនេះ។

យើងសូមថ្លែងអំណរគុណផងដែរ ចំពោះក្រុមការងារអង្គការ CCC សម្រាប់ការផ្តល់ជាមតិយោបល់ក្នុងសេចក្តីព្រាងដំបូងនៃរបាយការណ៍នេះ។ រាល់មតិយោបល់ និងព័ត៌មានត្រឡប់ ពិតជាជួយជម្រុញឱ្យយើងអាចឆ្លើយតប នឹងសំណួរមួយចំនួន ដែលនៅមិនទាន់បានដោះស្រាយក្នុងរបាយការណ៍នេះ។ លទ្ធផលចុងក្រោយ ឆ្លុះបញ្ចាំងអំពីធាតុចូល និងសំណួររបស់ពួកគេ។

ប្រសិនបើគ្មានការចូលរួមរបស់អ្នកទាំងអស់គ្នា ដូចបានរៀបរាប់ខាងលើនោះទេ របាយការណ៍នេះ នឹងមិនអាចត្រូវបានរៀបចំឡើងប្រកបដោយគុណភាព និងមានភាពស៊ីជម្រៅ ដូចក្នុងទម្រង់បច្ចុប្បន្ននេះឡើយ។ ទោះបីយ៉ាងណា យើងក៏នៅតែមានភាពខ្វះខាតសម្រាប់របាយការណ៍ចុងក្រោយដែរ។

*(អត្ថបទបកប្រែពីភាសាអង់គ្លេស)*

# តារាងពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCF | វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CG | ក្រុមពិគ្រោះយោបល់ |
| CMDGs | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា |
| DFID | នាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិ, UK |
| EU | សហគមន៍អឺរ៉ុប |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FfD | ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ |
| GDCC | គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ |
| GDP | ផលិតផលក្នុងស្រុកសរុប (ផសស) |
| IDP | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| ILO | អង្គការពលកម្មអន្តរជាតិ |
| INGOs | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| LICs | ប្រទេសមានចំណូលទាប |
| MDGs | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MICs | ប្រទេសចំណូលមធ្យម |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព |
| SMEs | សហគ្រាសខ្នាតតូច និងមធ្យម |
| TWG | ក្រុមការងារបច្ចេកទេស |
| WB | ធនាគារពិភពលោក |

# សេចក្តីផ្តើម

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ត្រូវបានផ្តល់ការគាំទ្រ បន្ទាប់ពីសេចក្តីប្រកាសសហស្សវត្សរ៍របស់អង្គការសហប្រជាជាតិក្នុងឆ្នាំ២០០០ ហើយនឹងត្រូវបញ្ចប់នាខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ។ របៀបវារៈនៃការអភិវឌ្ឍន៍ក្រោយ (MDGs) ឆ្នាំ២០១៥ គឺគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) កំពុងត្រូវបានរៀបចំដោយរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ក្រោមការដឹកនាំ និងការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ។ ក្នុងចំណោមរឿងជាច្រើន នៅពេលដែល MDGs បានគិតគូរក្នុងការកាត់បន្ថយភាពក្រីក្រជាសាកលឱ្យបានត្រឹមពាក់កណ្តាល រីឯ SDGs មានគោលដៅ ចម្បងក្នុងចំណោមគោលដៅជាច្រើន ធ្វើការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លានក្នុងពិភពលោក ត្រឹមឆ្នាំ២០៣០ និងដាក់បញ្ចូលនិរន្តរភាពបរិស្ថានទៅក្នុងរបៀបវារៈសម្រាប់គាំទ្រដល់អ្នកក្រីក្រ។

កម្ពុជានឹងចូលរួមអនុវត្ត SDGs។ ហេតុដូច្នេះ តើ SDGs មានអត្ថន័យយ៉ាងដូចម្តេចចំពោះរដ្ឋាភិបាល និងអ្នកអភិវឌ្ឍន៍ជាច្រើនទៀត និងតើរដ្ឋាភិបាលគួរធ្វើយ៉ាងណា ដើម្បីឱ្យ SDGs អាចអនុវត្តទៅបាននៅក្នុងបរិបទរបស់ខ្លួន ចំបាច់ត្រូវធ្វើការត្រួតពិនិត្យដ៏ហ្មត់ចត់? គោលបំណងនៃរបាយការណ៍នេះ[1]គឺដើម្បីឆ្លើយតបនឹងសំណួរទាំងនេះជាលក្ខណៈមូលដ្ឋាន និងទ្រឹស្តី ដូច្នេះអ្នកអភិវឌ្ឍន៍នឹងមានព័ត៌មានមូលដ្ឋានសម្រាប់ប្រើប្រាស់ ហើយសម្លេង និងក្តីកង្វល់របស់កម្ពុជានឹងត្រូវបានលើកឡើងក្នុងសន្និសីទសហប្រជាជាតិក្នុងខែកញ្ញា ឆ្នាំ២០១៥នេះ។

## សេចក្តីសង្ខេបអំពីគោលបំណងនៃរបាយការណ៍ និងលទ្ធផលរកឃើញសំខាន់ៗ

គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីពិនិត្យអំពីកម្រិតដែលកម្ពុជាបានត្រៀមខ្លួនក្នុងការសម្រេចនូវ SDGs ផ្អែកលើការវិភាគនៃយន្តការ/ក្របខ័ណ្ឌអភិវឌ្ឍន៍មានស្រាប់ និងគោលនយោបាយផ្សេងៗ ដែលកម្ពុជាបានបង្កើត។ ក្នុងចំណោមគោលបំណងសំខាន់ៗ របាយការណ៍នេះ ទីមួយគឺបង្ហាញនូវភាពផ្ទុយគ្នា ឬ ភាពតានតឹង រវាងទស្សនៈអន្តរជាតិនៃ SGDs និងផែនការអភិវឌ្ឍន៍កម្ពុជាសំខាន់ៗ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទីពីរ របាយការណ៍នេះផ្តល់នូវការវិភាគលើ

[1] ជាការល្អ គួរកត់សម្គាល់ថា របាយការណ៍នេះ នឹងមិនលើកឡើងអំពីការវិភាគជាលម្អិតឡើយ ដូច្នេះ សេចក្តីលម្អិតអំពីការវិភាគនេះនឹងទុកសម្រាប់ការសិក្សានាពេលខាងមុខទៀត។

បញ្ហាប្រឈម និងឱកាសសម្រាប់កម្ពុជា និងប្រសិនបើចាំបាច់ លើកឡើងនូវរូបភាពទូទៅមួយនៃ SDGs របស់កម្ពុជា ដែលគួរតែរៀបចំឡើង។

ជារួម អ្វីដែលជាគោលបំណងសំខាន់ដែលយើងចង់លើកឡើងគឺកម្ពុជាបង្ហាញនូវសមត្ថភាពរបស់ខ្លួន ជាពិសេស សមត្ថភាពក្នុងការកៀគរធនធាន ដើម្បីអនុវត្ត SDGs បានច្រើនជាងក្នុងអំឡុងពេលអនុវត្ត CMDGs អស់រយៈពេល១៥ឆ្នាំកន្លងទៅ។ បញ្ហាប្រឈមចម្បងរបស់កម្ពុជា គឺការចរចារជាមួយអន្តរជាតិ ដោយធ្វើយ៉ាងឱ្យរដ្ឋាភិបាលអាចអនុវត្ត SDGs របស់ខ្លួននៅកម្ពុជា បានក្នុងបរិបទប្រទេសរបស់ខ្លួន និងមិនធ្វើឱ្យកំណើនមានភាពយឺតយ៉ាវខ្លាំង។

## វិធីសាស្ត្រ និងវិសាលភាពនៃរបាយការណ៍

របាការណ៍នេះត្រូវបានព្រាងដូចតទៅ ៖ របាយការណ៍នេះនឹងដាក់ SDGs ដែលបានលើកឡើង និងគំនិត ព្រមទាំងទស្សនៈសំខាន់ៗ ដាច់ដោយឡែកប្រកបដោយភាពហ្មត់ចត់។ បន្ទាប់មកទៀត របាយការណ៍នេះនឹងប្រើប្រាស់គំនិតសំខាន់ៗនៃ *គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព* (SDGs) ដូចលោក Jeffrey Sachs បានលើកឡើង ដើម្បីប្រៀបធៀបជាមួយនឹងយន្តការ និងក្របខ័ណ្ឌអភិវឌ្ឍន៍មានស្រាប់របស់កម្ពុជា និងការអនុវត្តជាក់ស្តែងនូវយន្តការ និងក្របខ័ណ្ឌនេះ ដើម្បីលុបបំបាត់ភាពតានតឹង/ភាពខុសគ្នាដែលអាចមាន។ លោក Sachs (២០១២, p. ២២០៦) ស្នើឡើងថា នៅពេលមិនទាន់មានការឯកភាពគ្នាចំពោះនិយមន័យ នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការយល់ដឹងអំពីអ្វីមួយទាមទារនូវ "វិធីសាស្ត្រផ្តោតលើជ្រុងសំខាន់ទាំងបីសម្រាប់សុខុមាលភាពមនុស្ស...ការបញ្ចូលគ្នារវាងការអភិវឌ្ឍសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងបរិយាប័ន្នសង្គម" សម្រាប់កម្លាំងទាំងបីនេះ ត្រូវការការគាំទ្រផ្នែកអភិបាលកិច្ចល្អ។ សម្រាប់លោក Sachs ជាលម្អិត ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាវិធីចម្បងក្នុងការកាត់បន្ថយភាពក្រីក្រជាសាកល (បន្តពី MDGs)។ ទោះបីយ៉ាងណា ស្របតាមការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវពិចារណាអំពីនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីរបស់ភពផែនដីដែលទ្រទ្រង់ជីវិតគ្រប់ប្រភេទ។ លើសពីនេះ GDP និងចំណូលគ្រួសារ ត្រូវតែផ្លាស់ប្តូរពីវិធីបុរាណដែលផ្តល់ផលប្រយោជន៍ដល់មនុស្សតែមួយចំនួន ទៅជាការផ្តល់ផលប្រយោជន៍ដល់ទាំងអស់គ្នា ឬធានានូវសេចក្តីសុខទូទៅសម្រាប់ជាតិ។ លើសពីនេះ លោក Sachs បញ្ជាក់ដោយសង្កត់ថា អភិបាលកិច្ចល្អ ដែលនឹងរួមបញ្ចូលនៅគ្រប់កម្រិតទាំងអស់ ចាប់ពីកម្រិតពិភពលោកដល់កម្រិតមូលដ្ឋាន និងក្នុងរដ្ឋាភិបាល និងវិស័យឯកជន គឺជាមូលដ្ឋានក្នុងការកំណត់ភាពជោគជ័យនៃចំណុចសំខាន់ទាំងបីនៃការអភិវឌ្ឍដូចបានលើកឡើងខាងលើ។ ក្នុងចំណោមការប្តេជ្ញាចិត្តជាច្រើនលោកលើកឡើងអំពីការប្តេជ្ញាចិត្តចំពោះនីតិរដ្ឋ ការចូលរួម ការរួមបញ្ចូលគ្នា និងស្ថាប័នទាំងមូល។ មិនថាចំណុចល្អទាំងនេះ គឺចំណុចសំខាន់ទាំងបីនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពខាងលើ និង

អភិបាលកិច្ចល្អ អាចអនុវត្តបានស្របគ្នាឬក៏អត់ ចំណុចល្អទាំងនេះនឹងត្រូវបានវាយតម្លៃដូចខាងក្រោមក្នុងទម្រង់ជាបញ្ហាប្រឈម និងឱកាស។

ក្រៅពីនេះ របាយការណ៍នេះនឹងពិនិត្យលើប្រភពហិរញ្ញប្បទានផ្ទាល់ និងមិនផ្ទាល់សម្រាប់អនុវត្ត SDGs ដែលបែងចែកជាបីផ្នែកសំខាន់ៗ ៖ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកៀរគរធនធាន កំណើន និងការអភិវឌ្ឍវិស័យឯកជន និងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។ ផ្អែកលើការពិភាក្សាបែបវិភាគកន្លងមក គំនិត និងអនុសាសន៍សម្រាប់ SDGs កម្ពុជា ត្រូវបានលើកឡើង។ របាយការណ៍នេះត្រូវបានបញ្ចប់ដោយសេចក្តីសន្និដ្ឋានសង្ខេប។

ដើម្បីសម្រេចបានគោលបំណងខាងលើ របាយការណ៍នេះនឹងបង្ហាញអំពីការពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់នូវព័ត៌មានពាក់ព័ន្ធនឹងប្រធានបទ SDGs ជំនួយបរទេស MDGs និងការអភិវឌ្ឍជាសកល និងជាក់លាក់សម្រាប់កម្ពុជា ព្រមទាំងបទសម្ភាសជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ ការសិក្សានេះក៏ទទួលបានព័ត៌មានមានដ៏សំខាន់ពីសិក្ខាសាលាពិគ្រោះយោបល់ ដែលរៀបចំដោយអង្គការ CCC នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ដែលមានតំណាង NGOs ៧០ អង្គការ និងដៃគូម្ចាស់ជំនួយ និងមន្ត្រីរដ្ឋាភិបាល ១០ រូប បានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាអំពីរបាយការណ៍ព្រាង។ ក្នុងអំឡុងសិក្ខាសាលា មតិយោបល់សំខាន់ៗពីតំណាងក្រុមការងារនៃអង្គការសហប្រជាជាតិ និងការពិភាក្សាជាក្រុម ពិតជាផ្តល់សារៈប្រយោជន៍យ៉ាងខ្លាំង និងត្រូវបានយកមកពិចារណាសម្រាប់រៀបចំរបាយការណ៍ចុងក្រោយ។

## គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs)

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) បង្ហាញឱ្យឃើញពីគោលបំណងជាសាកល និងប្រវត្តិសាស្ត្រក្នុងការលើកកម្ពស់ និងពន្លឿនសុខុមាលភាពមនុស្ស។ ប្រទេសចំនួន ១៩២ បានឯកភាពលើបណ្តុំគោលដៅជាច្រើន ដែលនឹងត្រូវសម្រេចត្រឹមឆ្នាំ២០១៥។ ក្នុងចំណោមបណ្តុំគោលដៅទាំងនេះ រួមមាន ការកាត់បន្ថយភាពក្រីក្រជាសាកលឱ្យបានពាក់កណ្តាល សិស្សទាំងអស់ទទួលបានការសិក្សាកម្រិតមូលដ្ឋាន ការលើកកម្ពស់សុខភាពមាតា និងកុមារ ការលុបបំបាត់ការរើសអើងយេនឌ័រ ការការពារបរិស្ថាន និងការផ្តល់ជំនួយអន្តរជាតិបន្ថែម។ បន្ទាប់ពីការអនុវត្តបានជាងមួយទស្សវត្សរ៍ ការពិភាក្សាវែកញែកបែបទ្រឹស្តី និងគោលនយោបាយនៅថ្នាក់ពិភពលោក និងជាតិអំពី MDGs នៅតែបន្ត។

ផ្ទុយទៅវិញ ប្រទេសមានចំណូលទាបមួយចំនួន មិនបានសម្រេចនូវ MDGs ដោយសារមួយផ្នែកមកពីដៃគូអភិវឌ្ឍន៍មិនបានរក្សាពាក្យសន្យាក្នុងផ្តល់ជំនួយតាមការរំពឹងទុក (Sachs, ២០១២)។ ម្យ៉ាងវិញទៀត Ashwani Saith (២០០៦) មានគំនិតទុទិដ្ឋិនិយមថា ដោយសារសេដ្ឋកិច្ចនយោបាយ

ស្ថិតនៅខាងម្ចាស់ជំនួយ ដែលធ្វើឱ្យដំណើរការ MDG ប្រព្រឹត្តទៅដើម្បីសម្រេចនូវផលប្រយោជន៍ផ្ទាល់ខ្លួនពួកគេច្រើនជាង ដូច្នេះ ការសម្រេចបាននូវ MDGs គឺផ្អែកច្រើនទៅលើសមត្ថភាពនៃរដ្ឋទទួលបានជំនួយ។ នៅពេលប្រទេសដែលខ្លាំងជាង ដូចជា ចិន ឥណ្ឌា ឬ ប្រេស៊ីលកំពុងស្ថិតក្នុងស្ថានភាពល្អក្នុងការអភិវឌ្ឍកម្មវិធីជនជាតិដើមភាគតិច ដើម្បីសម្រេចបាន MDGs ប្រទេសក្រីក្រភាគច្រើនមិនមិនមានសមត្ថភាពក្នុងធ្វើបានបែបនេះ ហើយប្រទេសទាំងនេះនឹងមិនអាចសម្រេចបាន MDGs ឡើយ (ibid)។

ទោះបីយ៉ាងណា Green, Hale, និង Lockwood (២០១២) កត់សម្គាល់ថា MDGs អាចមានផលប៉ះពាល់មួយចំនួនលើគោលនយោបាយអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជា រដ្ឋាភិបាលជាច្រើនបានកំណត់អាទិភាពលើវិស័យសុខាភិបាល និងការអប់រំ ដោយផ្អែកលើ MDGs និងកែសម្រួល MDGs ដាក់ទៅក្នុងគោលនយោបាយរបស់ពួកគេ។ ការធ្វើបែបនេះឆ្លុះបញ្ចាំងអំពីភាពពិតដែលមិនអាចប្រកែកបានថា ជាទូទៅ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនបានកាត់បន្ថយភាពក្រីក្របានពាក់កណ្តាលចន្លោះឆ្នាំ១៩៩០ និងឆ្នាំ២០១០ (Sachs, ២០១២)។ តួលេខជាក់ស្តែងរបស់ UN បង្ហាញថា ភាពក្រីក្រខ្លាំងបានធ្លាក់ចុះច្រើនជាងបីដងពី ៤៧% ក្នុងឆ្នាំ១៩៩០ មកត្រឹមតែ ១៤% ប៉ុណ្ណោះក្នុងឆ្នាំ២០១៥ (UN, ២០១៥a)។ ក្រៅពីនេះ អ្នករៀបចំគោលនយោបាយ និងសង្គមស៊ីវិលយល់ស្របថា ភាពអត់ឃ្លាន និងជំងឺ ត្រូវបានកាត់បន្ថយយ៉ាងច្រើន (Sachs, ២០១២)។ ជារួម MDGs បានចូលរួមក្នុងការលើកកម្ពស់សុខុមាលភាពប្រជាជននៃប្រទេសកំពុងអភិវឌ្ឍន៍បានយ៉ាងច្រើន ដោយមិនអាចប្រកែកបាន (Sachs, ២០១២; Vandemoortele, ២០១១)។

ដើម្បីធានានូវភាពរីកចម្រើននេះ មានការឯកភាពថា ការប្រយុទ្ធប្រឆាំងភាពក្រីក្រជាសាកលត្រូវតែបន្តអនុវត្តក្នុងបរិបទបច្ចុប្បន្ន នៅពេលដែលការប្រែប្រួលអាកាសធាតុ និងការបំផ្លាញបរិស្ថានធ្ងន់ធ្ងរគឺជាបាតុភាពជាក់ស្តែងនៃការអភិវឌ្ឍ (Sachs, ២០១២)។ ហេតុដូច្នេះ SDGs ដែលបានលើកឡើង ត្រូវបានរៀបចំឡើង ដោយរួមបញ្ចូលគោលដៅទាំង ១៧ ដូចមានក្នុងកំណត់សម្គាល់ខាងក្រោម[2]។ លក្ខណៈសំខាន់បួននៃ SDGs ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់។ ខុសគ្នាពី MDGs

[2]គោលដៅ ១ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ នៅគ្រប់ទីកន្លែង
គោលដៅ ២ បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរជាងមុន និងលើកកម្ពស់កសិកម្មមាននិរន្តរភាព
គោលដៅ ៣ ធានាឲ្យមានជីវភាពប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពសម្រាប់មនុស្សគ្រប់រូប នៅគ្រប់វ័យ
គោលដៅ ៤ ធានាឲ្យមានការអប់រំប្រកបដោយគុណភាពជាបរិយាប័ន្ន និងដោយសមធម៌ ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប
គោលដៅ ៥ សម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចនៃស្ត្រី និងកុមារីគ្រប់រូប
គោលដៅ ៦ ធានាវត្តមានទឹក និងការគ្រប់គ្រងទឹក និងអនាម័យដោយនិរន្តរភាពសម្រាប់មនុស្សគ្រប់រូប

ជាដំបូង SDGs ផ្តោតលើតួនាទីចម្បង និងកិច្ចសហប្រតិបត្តិការទាំងជាមួយប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ចំណែក MDGs ផ្តោតភាគច្រើនលើការទទួលខុសត្រូវរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលបានការគាំទ្រផ្នែកធនធាន (ហិរញ្ញប្បទាន និងបច្ចេកទេសពីខាងក្រៅ) ពីរដ្ឋាភិបាលប្រទេសអភិវឌ្ឍន៍។ ទីពីរ កិច្ចព្រមព្រៀងក្រោយឆ្នាំ២០១៥ នឹងផ្តោតជាងមុនលើបរិបទក្នុងស្រុក ពីព្រោះរដ្ឋាភិបាលបង្កើនទំនាក់ទំនងអន្តរជាតិជាច្រើន មានសមត្ថភាពកាន់តែខ្លាំងក្នុងបង្កើនចំណូលក្នុងស្រុក និងបន្តពឹងផ្អែកកាន់តែតិចលើជំនួយ (Green et al., ២០១២)។ អាចនិយាយបានម៉្យាងទៀតថាជាមួយ SDGs ការផ្តោតចិត្តទុកដាក់ត្រូវបានផ្លាស់ប្តូរដោយផ្តោតលើការពង្រឹងភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពរបស់រដ្ឋាភិបាលដែលធ្លាប់ពឹងផ្អែកលើជំនួយខាងក្រៅពីម្ចាស់ជំនួយបរទេស នៅពេលអនុវត្ត MGDs។ បើសម្លឹងមើលទៅមុខ រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ទាំងនោះ ត្រូវបានរំពឹងថា ត្រូវបង្កើនចំណូលក្នុងស្រុកបន្ថែមទៀតពីកំណើនសេដ្ឋកិច្ច និងពីកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ (south south cooperation) ដែលជំនួយបានមកពីម្ចាស់ជំនួយថ្មីអាចបំពេញបន្ថែមលើជំនួយបានមកពីម្ចាស់ជំនួយមានស្រាប់កន្លងមក។ ទីបីដូចបានលម្អិត ខាង

---

គោលដៅ ៧ ធានាឲ្យមានការទទួលបានថាមពល ក្នុងតម្លៃដែលអាចជាវបាន ជឿទុកចិត្តបាន មាននិរន្តរភាព និងទំនើបសម្រាប់មនុស្សគ្រប់រូប

គោលដៅ ៨ លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព មុខរបរពេញលេញ និងដែលផ្តល់ផល និងការងារសមរម្យសម្រាប់មនុស្សគ្រប់រូប

គោលដៅ ៩ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មជាបរិយាប័ន្ន និងដែលមាននិរន្តរភាព និងលើកស្ទួយនវានុវត្តន៍

គោលដៅ ១០ កាត់បន្ថយវិសមភាពនៅក្នុង និងរវាងប្រទេសនានា

គោលដៅ ១១ ធ្វើឱ្យទីក្រុង និងកន្លែងតាំងលំនៅដ្ឋានរបស់មនុស្សមានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់ និងមាននិរន្តរភាព

គោលដៅ ១២ ធានាឲ្យមានការប្រើប្រាស់ និងផលិតកម្មតាមទម្រង់ដែលមាននិរន្តរភាព

គោលដៅ ១៣ ចាត់វិធានការជាបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ *

គោលដៅ ១៤ អភិរក្ស និងប្រើប្រាស់មហាសាគរ សមុទ្រ និងធនធានសមុទ្រដោយនិរន្តរភាព សម្រាប់ការអភិវឌ្ឍដោយនិរន្តរភាព

គោលដៅ ១៥ ការពារ ស្តារ និងជម្រុញការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីផែនដីដោយនិរន្តរភាព គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការប្រយុទ្ធប្រឆាំងនឹងឱនភាពដី និងបញ្ឈប់ ព្រមទាំងបង្វែរទិសនៃការរិចរឹលគុណភាពដី និងបញ្ឈប់ការបាត់បង់ជីវៈចម្រុះ

គោលដៅ ១៦ លើកកម្ពស់សង្គមមានសន្តិភាព និងជាបរិយាប័ន្ន សម្រាប់ការអភិវឌ្ឍដោយនិរន្តរភាព ផ្តល់យុត្តិធម៌ដល់មនុស្សគ្រប់រូប និងកសាងបរិយាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់លំដាប់ថ្នាក់

គោលដៅ ១៧ ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើនភាពរស់រវើកនៃភាពជាដៃគូសាកលសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ក្រោម SDGs ផ្តោតយ៉ាងខ្លាំងលើការការពារបរិស្ថាន។ ប្រហែលជាជិតពាក់កណ្តាលនៃគោលដៅ SDGs ផ្តោតលើបរិស្ថានដោយផ្ទាល់ និងមិនផ្ទាល់។ ទីបួន ខុសគ្នាពី MDGs កន្លងមក ដែលត្រូវបានរិះគន់លើវិធីសាស្ត្របែបមជ្ឈការ ដែលផ្តោតចម្បងលើបណ្តុំទស្សនវិស័យពិសេស ដែលមានលក្ខណៈចង្អៀតចង្អល់ SDGs អនុវត្តនូវដំណើការធ្វើការសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធចម្រុះ តាមរយៈការចូលរួមពីផ្នែកធុរកិច្ច សហគមន៍ រដ្ឋាភិបាលតាមមូលដ្ឋាន និងអង្គការសង្គមស៊ីវិលជាច្រើនទៀត (Geoghegan, ២០១៣)។

## *តើមានអ្វីខុសផ្លែកសម្រាប់ SDGs?*

គោលដៅទាំង ១៧ និងចំណុចដៅទាំង ១៦៩ ត្រូវបានកំណត់ក្រោមទស្សនវិស័យ និងការរំពឹងថា អ្វីៗល្អទាំងអស់នឹងដើរទន្ទឹមគ្នា ដែលមានសេចក្តីលម្អិតមួយចំនួន រួមមាន "... ពិភពលោកគ្មានភាពក្រីក្រ ភាពអត់ឃ្លាន ជំងឺ និងសេចក្តីប្រាថ្នា... ពិភពលោកដែលមានការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាសាកល នីតិរដ្ឋ យុត្តិធម៌...សន្តិភាព..." (UN, ២០១៥b, p.៥) និងចំណុចជាច្រើនទៀត។ អង្គការសហប្រជាជាតិផ្ទាល់ទទួលស្គាល់ថា គោលដៅ និងចំណុចដៅទាំងនេះតំណាងឱ្យ "... ទស្សនៈដែលអាចផ្លាស់ប្តូរបាន និង*មានមហិច្ឆិតាខ្ពស់បំផុត*" (UN, ២០១៥b, p. ៥ បានបន្ថែមការផ្តោតចិត្តទុកដាក់) និង "ការបញ្ចូលគ្នា និងមិនអាចបែងចែកចេញពីគ្នាបាន" (ibid: p.៧)។ គោលដៅ និងចំណុចដៅទាំងនេះ គឺជាគោលដៅមានមហិច្ឆិតាខ្ពស់ ជាពិសេស នៅពេលធ្វើការវិភាគលើភាពតានតឹងរវាងកំណើនខ្ពស់ ដែលកាត់បន្ថយភាពក្រីក្រ និងលទ្ធភាពអាចថែរក្សាបរិស្ថានបាន។ ការងារនេះមានភាពលំបាកក្នុងការសម្រេចបាន សូម្បីក្នុងចំណោមប្រទេសអភិវឌ្ឍន៍ដូចជា កាណាដា និងសហរដ្ឋអាមេរិក (Gore & Stoett, ២០០៩)។ ភាពតានតឹងសំខាន់មួយទៀតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ គឺការដាក់សម្ពាធពីដៃគូអភិវឌ្ឍន៍ ឱ្យសម្រេចបាននូវសន្តិភាព ស្ថេរភាព និងនីតិរដ្ឋក្នុងពេលតែមួយ។ ការសិក្សាខុសៗគ្នាជាច្រើនត្រូវបានចងក្រងជាឯកសារស្តីពីការបង្ខំជំរុញឱ្យមាននីតិរដ្ឋលឿនពេក ធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាព (Fukuyama, ២០១៤)។ ខាងក្រោមនេះ បង្ហាញអំពីករណីប្រទេសកម្ពុជា ដែលនឹងត្រូវលើកមកពិនិត្យ។

## កម្ពុជា ៖ ការប្តូរពី CMDGs ទៅជា SDGs

### *CMDGs ៖ តើកម្ពុជាអនុវត្តបានកម្រិតណាហើយ ?*

ដើម្បីដឹងអំពីកម្រិតដែលកម្ពុជាបានត្រៀមខ្លួនក្នុងការសម្រេចនូវ SDGs ចាំបាច់ត្រូវពិនិត្យមើលថា តើកម្ពុជាបានអនុវត្តយ៉ាងដូចម្តេចពាក់ព័ន្ធនឹង CMDGs។ ជារួម កម្ពុជាបានសម្រេចនូវគោលដៅយ៉ាងតិចបួន[3] ក្នុងចំណោមបណ្តុំគោលដៅទាំង៩ (ការគាំពារកុមារ សុខភាពមាតា ជំងឺឆ្លង និងភាពជាដៃគូ) ហើយកម្ពុជាកំពុងឈានទៅកាន់តែជិតក្នុងការឆ្លើយតបនឹងគោលដៅកាត់បន្ថយភាពក្រីក្រ (ភាពក្រីក្របានធ្លាក់ចុះពី ៤៧.៨% ក្នុងឆ្នាំ២០០៧ មកត្រឹម ១៩.៨% ក្នុងឆ្នាំ២០១១ ដែលធ្លាក់ចុះត្រឹមតែ ០.៣% លើចំណុចដៅ ១៩.៥%) (RGC, ២០១៣, ២០១៤a)។

រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាក្នុងការសម្រេចឱ្យបាននូវ CMDGs ដោយសារកម្ពុជាបានដាក់បញ្ចូលគោលដៅទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០១៤-២០១៨ និងផែនការសំណៅមុន)។ ហេតុដូច្នេះ មន្ត្រីសាមីសហការជាមួយគ្នាក្នុងការសម្រេចឱ្យបាននូវ MDGs និងគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងនោះ។ រដ្ឋាភិបាលបានបន្តដាក់ចេញនូវក្របខ័ណ្ឌពន្លឿន CMDG ក្នុងគោលបំណងពន្លឿនវឌ្ឍនភាពនៃ MDGs និងគោលដៅអភិវឌ្ឍន៍មនុស្សផ្សេងទៀត (RGC, ២០១៤b)។ ទោះបីយ៉ាងណា នៅពេល CMDGs ដើរតួនាទីបានល្អក្នុងផែនការអភិវឌ្ឍន៍ជាតិ អ្វីដែលគួរកត់សម្គាល់ គឺមិនមានយន្តការពិសេស ដែលអាចលើកកម្ពស់ CMDGs បានជាពិសេសឡើយ។ ការនេះបង្ហាញថា នៅពេលរដ្ឋាភិបាលយល់ដឹងអំពីសារៈសំខាន់នៃ CMDGs ក្របខ័ណ្ឌមានស្រាប់ដែលសម្របសម្រួលដោយក្រសួងផែនការ ត្រូវបានប្រើប្រាស់ជាទូទៅដើម្បីសម្រេចបានគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង CMDGs ក្នុងពេលតែមួយ។ ភាពជោគជ័យ និងការមិនសម្រេចបាន CMDGs តាមការកំណត់ទុក ត្រូវបានកំណត់ដោយកត្តាខុសៗគ្នាជាច្រើនដូចខាងក្រោម។

---

[3] យើងសុំរំលឹកអំពីការប្រកាសរបស់រដ្ឋាភិបាលថា កម្ពុជាបានសម្រេចបាននូវ CMDG ប្រាំបី ស្តីពី "ការពង្រឹងភាពជាដៃគូជាសាកលសម្រាប់ការអភិវឌ្ឍ"។ ការវាយតម្លៃចុងក្រោយរបស់រដ្ឋាភិបាល (RGC, ២០១៤a) លើ CMDGs ដែលអះអាងថា កម្ពុជាសម្រេចបាននូវ MGD ៨ ធ្វើឱ្យមានការគិតថា កម្ពុជាបានទទួលជំនួយច្រើនជាងមួយពាន់លានដុល្លារអាមេរិកពីប្រភពខាងក្រៅតាំងពីឆ្នាំ២០០៨ជារៀងរាល់ឆ្នាំ។ ហិរញ្ញប្បទានពីខាងក្រៅដែលមានចន្លោះពី ៨ ទៅ ៩ ភាគរយនៃ GDP ត្រូវបានរដ្ឋាភិបាលអះអាងថា បានយកទៅប្រើប្រាស់ក្នុងការចូលរួមចំណែកក្នុងការរក្សាកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងវិះរកមធ្យោបាយសម្រាប់កម្ពុជាសម្រេចបាន MDGs ផ្សេងទៀត។ យើងសូមអបអរចំពោះរដ្ឋាភិបាល ដែលមានសមត្ថភាពទទួលបានហិរញ្ញប្បទានពីខាងក្រៅសម្រាប់គាំទ្ររបៀបវារៈអភិវឌ្ឍន៍ក្នុងស្រុក។ ទោះបីយ៉ាងណា វាមិនមានន័យថា ប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ជាក់ស្តែង ដូចបង្ហាញក្នុងផ្នែកបញ្ហាប្រឈម ការសម្របសម្រួលរវាងដៃគូ និង CSOs នៅតែមានភាពទន់ខ្សោយ ឬ មិនទៀងទាត់ ស្ថិតក្រោមលក្ខខណ្ឌអនុគ្រោះបំផុត។

ដំបូង មានការឯកភាពជាទូទៅថា កំណើនជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់របស់កម្ពុជា ៧.៨% ដែលសម្រេចបានក្នុងចន្លោះឆ្នាំ ១៩៩៤ និង ២០១១ បានរួមចំណែកយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ (ADB ២០១៣ CDRI ២០១៣ RGC ២០១៤a)។

**តារាង ១ ៖ សេចក្តីសង្ខេបអំពីវឌ្ឍនភាពនៃ CMGDs**

| CMDGs | ការវាយតម្លៃ |
|---|---|
| CMDG ១ ៖ ភាពក្រីក្រ | បានឆ្លើយតបក្នុងសូចនាករសំខាន់ៗ |
| CMDG ២ ៖ ការអប់រំមូលដ្ឋាន | ភាគច្រើនទំនងជាបានឆ្លើយតបក្នុងសូចនាករសំខាន់ៗ |
| CMDG ៣ ៖ យេនឌ័រ | បានឆ្លើយតបក្នុងសូចនាករសំខាន់ៗ |
| CMDG ៤ ៖ សុខភាពកុមារ | បានឆ្លើយតប |
| CMDG ៥ ៖ សុខភាពមាតា | បានឆ្លើយតប |
| CMDG ៦ ៖ ជំងឺឆ្លង | បានឆ្លើយតប |
| CMDG ៧ ៖ បរិស្ថាន | បានឆ្លើយតបក្នុងសូចនាករសំខាន់ៗ |
| CMDG ៨ ៖ ភាពជាដៃគូ | បានឆ្លើយតប |
| CMDG ៩ ៖ ការបោសសម្អាតមីន | កំពុងដំណើរការអនុវត្ត |

ប្រភព ៖RGC (២០១៤a, p. ៤២) (*ចម្លងឡើងវិញ)*

ទីពីរ ទោះបីយ៉ាងណា ការសម្រេចបានគោលដៅ ៤ ៥ ៦ អាចបង្ហាញឱ្យឃើញដោយផ្ទាល់ និង មិនផ្ទាល់អំពីទស្សនៈសេដ្ឋកិច្ចនយោបាយ។ K. Un និង Hughes (២០១១) ដែលសិក្សាអំពីកំណែទម្រង់អភិបាលកិច្ចរបស់ទីភ្នាក់ងារផ្គត់ផ្គង់ទឹកភ្នំពេញ និងអាជ្ញាធរអេដស៍ ជាតិបានចង្អុលបង្ហាញថា វិស័យទាំងពីរនេះ បានទទួលជោគជ័យយ៉ាងខ្លាំង ពីព្រោះវិស័យទាំងពីរនេះជាវិស័យមានការអនុញ្ញាត ដោយក្នុងនោះទំនិញសាធារណៈ (សេវាទឹក និងសុខភាព) នឹងពង្រឹងនូវភាពស្របច្បាប់របស់ប្រទេស។ ភាពរីកចម្រើនដែលមិនប៉ះពាល់ផលប្រយោជន៍ដាច់ណាត់របស់ក្រុមអភិជនអាចជាការរីកចម្រើនដែលផ្តល់នូវផលប្រយោជន៍សម្រាប់ទាំងរដ្ឋ និងម្ចាស់ជំនួយ ដែលបាន និងកំពុងគាំទ្រវិស័យទាំងនេះផងដែរ។ កំណែទម្រង់ក្នុងវិស័យពីរផ្សេងទៀតដែលបានធ្វើការសិក្សា គឺរដ្ឋបាលព្រៃឈើ និងស្ថាប័នតុលាការ ដែលបានជួបនឹងការជំទាស់យ៉ាងធ្ងន់ធ្ងរ (ibid)។ វិស័យទាំងពីរនេះ នៅតែមានភាពទន់ខ្សោយខ្លាំង ទោះបីមានកិច្ចប្រឹងប្រែង និងការតាំងចិត្តពីម្ចាស់ជំនួយសំខាន់ៗជាច្រើនក៏ដោយ (ibid)។ ផ្ទុយវិស័យពីរខាងលើ ហេតុផលចម្បងគឺការលើកកម្ពស់ការគ្រប់គ្រងវិស័យដែលសម្បូរធនធាន និងថាមពលនឹងធ្វើឱ្យអំណាចក្រៅផ្លូវការរបស់ក្រុមអភិជន បណ្តាញ និងបក្ខពួកនៃក្រុមនេះមានភាពទន់ខ្សោយ (ibid)។

ទីបី ភាពលំបាកក្នុងការសម្រេចនូវគោលដៅទី៧ ស្តីពីនិរន្តរភាពបរិស្ថាន ក៏ឆ្លុះបញ្ចាំងនូវនិន្នាការក្នុងចំណុចទីពីរខាងលើផងដែរ។ ចំណូលបានមកពីការធ្វើអាជីវកម្មព្រៃឈើ បានបង្កើតជា

ប្រភពចំណូលមិនផ្លូវការមួយ ប៉ុន្តែជាប្រភពសំខាន់សម្រាប់តែក្រុមអភិជនដែលកាន់កាប់អំណាច និងបក្សពួករបស់ពួកគេ។ លើសពីនេះ រដ្ឋាភិបាលក៏ទទួលស្គាល់អំពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងការបំផ្លាញបរិស្ថាន។ ឧទាហរណ៍ រដ្ឋាភិបាលលើកឡើងថា វិលទៅកាន់ "ឆ្នាំ១៩៦០ ព្រៃឈើគ្របដណ្តប់ច្រើនជាង ៧០% ក្នុងប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ ១៩៩០ (បន្ទាប់ពីសង្គ្រាម) ព្រៃឈើគឺជាធនធានតែមួយប៉ុណ្ណោះនៃធនធានពិតប្រាកដមួយចំនួន ដែលកម្ពុជាកាន់កាប់គ្រប់គ្រងក្នុងវិស័យពាណិជ្ជកម្ម និងកសិកម្ម។ ជាលទ្ធផល ការកាប់បំផ្លាញព្រៃឈើបានចាប់ផ្តើម... ចន្លោះឆ្នាំ ១៩៩០ និងឆ្នាំ២០១០ រដ្ឋាភិបាលប៉ាន់ប្រមាណថា កម្ពុជាបានបាត់បង់គម្របព្រៃឈើ **២២%** ឬប្រហែលជា ២.៨៥០.០០០ ហិកតា (RGC, ២០១៤a, p. ៣១ បានបន្ថែមការផ្តោតចិត្តទុកដាក់ )។ អត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ដែលទើបចេញថ្មីបំផុតលើកឡើងថា កម្ពុជាបានបាត់បង់ព្រៃឈើ "លឿនជាងប្រទេសដទៃទៀតក្នុងពិភពលោក ចាប់តាំងពីឆ្នាំ២០០១" យោងតាម អង្គការឃ្លាំមើលព្រៃឈើពិភពលោក (GFW) គំនិតផ្តួចផ្តើមត្រួតពិនិត្យធនធានឈានមុខគេ (Harfenist, ២០១៥)។ អត្ថបទនេះពណ៌នាបន្ថែមទៀតថា កម្ពុជាបានបាត់បង់គម្របព្រៃឈើក្នុងកម្រិតខ្ពស់ក្នុងពិភពលោកសម្រាប់រយៈពេល១៤ឆ្នាំកន្លងទៅនេះ។ ការបាត់បង់នេះមានទំហំធំជាងការបាត់បង់ក្នុងប្រទេសប្រេស៊ីល និងឥណ្ឌូនេស៊ី ដែលកម្ពុជាបានបាត់បង់គម្របព្រៃឈើស្មើនឹងគុណនឹងបួនក្នុងឆ្នាំ ២០១៤ បើប្រៀបធៀបឆ្នាំ២០០១ (ibid)។ អត្ថបទនេះបញ្ជាក់ដោយសង្កត់ថា ការបាត់បង់គម្របព្រៃឈើកម្ពុជា មានភាពពាក់ព័ន្ធនឹងតម្លៃកៅស៊ូពិភពលោក (Ibid)។ ការអះអាងបែបនេះធ្វើឱ្យនឹកឃើញដល់ការអង្កេតតាមដានថា កំណើនសេដ្ឋកិច្ចកន្លងមកក៏មានភាពហិនហោចបរិស្ថានធ្ងន់ធ្ងរផងដែរ។

**រូបភាព ២ ៖ ការបាត់បង់ព្រៃឈើរបស់កម្ពុជាមានការពាក់ព័ន្ធនឹងតម្លៃកៅស៊ូពិភពលោក**




ប្រភព ៖ វិទ្យាស្ថានធនធានពិភពលោក (ដូចលើកឡើងក្នុង Harfenist, ២០១៥)

ទីបួន ការមិនអាចសម្រេចបានគោលដៅ ២ និងគោលដៅ ៣ អាចពាក់ព័ន្ធនឹងលទ្ធភាពវិនិយោគ ជាពិសេស ក្នុងវិស័យអប់រំក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ និងការខ្វះការប្តេជ្ញាចិត្តចំពោះវិស័យនេះ (RGC, ២០១៤a)។ ឧទាហរណ៍ ការវាយតម្លៃរបស់រដ្ឋាភិបាលលើ CMDGs បង្ហាញអំពីការខ្វះខាតសាលាបឋមសិក្សាសម្រាប់ចំនួនសិស្សដែលកាន់តែកើនឡើង ដែលជាហេតុផលមួយសម្រាប់លទ្ធផលសិក្សា និងអត្រាបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន (RGC, ២០១៤a)។

ទីប្រាំ នៅក្នុង CMDGs ទាំងអស់ ការចូលរួមចំណែកពី (១) NGOs និងដៃគូអភិវឌ្ឍន៍កំពុងតែមាន (CCC, ២០១៣)។ ទោះបីយ៉ាងណា ផ្នែកនេះបង្ហាញករណីថា ដូចបានបង្ហាញក្នុងចំណុច២ខាងលើ សម្រាប់ MDGs មួយចំនួនដូចជា សុខភាព ផលប្រយោជន៍ និងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងអ្នកអភិវឌ្ឍន៍ទាំងអស់ ត្រូវបានប្រមូលផ្តុំគ្នា ដូច្នេះ វាកាន់តែងាយស្រួលក្នុងការសម្រេចនូវ MDG។ ទោះបីយ៉ាងណា ពាក់ព័ន្ធនឹងនយោបាយ ជាញឹកញាប់ ការអនុវត្តនៅមិនទាន់បានគ្រប់គ្រាន់ ដោយសារតែផលប្រយោជន៍របស់រដ្ឋាភិបាល (និងក្រុមអភិជននៃរដ្ឋាភិបាល) ដៃគូអភិវឌ្ឍន៍ និង NGOs មានភាពខុសគ្នា ដែលធ្វើឱ្យមានផលវិបាកសម្រាប់ SDGs ផងដែរ។

## *SDGs និង កម្ពុជា*

ក្នុងពេលដែល SDGs មិនទាន់បានអនុវត្តក្នុងបរិបទកម្ពុជា លទ្ធផលនៃការអនុវត្តប្រហែលជាមាននិន្នាការដូចគ្នានឹង CMDGs ដូចបានវិភាគខាងលើ។ គោលដៅដែលកំពុងដំណើរការ ដូចជាភាពក្រីក្រ កំណើន ការកាត់បន្ថយភាពអត់ឃ្លានអាចសម្រេចបានលឿនជាង (ឧទាហរណ៍) ការអភិរក្សបរិស្ថាន និងកំណែទម្រង់ស្ថាប័ន ដូចជា នីតិរដ្ឋ។ ខាងក្រោមគឺជាបញ្ហាប្រឈមដែលអាចមានលើកឡើងក្នុងរបៀបវារៈអន្តរជាតិនៃ SDGs ស្តីពីកម្ពុជា និងតើសេដ្ឋកិច្ចនយោបាយកម្ពុជាមានបញ្ហាប្រឈមដូចម្តេចចំពោះកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការសម្រេចនូវ SDGs។ ឱកាស នឹងត្រូវលើកយកមកពិភាក្សាផងដែរ។

## SDGs ៖ បញ្ហាប្រឈម និងឱកាស[4] សម្រាប់កម្ពុជា

ផ្នែកនេះ នឹងពន្យល់អំពីបញ្ហាប្រឈម និងឱកាសដែលលើកឡើងក្នុង SDGs ស្តីពីកម្ពុជា និងតើកម្ពុជាមានបញ្ហាប្រឈម និងឱកាសដូចម្តេចខ្លះក្នុងការសម្រេចនូវ SDGs។ បញ្ហាប្រឈម និងឱកាស ជាទូទៅ ត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍របស់កម្ពុជា សម្រាប់ការអនុវត្តកន្លងមក និងទស្សនវិជ្ជានៅពីក្រោយបញ្ហាប្រឈម និងឱកាសទាំងនេះ។ ការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NDSP) របស់កម្ពុជា ដែលធ្វើបច្ចុប្បន្នភាព ឆ្នាំ ២០១៤-២០១៨ បង្ហាញថា កម្ពុជាបានអនុវត្តគ្រប់សមាសធាតុអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលលោក Sachs រំលឹកថា កំណើន (ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ) ការផ្តោតលើបរិស្ថាន កំណើនគ្រប់ជ្រុងជ្រោយ និងអភិបាលកិច្ចល្អគឺជាផ្នែកសំខាន់នៃឯកសារទាំងនេះ[5]។ SDGS និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានធាតុផ្សំរួមគ្នា គឺចំណុចល្អទាំងអស់ត្រូវដើរទន្ទឹមគ្នា។ ហេតុដូច្នេះ វាមិនមានភាពតានតឹងធ្ងន់ធ្ងររវាងឯកសារទាំងនេះឡើយ។ ទោះបីយ៉ាងណា ដោយសារតែការវិភាគលទ្ធផល CMDGs ខាងលើមិនទាន់ផ្សព្វផ្សាយ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង CMGDs ដែលជាផ្នែកនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បង្ហាញពីការអង្កេតតាមដានផ្ទុយគ្នាមួយចំនួន ដែលត្រូវធ្វើការអង្កេតម្តងទៀត នៅពេល SDGs ត្រូវបានអនុវត្តក្នុងប្រទេស។ ក្រៅពីភាពតានតឹង និងបញ្ហាប្រឈមទាំងនេះ ឱកាសក៏មានច្រើនផងដែរ។

បញ្ហាប្រឈមទីមួយ ដែលជាបញ្ហាប្រឈមផ្ទៃក្នុង គឺកម្ពុជាមិនទាន់បានសម្រេចនូវកំណើនបៃតងឡើយ (Green Growth)។ ការរក្សាកំណើនខ្ពស់ជាបន្តបន្ទាប់ គឺពាក់ព័ន្ធយ៉ាងច្បាស់ជាមួយនឹងការបាត់បង់នូវការលះបង់ដ៏សំខាន់នៃបរិស្ថាន អ្នកនិពន្ធនាំមុខគេ Sarah Miller ស្តីពី *ការអភិរក្ស និងការអភិវឌ្ឍនៅកម្ពុជា ៖ ការស្វែងយល់អំពីព្រំដែននៃការផ្លាស់ប្តូរក្នុងធម្មជាតិ រដ្ឋ និងសង្គម*" អះអាងថា កំណើនផលទុនជាតិសរុបខ្ពស់របស់កម្ពុជា កើនឡើងដោយរួមមកជាមួយនឹង" ...តម្លៃបរិស្ថានសង្គម...។ ឧទាហរណ៍ ការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា ត្រូវបានកំណត់ថា មានអត្រាខ្ពស់បំផុតក្នុងពិភពលោក និងបង្កឱ្យមានបញ្ហាបរិស្ថានដែលមានការគំរាមកំហែងខ្លាំងក្នុងការធ្វើឱ្យភាពក្រីក្រ

---

4 យើងផ្តល់តម្លៃចំពោះមតិយោបល់របស់អ្នកចូលរួមមួយចំនួន ក្នុងសិក្ខាសាលាពិគ្រោះយោបល់របស់យើង ដែលស្នើឡើងថា ចំណុចខ្សោយ និងការគំរាមកំហែងអាចត្រូវយកមកពិចារណាផងដែរ។ ទោះបីយ៉ាងណា អ្នកចូលរួមម្នាក់ទៀតបានអះអាងថា SDGs កំពុងទាញកម្ពុជាឱ្យដើរក្នុងទិសដៅវិជ្ជមានស្របជាមួយផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ហេតុដូច្នេះ មិនមែនជាចំណុចខ្សោយ និងការគំរាមកំហែងទៀតទេ ប៉ុន្តែ ជាបញ្ហាប្រឈម ដែលជាលក្ខខណ្ឌផលិតភាពបន្ថែមទៀត រួមបញ្ចូលទាំងគំនិតនៃការគំរាមកំហែង និងចំណុចខ្សោយមួយចំនួនផងដែរ។

5 ទោះបីយ៉ាងណា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មិនផ្តល់នូវសេចក្តីលម្អិត ជាពិសេស សេចក្តីលម្អិតនៃសូចនាករ ដូច SDGs ឡើយ។

កាន់តែធ្ងន់ធ្ងរ និងបំផ្លាញស្ថេរភាពនយោបាយ ដូចជា ការបំពុល ការប្រែប្រួលអាកាសធាតុ ភាពរិចរឹលដី និងការធ្លាក់ចុះបរិមាណត្រី" (Phy, ២០១៥)។ អ្នកវាយការណ៍ម្នាក់ក្នុងចំណោមអ្នកវាយការណ៍ដែលបម្រើការងារឱ្យស្ថាប័នអង្គការសហប្រជាជាតិ ដែលធ្វើការជិតស្និទ្ធជាមួយរដ្ឋាភិបាលលើបញ្ហាអភិវឌ្ឍន៍ ដូចជា CMDGs និង SDGs ពិពណ៌នាថា បច្ចុប្បន្ន រដ្ឋាភិបាលកំពុងទទួលស្គាល់អំពីការបំផ្លាញបរិស្ថានក្នុងទ្រង់ទ្រាយធំ និងកំពុងបង្ហាញក្ដីកង្វល់ធ្ងន់ធ្ងរអំពីផលប៉ះពាល់របស់វា[6]។ ការពិភាក្សាលើកមុនបានលើកឡើងរួចហើយថា គ្រាន់តែមួយទស្សវត្សរ៍ក្នុងអំឡុងឆ្នាំ១៩៩០ កម្ពុជាបានបាត់បង់ព្រៃចំនួន ២២% (RGC, ២០១៤a)។

បញ្ហាប្រឈមទីពីរ ដែលជាបញ្ហាផ្ទៃក្នុងសម្រាប់កម្ពុជា គឺមានការជំរុញយ៉ាងខ្លាំងពីអ្នកផ្ដល់ហិរញ្ញប្បទានខាងក្រៅ ឬអ្នកអភិវឌ្ឍន៍ធ្វើការពង្រឹងឱ្យបានឆាប់រហ័សនូវអភិបាលកិច្ច ជាពិសេសនីតិរដ្ឋ នៅពេលដែលមិនទាន់មានការរៀបចំ។ កត្តាសំខាន់គឺសារៈសំខាន់នៃការជំរុញប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជា ដែលឆ្លងកាត់នូវរបបប្រល័យពូជសាសន៍ និងសង្គ្រាមជាច្រើនទសវត្សរ៍ ឱ្យអនុម័តនូវរបៀបវារៈអភិបាលកិច្ចល្អ ដូចជា នីតិរដ្ឋ ឱ្យបានឆាប់រហ័ស និងហ្មត់ចត់ដោយ ប្រថុយប្រថាន។ ពិប្រាកដណាស់ ការផ្លាស់ប្ដូរពីបរិបទនៃប្រព័ន្ធគ្រប់គ្រងតាមបែបដូនតា (neo-patrimonial context) ទៅជាប្រព័ន្ធគ្រប់គ្រងទំនើប គឺជាដំណើរការឈឺចាប់មួយ ហើយការផ្លាស់ប្ដូរណាមួយក្នុងដំណើរការនេះ ដែលមានភាពលឿនពេក អាចនឹងធ្វើឱ្យប៉ះពាល់ដល់សន្តិភាព និងស្ថេរភាពដែលពិបាកស្វែងរក។ Fukuyama (២០១៤) ពន្យល់ថា រដ្ឋប្រជាធិបតេយ្យ ទំនើប និងមិនពុករលួយ មានន័យថា មានបន្ទាត់បែងចែកយ៉ាងច្បាស់លាស់រវាងវិស័យសាធារណៈ និងឯកជន។ ទោះបីយ៉ាងណាក្នុងប្រទេសអន្តរកាលជាច្រើន បន្ទាត់បែងចែកនេះ មានការខូចខាតយ៉ាងខ្លាំង។ នេះគឺជាគម្លាតដ៏ធំរវាងប្រទេសមានប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្នតាមបែបដូនតា (neo-patrimonial context)[7] និងប្រទេសទំនើប (ibid)។ ហេតុដូច្នេះ នៅពេលមានកម្មវិធីពីខាងក្រៅ ដូចជា នីតិរដ្ឋ និងការបង្កើតស្ថាប័នច្បាប់ត្រូវបានរៀបចំ និងអនុវត្ត ដើម្បីបង្កើតស្ថាប័នក្នុងគោលដៅជំរុញប្រទេស *នៅពេលប្រទេសមិនទាន់ត្រៀមរួចរាល់* វានឹងមានបញ្ហា និងមិនអាចអនុវត្ត ដើម្បីសម្រេចបានឡើយ (Ibid)។ Fukuyama

---

[6]វិស័យអភិវឌ្ឍន៍ បទសម្ភាសន៍ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ភ្នំពេញ។

[7] ប្រព័ន្ធគ្រប់គ្រងតាមបែបដូនតា (Neo-patrimonialism) សំដៅលើប្រព័ន្ធនយោបាយដែល "ថ្នាក់ដឹកនាំជាអ្នករក្សាអំណាច តាមរយៈការការពារដោយខ្លួនឯង ជាជាងតាមរយៈមនោគមន៍វិជ្ជា ឬច្បាប់ ... ទំនាក់ទំនងនៃភាពស្មោះត្រង់ និងការពឹងផ្អែក បង្កើតបានជានយោបាយផ្លូវការមួយ និងប្រព័ន្ធរដ្ឋបាល ... អ្នកដឹកនាំគ្រប់គ្រងការិយាល័យធិបតេយ្យដើម្បីអនុវត្តសេវាសាធារណៈ តិចជាងការទទួលនូវទ្រព្យសម្បត្តិ និងមុខតំណែងផ្ទាល់ខ្លួន។ ភាពខុសគ្នារវាងផលប្រយោជន៍ឯកជន និងសាធារណៈ គឺមិនមានភាពច្បាស់លាស់ឡើយ ... ដើម្បីទទួលបានរង្វាន់ជាសម្ភារ គេត្រូវកៀគរការគាំទ្រនយោបាយ និងបញ្ជូនសេចក្ដីសម្រេចចិត្តទៅថ្នាក់លើ ដើម្បីបង្ហាញអំពីការគោរពចំពោះក្រុមគាំទ្រសង្គម។" (Bratton និង van de Walle ១៩៩៤ ដូចបានលើកឡើងក្នុង Pak, ឆ្នាំ២០១១)។

លើកឡើងថា អ្នកអន្តរាគមពីខាងក្រៅ មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់អំពីការផ្លាស់ប្តូរដែលមានភាពឈឺចាប់ ភាពលំបាក និងមានលក្ខណៈស្រដៀងគ្នា ដែលសូម្បីតែសហរដ្ឋអាមេរិកទើបតែនឹងបានឆ្លងកាត់នៅដើមសតវត្សរ៍ទី១៩ ប៉ុណ្ណោះ (ibid)[8]។ កន្លងមក មានការអប់រំអំពីចំណុចវិជ្ជមាននៃអំពើពុករលួយក្នុងការរក្សាជាបណ្តោះអាសន្ននូវសន្តិភាព និងស្ថេរភាពក្នុងផ្នែកខុសៗគ្នាក្នុងពិភពលោក រួមទាំង កម្ពុជា (Biddulph, ២០១៤; ២០១៤)។ សន្ទស្សន៍នីតិរដ្ឋឆ្នាំ២០១៥ នៃគម្រោងយុត្តិធម៌ពិភពលោក អាចត្រូវបានបកស្រាយ ដើម្បីគាំទ្រការលើកឡើងខាងលើ។ ផ្អែកលើសន្ទស្សន៍នីតិរដ្ឋនេះ នីតិរដ្ឋនៃកម្ពុជាឈរលំដាប់ទាបបំផុតគឺលំដាប់ទី៩៩ ក្នុងចំណោម លំដាប់ទាំង១០២ (Ponce, ២០១៥)។ ទោះបីយ៉ាងណា ពិន្ទុកម្ពុជាខាងលើ ជាពិន្ទុដែលស្ថិតលើពួកអាស៊ីខាងកើត និងប៉ាស៊ីហ្វិក សម្រាប់សណ្តាប់ធ្នាប់ និងសន្តិសុខ ដែលជាការលើកទឹកចិត្តមួយសម្រាប់ប្រទេសដែលធ្លាប់ឆ្លងកាត់របបប្រល័យពូជសាសន៍ និងសង្គ្រាមស៊ីវិលជាច្រើនសតវត្សរ៍ (Ibid:៧២)។ ប្រសិនបើរដ្ឋគ្មានសមត្ថភាពក្នុងរក្សានូវស្ថេរភាព និងសណ្តាប់ធ្នាប់ដូចមានក្នុងពេលបច្ចុប្បន្ននេះទេ កម្ពុជានឹងមិនអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងកាត់បន្ថយភាពក្រីក្របានប្រសើរ និងសម្រេចនូវគោលដៅ CMGDs ដទៃទៀតឡើយ។ ជាថ្មីម្តងទៀត ដូច Fukuyama បានរំលឹកខាងលើ ការពង្រឹងនីតិរដ្ឋដោយចំណាយខ្ពស់ គឺមិនត្រូវបានណែនាំឡើយ។ ហេតុដូច្នេះ ចាំបាច់ត្រូវមានការយល់ដឹងអំពីប្រតិបត្តិករអន្តរជាតិទាក់ទងនឹងអ្វីដែលអាចធ្វើបាន និងអ្វីដែលមិនអាចធ្វើបានក្នុងរយៈពេលមធ្យម និងរយៈពេលវែង សម្រាប់បរិបទប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជា។ ទោះបីយ៉ាងណា SDGs កំពុងដាក់ចេញនូវវិធានលើប្រទេសកំពុងអភិវឌ្ឍន៍ ដូច្នេះ គេរំពឹងថា ការគាំទ្រពីខាងក្រៅនឹងមិនដាក់សម្ពាធសម្រាប់កំណែទម្រង់ស្ថាប័នដែលមិនអាចអនុវត្តបានឡើយ។

---

[8] យោងតាម Fukuyama (២០១៤) នៅសហរដ្ឋអាមេរិក ប្រព័ន្ធក្រុមគាំទ្រសង្គម ឬ ប្រព័ន្ធមិនល្អ នៅតែត្រូវបានអនុវត្តនៅដើមសតវត្សរ៍ទី១៩។ ឧទាហរណ៍ ក្នុងការបោះឆ្នោតឆ្នាំ១៨៧៨ លោក John Quincy Adams ប្រធានាធិបតីអាមេរិកទី៦ បានឈ្នះការបោះឆ្នោត ដោយប្រើប្រាស់នយោបាយក្រុមអ្នកគាំទ្រសង្គម។ ការទាក់ទាញប្រជាជនឱ្យមកបោះឆ្នោត និងបោះឆ្នោតជូនគណបក្សមួយក្នុងប្រទេសមួយ (ដូចជា សហរដ្ឋអាមេរិកក្នុងពេលនោះ) នៅពេលប្រជាជនមានការអប់រំតិចតួច និងមានចំណូលដែលមិនមែនសម្រាប់ប្រើក្នុងនយោបាយសាធារណៈ ដូចជា ការកាត់បន្ថយពន្ធ ឬ ការផ្តល់ការថែទាំសុខភាពសាធារណៈដោយឥតគិតថ្លៃ (ដូចបានអនុវត្តក្នុងពេលបច្ចុប្បន្ននេះ)។ វាគឺជាការសូកប៉ាន់ដល់អ្នកបោះឆ្នោតម្នាក់ៗ ដោយការផ្តល់ការងារដល់អ្នកគាំទ្រសំខាន់ៗ (ក្នុងការិយាល័យប្រៃសណីយ៍ ក្នុងកងកម្លាំងប៉ូលីស...)។ នៅពេល John Quincy ឈ្នះការបោះឆ្នោត គាត់បានជ្រើសរើសភ្នាក់ងារសំខាន់ៗ ដែលគាំទ្ររូបលោកឱ្យកាន់តំណែងសាធារណៈ។ នយោបាយបែបនេះ ត្រូវបានអនុវត្តជាទូទៅអស់រយៈពេលប្រហែលជា ១០០ឆ្នាំ មកហើយ ក្នុងប្រជាធិបតេយ្យអាមេរិកដែលក្នុងនោះមន្ត្រីតាំងពីថ្នាក់លើដល់ថ្នាក់ក្រោម ត្រូវបានតែងតាំងដោយអ្នកនយោបាយសម្រាប់ជាសំណូកក្នុងការគាំទ្រនយោបាយក្នុងអំឡុងពេលបោះឆ្នោត។ នៅពេលដែលសភាបានរកឃើញថា ប្រព័ន្ធក្រុមគាំទ្រសង្គម ឬប្រព័ន្ធមិនល្អ ផ្តល់ភាពអាម៉ាស សភាបានបោះបង់ចោលនូវប្រព័ន្ធនេះ ហើយប្រព័ន្ធសនិទាន ភាពត្រូវបានយកមកអនុវត្តជំនួសវិញ។

បញ្ហាប្រឈមខាងក្រៅទីបី គឺដូចគ្នានឹង MDGs ដែរ SDGs មានដំណើរការផ្ដែកលើគោលដៅ និងចំណុចដៅលម្អិត ដែលមានភាពលំបាកសម្រាប់ប្រទេសមួយ ដូចជា កម្ពុជា ដែលជាទូទៅ មានសមត្ថភាពខ្សោយក្នុងការអនុវត្តតាម។ គោលដៅ និងចំណុចដៅមានន័យថាជាបន្ទាត់មូលដ្ឋាន និងលទ្ធផលរំពឹងទុក ដែលចាំបាច់ត្រូវកំណត់បរិមាណ ដូច្នេះ ការដែលកម្ពុជាអាចប្រឈមនឹងបញ្ហាដ៏លំបាកបានយ៉ាងណា មិនអាចវាយតម្លៃពីសំបកក្រៅបានឡើយ ជាពិសេស ក្នុងបរិបទដែលការសម្របសម្រួលរវាងក្រសួងជាច្រើនត្រូវបានធ្វើឡើងជាផ្នែកៗ។ បុគ្គលិកម្នាក់មកពីវិស័យអភិវឌ្ឍន៍ និងម្នាក់មកពីវិស័យឯកជន ដែលបានផ្ដល់បទសម្ភាសចែករំលែកអំពីក្ដីកង្វល់ផងដែរ[៩]។

បញ្ហាប្រឈមទីបួន ដែលជាការបញ្ចូលគ្នារវាងបញ្ហាពីខាងក្រៅ និងផ្ទៃក្នុង គឺគោលដៅ និងទស្សនវិស័យនៃ SDGs និងគោលដៅ និងទស្សនវិស័យរបស់កម្ពុជា មានភាពខុសគ្នា ជាពិសេសការអនុវត្ត ដែលចំណុចនេះមានភាពពាក់ព័ន្ធខ្លាំងនឹងបញ្ហាប្រឈមទីពីរ។ SDGs អនុវត្តតាមគំនិតដែលអ្វីៗល្អទាំងអស់អាចដើរទន្ទឹមគ្នា។ ទោះបីយ៉ាងណា សម្រាប់រដ្ឋាភិបាលកម្ពុជា មានទស្សនថា "ចាំបាច់ត្រូវមានដុំបាយ មុននឹងសិទ្ធិត្រូវបានគោរព"។ ដូចបានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កំណើន (និងការកាត់បន្ថយភាពក្រីក្រ) និងអភិបាលកិច្ចល្អទាំងអស់នេះត្រូវបានរៀបចំឡើង ដើម្បីឱ្យបានទន្ទឹមគ្នា។ ទោះបីយ៉ាងណា ប្រហែលជាក្នុងពេលអនុវត្តជាក់ស្ដែង កំណើនត្រូវបានកំណត់ជាអាទិភាព ប៉ុន្តែអភិបាលកិច្ចល្អមិនត្រូវបានកំណត់ជាអាទិភាពឡើយ។ បទសម្ភាសរបស់យើងជាមួយអ្នករាយការណ៍ម្នាក់ ដែលជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយរូប ក៏អះអាងអំពីអាទិភាពលាក់កំបាំងផងដែរ[10]។ ការរៀបរាប់របស់ Slocomb (២០១០) រំលឹកថា គម្រោងអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ (UNDP) ត្រូវបានអញ្ជើញឱ្យជួយអាជ្ញាធរកម្ពុជាក្នុងការរៀបចំកម្មវិធីកំណែទម្រង់ជាតិ និងការអនុវត្ត។ គោលដៅគឺការកសាងស្ថាប័ន និងយុទ្ធសាស្ត្រ រួមទាំង ក្របខ័ណ្ឌច្បាប់សម្រាប់រៀបចំរចនាសម្ព័ន្ធរដ្ឋបាលសាធារណៈឡើងវិញ ពង្រឹងការគ្រប់គ្រងក្រសួងសាមី និងកែទម្រង់ការគ្រប់គ្រងសេវាសង្គម លើកកម្ពស់សមត្ថភាព និងពង្រឹងរដ្ឋបាលខេត្ត។ រដ្ឋាភិបាល បានចុះហត្ថលេខាកម្មវិធីកែសម្រួលជារចនាសម្ព័ន្ធរបស់មូលនិធិរូបិយប័ណ្ណអន្តរជាតិ (IMF) ដែលប្ដេជ្ញាកាត់បន្ថយចំនួនមន្ត្រីរាជការ ២០% ត្រឹមឆ្នាំ១៩៩៧។ ការជំទាស់ប្រឆាំង និងវិទ្ធស្សនា គឺជាឧបសគ្គចម្បងក្នុងកិច្ចប្រឹងប្រែងកំណែទម្រង់។ លទ្ធផលគឺខកបំណង កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិបានចូលរួមវិភាគទានចំនួន ៣,៥ លានដុល្លារ ប៉ុន្តែទឹកប្រាក់ទាំងនោះត្រូវបានបាត់។ ទោះបីយ៉ាងណា លទ្ធផលភ្លាមៗមួយដែលកម្ពុជាជំទាស់នឹងលក្ខខណ្ឌរបស់ម្ចាស់ជំនួយ គឺកម្ពុជាអាចរក្សានូវសន្តិភាព និងស្ថេរភាពដែលលំបាកក្នុងការរក្សាបាន

[៩]វិស័យអភិវឌ្ឍន៍ បទសម្ភាសថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ភ្នំពេញ។ បុគ្គលិកវិស័យឯកជនម្នាក់ បទសម្ភាសថ្ងៃទី១៩ ខែសីហា ភ្នំពេញ។

[10]មន្ត្រីរដ្ឋាភិបាល បទសម្ភាសថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ ភ្នំពេញ។

សម្រាប់ប្រទេសដែលធ្លាប់ឆ្លងកាត់របបប្រល័យពូជសាសន៍ និងមានសង្គ្រាមស៊ីវិលជាបន្តបន្ទាប់អស់រយៈពេលជិតពីរទសវត្សរ៍ (ចាប់ពីឆ្នាំ១៩៧៩ ដល់ ១៩៩៨ នៅពេលខ្មែរក្រហមដួលរលំ)។ លោកស្រី Caroline Hughes (២០០៩) ក្នុងការសិក្សាប្រៀបធៀប រវាងអន្តរាគមន៍របស់សហគមន៍អន្តរជាតិក្នុងការកសាងសន្តិភាពនៅកម្ពុជា និងទីម័រខាងកើតបានរកឃើញថា ក្រុមអភិជនក្នុងស្រុកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់លទ្ធផលនៃសន្តិភាពក្នុងប្រទេសទាំងពីរ។ កម្ពុជា ដូចជាអនុវត្តបានល្អច្រើនជាង ទីម័រខាងកើត ពីព្រោះក្រុមអភិជនជាតិកំពុងតែអនុវត្តលើសពីរបៀបវារៈអន្តរជាតិទៅកាន់កម្រិតខ្ពស់ជាង (ដែលពួកគេត្រូវបានរិះគន់យ៉ាងខ្លាំង) ហើយដូច្នេះ ក៏មានដំណើរការសន្តិភាពផ្ទាល់ខ្លួនជាបន្តបន្ទាប់ល្អជាងសមភាគីទីម័រ។ ផ្ទុយទៅវិញ ក្រុមអភិជនទីម័រខាងកើត មានបំណងក្លាយជាអ្នកអនុវត្តល្អបំផុត "ក្រោមរបបសន្តិភាពសេរី ផ្អែកតាមលក្ខខណ្ឌរបស់ម្ចាស់ជំនួយ"។ ហេតុដូច្នេះ ក៏ទទួលបានលទ្ធផលសន្តិភាពទន់ខ្សោយជាង (Hughes ២០០៩)។ ជារួម បញ្ហានៅទីនេះ គឺរបៀបវារៈរបស់ SDGs និង កម្ពុជា មានភាពខុសគ្នា។ សហគមន៍អន្តរជាតិអនុវត្ត SDGs ដោយសន្មតថា ពួកគេដឹងអំពីអ្វីដែលមានដំណើរការល្អសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងដាក់ចេញនូវគំរូអភិវឌ្ឍន៍របស់ពួកគេ ខណៈកម្ពុជាអនុវត្តជាយូរហើយនូវវិធីសាស្ត្រជាក់ស្តែង ដែលអាចប្រើការបាន។ ផលវិបាកកើតមានពីចំណុចនេះ គឺប្រសិនបើកម្ពុជាជំទាស់នឹងរបៀបវារៈនៃ SDGs និងប្រសិនបើមានការជំទាស់នេះមែន កម្ពុជានឹងមិនទទួលបានការគាំទ្រហិរញ្ញវត្ថុ ដូចការរំពឹងទុកពីសហគមន៍អន្តរជាតិឡើយ។ ផ្ទុយទៅវិញ ប្រសិនបើកម្ពុជាបានអនុវត្តល្អប្រសើរ កម្ពុជាទំនងនឹងទទួលបានជំនួយកាន់តែច្រើន។ ទោះបីយ៉ាងណា វានឹងធ្វើឱ្យមានការប៉ះពាល់ដល់ស្ថេរភាពប្រទេស។

បញ្ហាប្រឈមផ្ទៃក្នុងទីប្រាំ គឺការពង្រឹងការបញ្ចូលគ្នា សុខុមាលភាព និងផលិតភាពនៃការរស់នៅជាក្រុមជុំវិញបន្ទាត់ក្រីក្រ ទាមទារនូវការវិនិយោគបន្ថែមក្នុងវិស័យសុខាភិបាល ការអប់រំ និងការការពារសង្គម។ នៅរង់ចាំមើលថា តើដល់ពេលណាកម្ពុជា ដៃគូអភិវឌ្ឍន៍ និងNGOs អាចជួយក្នុងដំណើរការនេះបាន។ នៅពេលភាពក្រីក្រកំពុងធ្លាក់ចុះ និងវិសមភាពត្រូវបានកាត់បន្ថយ (CDRI, ២០១៣; Hill & Menon, ២០១៣) ប្រហែលជាប្រជាជនបីភាគបួននៅតែស្ថិតក្នុងក្រុម "ក្រ" ឬ "ជិតក្រ" ក្រោម ឬ ពីលើខ្សែបន្ទាត់ក្រីក្រ (Hill & Menon, ២០១៣; WB, ២០១៥)។ លើសពីនេះ កង្វះអាហារូបត្ថម្ភកុមារនៅតែមានកម្រិតខ្ពស់ ហើយជាលទ្ធផល ធ្វើឱ្យមានភាពក្រីក្រ ជាពិសេស រីករាលដាលកាន់តែធំ។ វិសមភាពនៃអន្តរខេត្ត/ក្នុងខេត្ត កើតមានជាទូទៅផងដែរ (Hill & Menon, ២០១៣; RGC, ២០១៤a)។ "ភាពក្រីក្រថ្មី" គឺជាក្តីកង្វល់មួយទៀត។ ឧទាហរណ៍ (១) NGOs បានចងក្រងជាឯកសារថា ក្នុងបណ្តាខេត្តដែលសម្បូរធនធានធម្មជាតិក្នុងប្រទេស ភាពក្រីក្រថ្មីបានកើតឡើងក្នុងខេត្តទាំងនេះ ដែលចំនួនប្រជាជន (ដែលមិនមែនជាអ្នកក្រីក្រពីមុន) បានក្លាយជាអ្នកក្រីក្រ ពីព្រោះ

ធនធានធម្មជាតិរបស់ពួកគេត្រូវបានអ្នកអភិវឌ្ឍន៍/ក្រុមហ៊ុនអភិវឌ្ឍន៍ពីខាងក្រៅដណ្តើម ឬលួច[11]។ ក្តីកង្វល់ពាក់ព័ន្ធមួយគឺដោយសារកំណើនកម្ពុជា នៅតូចចង្អៀត ហេតុដូច្នេះ ធ្វើឱ្យទីផ្សារតំបន់ និងពិភពលោកមានការផ្លាស់ប្តូរញឹកញាប់ (Hill & Menon, ២០១៣) ការធ្លាក់ចុះសេដ្ឋកិច្ចដែលបានកើតឡើងក្នុងឆ្នាំ២០០៨/២០០៩ អាចធ្វើឱ្យកំណើនមានភាពយឺតយ៉ាវ និងធ្វើឱ្យមានហានិភ័យចំពោះក្រុមប្រជាជនមួយចំនួនធំដែលរួចផុតពីខ្សែបន្ទាត់ក្រីក្រ អាចធ្លាក់ចុះក្រោមបន្ទាត់ក្រីក្រវិញ។

បញ្ហាប្រឈមទីប្រាំមួយ ការបញ្ចូលគ្នារវាងបញ្ហាក្នុងស្រុក និងពីខាងក្រៅ គឺការសម្របសម្រួលចែកជាផ្នែក ក្នុងចំណោមរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ (រួមទាំង ទីភ្នាក់ងារចម្រុះភាគី និងទ្វេរភាគី) និងNGOs។ ការប្រមើមើល ក្នុងរបៀបវារៈប្រសិទ្ធភាពជំនួយ និងការអភិវឌ្ឍ អ្នកអភិវឌ្ឍន៍ទាំងអស់ ត្រូវសហប្រតិបត្តិការ ដើម្បីឱ្យដំណើរការអភិវឌ្ឍន៍អាចមានភាពរលូន។ ទោះបីយ៉ាងណា ទំនាក់ទំនងទាំងនេះបានកើតឡើងដោយខុសគន្លងក្នុងផ្នែកសំខាន់មួយចំនួន។ ទីមួយ នៅពេលម្ចាស់ជំនួយមានស្រាប់កន្លងមក និងរដ្ឋាភិបាលនៅមិនទាន់សហការគ្នាបានល្អក្នុងការសម្របសម្រួលជាមួយគ្នា[12] ម្ចាស់ជំនួយថ្មីនាំមកនូវបញ្ហាមួយផ្សេងទៀត ដែលពួកគេមិនអាចដាក់បញ្ចូលក្នុងយន្តការសម្របសម្រួលឡើយ។ និន្នាការថ្មីនៅកម្ពុជា គឺម្ចាស់ជំនួយថ្មីមានការកើនឡើងច្រើនដែលមានសារៈសំខាន់ក្នុងការផ្តល់ការគាំទ្រជាច្រើន ពីពេលមួយទៅពេលមួយទៀត។ ម្ចាស់ជំនួយថ្មីទាំងនេះគឺជាប្រទេសដែលមានសេដ្ឋកិច្ចថ្មីក្នុងប៉ែកខាងត្បូង ដូចជា ចិន កូរ៉េខាងត្បូង ឥណ្ឌា និងថៃ (Sato, Shiga, Kobayashi, & Kondoh, ២០១១)។ រហូតមកពេលនេះ ប្រទេសទាំងនេះមិនទាន់ក្លាយជាផ្នែកនៃយន្តការសម្របសម្រួលជំនួយឡើយ។ ម្ចាស់ជំនួយថ្មីត្រូវបានទុកចោលមួយឡែក ទោះបីជាមានជំនួយជាច្រើនតាមមូលដ្ឋានទិន្នន័យ ជំនួយសម្រាប់អភិវឌ្ឍន៍ តាមប្រព័ន្ធអ៊ីនធើណែត របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ និន្នាការនេះបំផ្លាញការសហការគ្នាក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សម្រាប់កម្ពុជា។ ទីពីរ ទំនាក់ទំនងរវាងរដ្ឋាភិបាល និងNGOs មិនសូវរលូនល្អនៅឡើយ។ ក្នុងនាមជាតំណាងនៃចលនាសង្គមស៊ីវិលនៅកម្ពុជា NGOs ដើរតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មានសម្រាប់ផែនការអភិវឌ្ឍន៍ផងដែរ។ ទោះបីយ៉ាងណា NGOs ក៏នៅមានផ្លូវផ្សេងទៀត។ ជាក់ស្តែង មានឧទាហរណ៍ពីរបង្ហាញអំពីនិន្នាការនេះ ទីមួយ ជំហររបស់រដ្ឋាភិបាលក្នុងការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បង្ហាញអំពីគោលបំណងជាក់លាក់ក្នុងការដាក់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលស្ថិតក្រោមការគ្រប់គ្រង។ ទីពីរ ការចូលរួមចំណែករបស់ NGOs ទៅក្នុងក្រុមការងារបច្ចេកទេស (TWGs) គឺមានកម្រិត។ រហូតមកដល់ឆ្នាំ២០០៩ ដូចបានចែងក្នុងគោលការណ៍ណែនាំ TWG តួនាទីរបស់ NGO ត្រូវបានរឹតបន្តឹងសម្រាប់តួនាទីជាអ្នកសង្កេត ហើយមិនមានការផ្លាស់ប្តូរ រហូតធនាគារពិភពលោកផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាល។ បន្ទាប់ពី

[11] ការស្រាវជ្រាវ ០១ បទសម្ភាសតាមប្រព័ន្ធ skype ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។

[12]បុគ្គលិកម្នាក់នៃ NGO បទសម្ភាសនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ភ្នំពេញ។

ការចូលរួមបានពេញលេញនៅ TWG និង គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) សមត្ថភាពសង្គមស៊ីវិលនៅតែខ្សោយ លើកលែងតែក្នុងវិស័យសុខាភិបាល និងការអប់រំ ដែលយន្តការចម្រុះភាគី មានភាពជោគជ័យខ្លាំង សម្រាប់តែការចូលរួមក្នុងតំបន់ទីប្រជុំជនប៉ុណ្ណោះ។ នៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន វេទិកាសម្រាប់ការចូលរួមរបស់សង្គមស៊ីវិលក្នុងរបៀបវារៈអភិវឌ្ឍន៍នៅមានកម្រិត (Nowaczyk ២០១១)។

ឱកាសទី ២ គឺកម្ពុជាបានពង្រឹងអភិបាលកិច្ចជាបន្តបន្ទាប់។ ដូចបានលើកឡើងខាងដើមថា កម្ពុជាខ្វះការពង្រឹងអភិបាលកិច្ចដូចដែលបានគ្រោងទុក ដែលចំណុចនេះ ត្រូវបាន David Roberts (ឆ្នាំ២០០៩) ហៅថា ការកសាងសំបកនយោបាយជាជាងការកសាងស្ថាប័ន (ដែលត្រូវបានទទួលស្គាល់ក្នុងបរិបទលោកខាងលិច)។ ទោះជាយ៉ាងណា ភស្តុតាង និងការសង្កេតតាមបទពិសោធន៍ជាក់ស្តែង (ហ្គីរី ឆ្នាំ ២០១៥) បង្ហាញថា កម្ពុជាបានធ្វើកំណែទម្រង់ជាច្រើន ចាប់តាំងពីការបោះឆ្នោតជាសាកលឆ្នាំ ២០១៣ ហើយការកែលម្អអភិបាលកិច្ច និងការបញ្ជូនសេវាកម្ម អាចនឹងបន្តមានសន្ទុះ។ ឧទាហរណ៍ អ្នកដឹកនាំដ៏មានប្រជាប្រិយភាពពីររូប ត្រូវបានតំឡើងតំណែងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាណិជ្ជកម្ម។ ថ្មីៗនេះ អង្គភាពប្រឆាំងអំពើពុករលួយ កំពុងធ្វើការកាន់តែសកម្ម ដោយបញ្ជូនសារ ដែលមានអត្ថន័យច្បាស់លាស់ ទៅកាន់វិស័យឯកជន និងសាធារណៈ អំពីលទ្ធផលនៃការប្រព្រឹត្តិអំពើពុករលួយ។ អ្នកផ្តល់បទសំភាសន៍[13] បានសង្កេតឃើញថា "អំពើពុករលួយនៅតែបន្តកើតមាន តែទោះជាយ៉ាងណា វាមិនសូវមានលក្ខណៈបើកចំហរដូចពីមុនទេ"។ លើសពីនេះ អ្នកផ្តល់បទសំម្ភាសន៍ដដែល បាននិយាយថា រដ្ឋាភិបាលសព្វថ្ងៃ "ខុសពីមុន គឺបានផ្លាស់ប្តូរហើយ"។ នៅពេលក្រុមហ៊ុនសារជីវកម្ម ដែលគាត់បម្រើការងារ បង្ហាញពីអ្វីដែលក្រុមហ៊ុនចង់បាន (ពីរដ្ឋ) ដូចជា បទប្បញ្ញត្តិចាំបាច់ថ្មីៗ ដែលកម្ពុជាគួរតែអនុម័ត និងទម្រង់ផ្សេងៗ ពាក់ព័ន្ធនឹងការគាំទ្រស្ថាប័ន ថ្នាក់ដឹកនាំជាន់ខ្ពស់ជារឿយៗ បានយល់ព្រម និងអនុវត្តតាម បើទោះបីជាមានការពន្យារពេលបន្តិចបន្តួចក្តី។ ប្រការដែលគួររំពឹកឡើងវិញនោះ គឺការអភិវឌ្ឍស្ថាប័ននៅក្នុងវិស័យមួយចំនួនដូចជា ការកាត់បន្ថយអត្រាមេរោគអេដស៍ (HIV/AID) និង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (K.Un និង Hughes ឆ្នាំ ២០១១)។ ចំណុចបន្ទាប់នឹងពិភាក្សាពីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ រដ្ឋាភិបាលបានបង្កើនសមត្ថភាពក្នុងការប្រមូលពន្ធអាករ ហើយចំណូលពន្ធក្នុងស្រុក ត្រូវបានប្រមូលកាន់តែច្រើន។ ទាំងនេះ បង្ហាញថា ទោះបីជាកម្ពុជានឹងមិនទទួលបានជោគជ័យ ១០០% សម្រាប់គោលបំណងអភិបាលកិច្ចល្អដែលរួមមាននីតិរដ្ឋ វឌ្ឍនភាពដែលកម្ពុជាបានធ្វើ ប្រហែលជាអាចធ្វើឱ្យមានជំនួយកាន់តែច្រើនពីសហគមន៍អន្តរជាតិ។

[13] បុគ្គលិកឯកជន ចំនួនបីនាក់ ត្រូវបានសម្ភាសតាម Skype ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥។

ឱកាសទី៣ គឺការបង្កើនភាពជាម្ចាស់កម្មសិទ្ធិរបស់រដ្ឋាភិបាលទៅលើរបៀបវារៈអភិវឌ្ឍន៍ និងជំនួយបរទេស។ ប្រសិទ្ធភាពជំនួយគឺជាផ្នែកមួយនៃយន្តការបច្ចុប្បន្ន ដែលសំខាន់សម្រាប់ប្រទេសពឹងផ្អែកលើជំនួយដូចជាកម្ពុជា ដើម្បីសម្រេចបាននូវ SDGs។ ខណៈដែលការវិវឌ្ឍនៃប្រសិទ្ធភាពជំនួយចាប់តាំងពីមានសេចក្តីប្រកាសក្រុងបារីស ឆ្នាំ២០០៥ រហូតដល់ប្រសិទ្ធភាពអភិវឌ្ឍន៍ឆ្នាំ២០១១[14] ត្រូវបានបង្ហាញថា មានទុទ្ធិដ្ឋិនិយម ជាជាងសុទិដ្ឋិនិយមនោះ[15] កំណត់ត្រា នៃប្រសិទ្ធភាពជំនួយនៅកម្ពុជា និងនិន្នាការនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ផ្តល់នូវឱកាសកាន់តែច្រើនសម្រាប់កម្ពុជា ក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិលើរបៀបវារៈអភិវឌ្ឍន៍ របស់ខ្លួនឱ្យកាន់តែប្រសើរជាងពីមុន។ ប្រទេសកម្ពុជាក្រោយពីមានជម្លោះ បានទទួលការគាំទ្រពីអង្គការសហប្រជាជាតិ សម្រាប់ដំណើរការកសាងសុខសន្តិភាព និងប្រជាធិបតេយ្យ ដោយចាប់ផ្តើមពីការបោះឆ្នោតជាតិលើកដំបូងក្នុងឆ្នាំ១៩៩៣ ក្រោមការគាំទ្រពីអង្គការសហប្រជាជាតិ។ វឌ្ឍនភាពរបស់កម្ពុជា បានផ្តើមចេញពីសន្និសីទថ្នាក់រដ្ឋមន្ត្រីឆ្នាំ ១៩៩២ ស្តីពីការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ (MCRRC) នៅទីក្រុងតូក្យូ រហូតដល់កិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិស្តីពីការកសាងប្រទេសកម្ពុជា (ICRC) ដែលបានប្រព្រឹត្តិទៅជាលើកដំបូងនៅទីក្រុងប៉ារីស ឆ្នាំ១៩៩៣ ហើយកិច្ចប្រជុំនេះ ត្រូវបានជំនួសដោយក្រុមពិភាក្សា (CG) នៅឆ្នាំ១៩៩៦។ CG បានចាប់ផ្តើមរៀបចំធ្វើឡើងជាលើកដំបូងនៅទីក្រុងភ្នំពេញ ឆ្នាំ២០០២ ដោយមានការចូលរួមពីរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោកជាប្រធាន និងត្រូវបានជំនួសដោយកិច្ចប្រជុំនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ឆ្នាំ ២០០៧។ ការវិវឌ្ឍនេះបង្ហាញឱ្យឃើញពីភាពជាម្ចាស់កម្មសិទ្ធិ និងភាពជាអ្នកដឹកនាំកាន់តែច្រើនឡើងរបស់រដ្ឋាភិបាល

[14] ផ្អែកលើសេចក្តីប្រកាសទីក្រុងប៉ារីសឆ្នាំ ២០០៥ ស្តីពីប្រសិទ្ធភាពជំនួយ ដោយផ្តោតលើភាពជាម្ចាស់កម្មសិទ្ធិ ការរៀបចំ សុខដុមនីយកម្ម ការចាត់ចែងលទ្ធផល និងគណនេយ្យភាពទៅវិញទៅមក (OECD ឆ្នាំ២០១២) វេទិកាជាន់ខ្ពស់លើកទី៤ ឆ្នាំ ២០១១ (HLF4) ស្តីពីប្រសិទ្ធភាពអភិវឌ្ឍន៍នៅទីក្រុង ប៊ូសាន បន្ទាប់មកជាមួយកិច្ចសហប្រតិបត្តិការភាពជាដៃគូជាសាកល សម្រាប់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។ នៅក្នុង HLF4 ទីក្រុងប៊ូសាន ភាពជាដៃគូត្រូវបានព្រមព្រៀង ដោយមិនត្រឹមតែរាប់បញ្ចូលទំនាក់ទំនងខ្សែបណ្តោយដ៏ល្អឥតខ្ចោះក្នុងចំណោមប្រទេសទទួលជំនួយប៉ុណ្ណោះទេ ថែមទាំងក្នុងចំណោមម្ចាស់ជំនួយដូចជា ចិន កូរ៉េខាងត្បូង ឥណ្ឌា និងប្រេស៊ីល វិស័យឯកជននីមួយៗ សង្គមស៊ីវិល និងបណ្ឌិតសភាចារ្យ (Eyben និង Savage ឆ្នាំ២០១៣)។ នៅទីក្រុងប៊ូសាន វេទិកានេះបានសង្កត់ធ្ងន់លើកិច្ចសហប្រតិបត្តិការក្នុងការគាំទ្របណ្តាប្រទេសនៅភូមិភាគខាងត្បូង ដើម្បីសម្រេចបាននូវ "ប្រសិទ្ធភាពអភិវឌ្ឍន៍" (Eyben និងSavage ឆ្នាំ២០១៣ ទំព័រ ៥៥៧)។

[15] ការវាយតម្លៃថ្មីៗ របស់អង្គការសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហប្រតិបត្តិការ (OECD) បានបង្ហាញអំពីលទ្ធផលនៃសេចក្តីប្រកាសទីក្រុងប៉ារីស ឆ្នាំ២០០៥ ស្តីពីប្រសិទ្ធភាពជំនួយ និងការប្តេជ្ញាចិត្ត "ប្រាកដប្រជា" ថាមានតែគោលដៅកិច្ចសហប្រតិបត្តិការបច្ចេកទេសមួយប៉ុណ្ណោះ ដែលបានសម្រេច រីឯគោលដៅចំនួន ១២ ទៀតមិនត្រូវបានសម្រេចទេ (OECD ឆ្នាំ២០១២) ដោយលើកឡើងថា ប្រសិទ្ធភាពជំនួយគឺនៅឆ្ងាយពីលទ្ធភាពដែលអាចសម្រេចបាន។

កម្ពុជា ក្នុងការសម្របសម្រួលជំនួយសម្រាប់ការអភិវឌ្ឍនៅប្រទេសកម្ពុជា (RGC ឆ្នាំ ២០១២)។ ប្រការសំខាន់ជាងនេះទៀតនោះ រដ្ឋាភិបាលកាន់តែមានបំណងចង់ធ្វើជាម្ចាស់របៀបវារៈអភិវឌ្ឍន៍របស់ខ្លួនច្រើនជាងទស្សនៈពីមុន ដែលនេះបង្ហាញឱ្យឃើញថា កិច្ចសហប្រតិបត្តិការត្បូង-ត្បូង មានផ្លែផ្កា និងប្រសិទ្ធភាព (RGC ឆ្នាំ២០១៣)។ យុទ្ធសាស្ត្រភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ២០១៤-២០១៨ ចាត់ទុកថា កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ជាគំរូដ៏មាន*សក្តានុពល* ដែលអាច "...ផ្តល់ដំណោះស្រាយគោលនយោបាយ និងបច្ចេកវិទ្យាកាន់តែសមស្របនឹងបរិបទ បំពេញតាមតម្រូវការ មានការឆ្លើយតប ភាពបត់បែន ប្រសិទ្ធភាពចំណាយ និងនិរន្តរភាព" (RGC ឆ្នាំ ២០១៣ ទំព័រ ៨)។ ការសិក្សាស្រាវជ្រាវបានបញ្ជាក់ថា ទោះបីជាមានការព្រួយបារម្ភអំពីផលប៉ះពាល់អវិជ្ជមាននៃម្ចាស់ជំនួយនានា ដូចជា កូរ៉េខាងត្បូង ចិន ឥណ្ឌា និងថៃ ដែលបានផ្តល់ជំនួយដល់ប្រទេសកម្ពុជា ក៏រដ្ឋាភិបាលចាត់ទុកថា ជំនួយ និងបែបបទទាំងនេះ មានផលវិជ្ជមាន (Sato et al. ឆ្នាំ ២០១១)។ រដ្ឋាភិបាលចាត់ទុកថា តម្រូវការហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានផ្គត់ផ្គង់ដោយម្ចាស់ជំនួយទាំងនោះ (ជាពិសេស ចិន) គឺមានការផ្តល់ឱ្យទាន់ពេលវេលា និងកាន់តែមានប្រសិទ្ធភាព (បើប្រៀបធៀបនឹងបែបបទនៃប្រទេសលោកខាងលិច) ដែលនេះគឺជាការរួមចំណែកដល់កំណើន និងការអភិវឌ្ឍប្រទេសកម្ពុជា ក៏ដូចជា SDG នាពេលខាងមុខ នេះបើយោងតាមការទស្សន៍ទាយ។ ចរិតលក្ខណៈនៃការបំពេញបន្ថែមរបស់ប្រទេសម្ចាស់ជំនួយ ជាធម្មតា គឺការផ្តល់ហេដ្ឋារចនាសម្ព័ន្ធធំៗ (ជាពិសេស ផ្លូវថ្នល់) ដែលប្រទេសកម្ពុជា ត្រូវការជាបន្ទាន់ និងមិនមែនជាអាទិភាពរបស់ម្ចាស់ជំនួយពីមុនទេ។

ឱកាសទី ៤ គឺជាដំណើរដ៏សកម្មក្នុងតំបន់នៃសហគមសេដ្ឋកិច្ចអាស៊ាន (AEC) ដែលនឹងត្រូវផ្តល់ឱ្យប្រទេសកម្ពុជា។ សហគមសេដ្ឋកិច្ចអាស៊ាន បង្ហាញពីឱកាសកាន់តែច្រើនសម្រាប់កម្ពុជាជាជាងបញ្ហាប្រឈម ដោយរួមចំណែកដល់ការសម្រេចបានទស្សនវិស័យរបស់ SDGs។ សមាជិកភាពកម្ពុជានៅក្នុង សហគមសេដ្ឋកិច្ចអាស៊ាន គឺត្រូវបានមើលឃើញថា ជាផលចំណេញសុទ្ធសម្រាប់ប្រទេសនេះ (Hing ឆ្នាំ២០១៥ Hing និង Strange ឆ្នាំ ២០១៥ ADB និង ILO ឆ្នាំ២០១៤ Pich ឆ្នាំ២០១៤ Dahles ឆ្នាំ ២០១៥)។ ពាក់ព័ន្ធនឹងលំហូរដោយសេរីនៃទំនិញ សេវាកម្ម ការវិនិយោគ មូលធន ពលករជំនាញ និងការរៀបចំពាណិជ្ជកម្មដោយសេរី ដំណើរការនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់តំបន់នេះទាំងមូល (Hing និង Strange ឆ្នាំ ២០១៥)។ សម្រាប់កម្ពុជា គេរំពឹងថា ផសស នឹងកើនឡើងចំនួន ៤,៤% ការនាំចេញ ៥,៣% និងការវិនិយោគឯកជន ២៤,៨% (Itakura ឆ្នាំ២០១៣ ដកស្រង់ចេញពី Hing និង Strange ឆ្នាំ២០១៥)។ សហគមសេដ្ឋកិច្ចអាស៊ាន ក៏ជាឱកាសមួយសម្រាប់ប្រទេសនេះ ដើម្បីធ្វើកំណែទម្រង់ចាំបាច់នានា សម្រាប់កម្ពុជា ដើម្បីបង្កើនផលចំណេញពីសមាហរណកម្ម។ សមាហរណកម្មក្នុងតំបន់ និងសកល អនុញ្ញាតឱ្យប្រទេសដែលមានសេដ្ឋកិច្ចតូចដូចកម្ពុជា ឱ្យកាន់តែមានការប្រកួតប្រជែងសម្រាប់ ផលិតផលឧស្សាហកម្ម និងជាឱកាសទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI)។ ទោះជាយ៉ាងណា ការសិក្សានេះក៏បានលើកឡើង ទាក់ទង

នឹងតថភាពនៃស្ថានភាពអប់រំ និងកំណើនសេដ្ឋកិច្ចរបស់កម្ពុជាបច្ចុប្បន្ន ចាំបាច់ត្រូវតែមានការប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចបាននូវលទ្ធផលល្អសម្រាប់សមាជិកសហគមសេដ្ឋកិច្ចអាស៊ាន។ កម្ពុជាត្រូវការដោះស្រាយបញ្ហាបរិយាកាសវិនិយោគ ដែលកំពុងដើរក្រោយបណ្តាប្រទេសនានាក្នុងតំបន់ ការសម្របសម្រួលពាណិជ្ជកម្ម ការអភិវឌ្ឍនិងការគាំទ្រផ្នែកសហគ្រាសខ្នាតតូច និងមធ្យម គុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) (Hing ឆ្នាំ ២០១៥)[16]។

## ហិរញ្ញប្បទាន SDGs ៖ តាមរយៈអ្នកណា?

ជាក់ស្តែងដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ប្រទេសនីមួយៗ ត្រូវការហិរញ្ញប្បទានជាចាំបាច់ ហើយកម្ពុជាក៏មិនខុសគ្នាដែរ។ ទាក់ទងនឹងចំណុចនេះ រដ្ឋាភិបាលបានលើកឡើងម្តងហើយម្តងទៀតអំពីសារៈសំខាន់នៃជំនួយ ឬជំនួយសម្រាប់អភិវឌ្ឍ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតួនាទីរបស់វិស័យឯកជន។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក អូន ព័ន្ធមុនីរ័ត្ន ដែលបានថ្លែងនៅក្នុងសន្និសីទអន្តរជាតិលើកទី ៣ ស្តីពីហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍនៅទីក្រុងអាឌីស អាបាបា ប្រទេសអេត្យូពី កាលពីខែកក្កដា ឆ្នាំ២០១៥ បានលើកឡើងម្តងទៀត អំពីស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសកម្ពុជា។ លោកបានឆ្លៀតក្នុងឱកាសនោះ ធ្វើការអំពាវនាវឱ្យថ្នាក់ដឹកនាំពិភពលោក មានវត្តមាននៅក្នុងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ដែលរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តចំពោះ SDGs ហើយនឹងចូលរួមកិច្ចប្រឹងប្រែងក្នុងការប្រមូលមូលនិធិចាំបាច់សម្រាប់របៀបវារៈក្នុងស្រុក។ កម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះរបៀបវារៈសកម្មភាពរបស់ទីក្រុងអាឌីសអាបាបា ដែលត្រូវបានជឿជាក់ថានឹងជួយកៀរគរធនធានដើម្បីផ្តល់ហិរញ្ញប្បទានដល់ SDGs (Aun ឆ្នាំ ២០១៥)។

ខាងក្រោមគឺជាការពិភាក្សាអំពីភាពខ្លាំង និងភាពខ្សោយនៃចំណុចសំខាន់ៗ ចំនួនបី រួមមាន ការពង្រឹងការប្រមូលចំណូលពន្ធក្នុងស្រុក ការលើកទឹកចិត្តវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន លំហូរការវិនិយោគផ្ទាល់ពីបរទេស និងលំហូរជំនួយសម្រាប់អភិវឌ្ឍ ជាបន្តបន្ទាប់ (ជំនួយឥតសំណង និងកម្ចី)។

---

[16] សម្រាប់ព័ត៌មានលម្អិត អំពីគុណសម្បត្តិ និងគុណវិបត្តិនៃសហគមសេដ្ឋកិច្ចអាស៊ាន និងផលវិបាកនានាសម្រាប់កម្ពុជា សូមមើលឧបសម្ព័ន្ធ ០២។ ដូច្នេះ យើងគួរតែសង្កត់ធ្ងន់បន្ថែមម្តងទៀតថា សហគមសេដ្ឋកិច្ចអាស៊ាន បង្ហាញពីឱកាសច្រើនជាងបញ្ហាប្រឈមយ៉ាងហោចណាស់ក៏ក្នុងរយៈពេលខ្លីដែរ។ តើកម្ពុជាអាចធ្វើកំណែទម្រង់គ្រប់គ្រាន់ដែលអាចធ្វើឱ្យខ្លួនចៀសផុតពីបញ្ហាប្រឈមផ្សេងៗ ដែលយើងចង្អុលបង្ហាញ ឬក៏អត់នោះ គឺលើសពីវិសាលភាពនៃការសិក្សានេះ ជាពិសេសក្នុងរយៈពេលវែង។

## កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រមូលចំណូលពន្ធដែលជាធនធានក្នុងស្រុក

ដូចបានរៀបរាប់ខាងលើ របៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ នឹងគិតគូរច្រើនទៅលើការប្រមូលចំណូលពន្ធក្នុងស្រុក និងមិនសូវគិតគូរទៅលើជំនួយនោះទេ (Green et al. ឆ្នាំ ២០១២)។ ការត្រួតពិនិត្យលើនិន្នាការចំណូលពន្ធក្នុងស្រុកគឺមានសុទិដ្ឋិនិយម យ៉ាងហោចណាស់ក៏នៅក្នុងរយៈពេលមធ្យមដែរ។ តាមរយៈការឆ្ពោះទៅមុននៃកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) គេប៉ាន់ស្មានថា ចំណូលពន្ធក្នុងស្រុករបស់រដ្ឋាភិបាលបានកើនឡើងដល់ ១៦,១% នៃ ផសស (ឬ ២,៦៨ ប៊ីលានដុល្លារ) នៅក្នុងឆ្នាំ ២០១៤ ធៀបនឹង ១៥,១% ក្នុងឆ្នាំ ២០១៣ (WB ឆ្នាំ ២០១៥) ។ កំណើន ១ % នៃ ផសស បង្ហាញឱ្យឃើញការរីកចម្រើនយ៉ាងខ្លាំង ដែលលើសពីគោលដៅ ០,៥% នៅក្នុងកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីបង្កើនការប្រមូលពន្ធ រដ្ឋាភិបាលបានប្រើប្រាស់យុទ្ធសាស្ត្រប្រមូលធនធានរយៈពេលមធ្យម (RBS) ឆ្នាំ ២០១៤-២០១៨ ដែលជាមូលដ្ឋានសំដៅពង្រឹងសមត្ថភាពក្នុងការប្រមូលពន្ធអាករ ខណៈដែលរក្សាបាននូវពន្ធដែលមានស្រាប់ និងអត្រាពន្ធឱ្យនៅដដែល។ យុទ្ធសាស្ត្រប្រមូលធនធានរយៈពេលមធ្យម ប្តេជ្ញាធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលពន្ធដារ ប៉ុន្តែមិនពង្រីកវិសាលភាពពន្ធដារ និងបង្កើនអត្រាពន្ធឡើយ។ ទោះជាយ៉ាងណា នៅពេលពង្រឹងការអនុវត្តរួច គេរំពឹងថានឹងអាចប្រមូលពន្ធបានកាន់តែច្រើន ជាពិសេសក្រុមហ៊ុនចុះបញ្ជីធំៗ[17]។

**តារាង ១ ៖ ចំណូលសាធារណៈ គិតជាភាគរយនៃ ផសស**

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010e | 2011 | 2012 | 2013 | 2014 | 2015p | 2016f | 2017f |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| %GDP | 10.2 | 10.0 | 10.5 | 9.6 | 10.3 | 10.3 | 11.5 | 11.9 | 12.0 | 11.5 | 13.1 | 13.2 | 15.3 | 15.1 | 16.1 | 16 | 16.3 | 16.8 |

ប្រភព ៖ (WB ឆ្នាំ ២០១១) (WB ឆ្នាំ ២០១៥) e = ការប៉ាន់ស្មាន f = ការព្យាករណ៍ p = ការទស្សន៍ទាយ

[17] បុគ្គលិកធនាគារអភិវឌ្ឍន៍ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៥។

## រូបភាព ៣ ៖ យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ ២០១៤-២០១៨

- **Main principles:** (1) full potential; (2) no new tax; (3) no tax rate increase; and (4) simplicity, equity, efficiency, transparency and accountability.
- **Three pillars:** (1) revenue administration; (2) revenue policy; and (3) monitoring and evaluation.
- **Target:** 0.5 percentage point of GDP current revenue increase per annum.
- **Policy reviews:** excises, value-added tax, tax base (estimated regime category), tax incentive, and property tax. Studying income tax and drafting state property law.

គោលដៅប្រចាំឆ្នាំ ដោយអគ្គនាយកដ្ឋាន

| អគ្គនាយកដ្ឋាន | 2014b | 2015p | 2016p | 2017p | 2018p |
|---|---|---|---|---|---|
| (ផសស គិតជាភាគរយ) | | | | | |
| GDCE | 6.85 | 7.08 | 7.24 | 7.39 | 7.54 |
| *ផ្លាស់ប្តូរ* | | *0.23* | *0.16* | *0.15* | *0.15* |
| GDT | 5.87 | 6.26 | 6.62 | 6.97 | 7.29 |
| *ផ្លាស់ប្តូរ* | | *0.39* | *0.36* | *0.35* | *0.32* |
| ចំណូលក្រៅពីពន្ធ | 2.48 | 2.35 | 2.40 | 2.45 | 2.51 |
| *ផ្លាស់ប្តូរ* | | -0.13 | 0.05 | 0.05 | 0.06 |
| សរុប | 15.20 | 15.69 | 16.26 | 16.81 | 17.34 |

GDCE: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

GDT: អគ្គនាយកដ្ឋានពន្ធដារ

b=ថវិកា; p=ការប៉ាន់ប្រមាណ

តំបន់គោលដៅ

| អគ្គនាយកដ្ឋាន | វង្វាស់វង្វាល់ ឬចំនុចដែលយកចិត្តទុកដាក់ |
|---|---|
| GDCE | Automated manifest, risk management, post-clearance audit, anti-smuggling, single window, institution, human resources, and audit strengthening |
| GDT | Registration, services, tax audits, debt, organization, human resources, and technology |
| ចំណូលក្រៅពីពន្ធ | Receipting system, civil aviation, tourism, visas, telecom, leases, public enterprises, casinos, and privatization |

ប្រភព (WB ឆ្នាំ ២០១៥ ទំព័រ ១០)

គួរកត់សម្គាល់ថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញពីមូលដ្ឋាននៃមុខងាររបស់រដ្ឋ និងពាក់ព័ន្ធនឹងភាពស្មុគ្រស្មាញខ្លាំងនៅពេលធ្វើកំណែទម្រង់។ ករណី កម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់កម្ពុជា ក៏មានលក្ខណៈស្រដៀងគ្នាដែរ។ ជាទូទៅ ការវិវឌ្ឍនៃកំណែទម្រង់ខាងលើ ត្រូវបានរាំងស្ទះដោយភាពស្ទាក់ស្ទើររបស់អ្នកនយោបាយ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបញ្ចេញមូលដ្ឋានហិរញ្ញវត្ថុទៅកាន់ក្រសួងពាក់ព័ន្ធ ដោយធ្វើឱ្យមានការយឺតយ៉ាវក្នុងការដោះស្រាយបញ្ហាទូទាត់ប្រាក់។ លទ្ធផលនៃ កម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញឱ្យឃើញពីការអភិវឌ្ឍមិនស្មើគ្នា រីឯចំណូលពន្ធក៏មានការកើនឡើងជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងណា ទម្រង់ និងការរៀបចំចំណាយ ទំនងជាមានការយឺតយ៉ាវ ដោយបណ្ដាលឱ្យមានការលំបាកដល់ក្រសួងពាក់ព័ន្ធ ក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន។ ទោះជាយ៉ាងណា ជាទូទៅ ដោយមានការគាំទ្ររបស់ធនាគារពិភពលោក និងការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាល ការវិវឌ្ឍនៃចំណាយគឺកំពុងតែដំណើរការជាលំដាប់[18]។

## *កំណើនសេដ្ឋកិច្ច/វិស័យឯកជន*

ខណៈដែលសេដ្ឋកិច្ចកំពុងរីកចម្រើន ការអភិវឌ្ឍវិស័យឯកជនគឺជាគន្លឹះនៃកំណើនប្រកបដោយនិរន្តរភាព។ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាជាងពីរទសវត្សរ៍កន្លងមកនេះ រីកចម្រើនគួរឱ្យកត់សម្គាល់ជាខ្លាំង បើទោះជាមូលដ្ឋាននៃកំណើននេះ មានលក្ខណៈតូចចង្អៀតក៏ដោយ។ កិច្ចពិភាក្សាជាបន្តបន្ទាប់នឹងបង្ហាញថា រដ្ឋាភិបាលដឹងពីឧបសគ្គក្នុងការសម្រេចបាននូវកំណើនប្រកបដោយនិរន្តរភាពនេះ និងបានបង្ហាញពីការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយឧបសគ្គទាំងនោះ ដូចជា ការប្រើប្រាស់គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មជាដើម។ លើសពីនេះតាមការកត់សម្គាល់នៅក្នុងការពិភាក្សាកន្លងមកបង្ហាញថា អភិបាលកិច្ចមានភាពប្រសើរជាមុន ជាពិសេសក្នុងការឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជន ហើយសហគមសេដ្ឋកិច្ចអាស៊ាន នឹងផ្ដល់តម្លៃបន្ថែមសម្រាប់កំណើនរបស់កម្ពុជា។ ដូច្នេះ ខណៈដែលគេកំពុងរង់ចាំមើលថាតើ គោលនយោបាយអភិវឌ្ឍផ្នែកឧស្សាហកម្ម (IDP) សហគមសេដ្ឋកិច្ចអាស៊ាន និង កំណែទម្រង់របស់រដ្ឋាភិបាល នឹងត្រូវបានធ្វើឡើងដោយរបៀបណានោះ ទស្សនវិស័យនៃកំណើននេះ អាចយ៉ាងហោចណាស់ ក៏មានរយៈពេលមធ្យមដែរ។

ពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ ក្នុងអត្រាជាមធ្យម ៧% (CDRI ឆ្នាំ ២០១៣ Hill & Menon ឆ្នាំ ២០១៣ RGC ឆ្នាំ ២០១៤) ដែលកំណើននេះ លើសពីការទស្សន៍ទាយរបស់មនុស្សគ្រប់រូប នៅពេលកិច្ចព្រមព្រៀងសន្តិភាពទីក្រុង

[18] បុគ្គលិកធនាគារអភិវឌ្ឍន៍ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៥។

ប៉ារីស ត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៩១។ កំណើននេះពឹងផ្អែកលើវិស័យវាយនភណ្ឌ ទេសចរណ៍ សំណង់ និងសេវាកម្មផ្សេងៗ។ ទោះជាយ៉ាងណា បញ្ហាប្រឈម និងរបៀបវារៈកំណែទម្រង់នេះ គឺសុទ្ធសឹងតែពិបាកដោះស្រាយដូចគ្នា។ ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) អាចមានការធ្លាក់ចុះ។ ប្រការនេះ ប្រហែលជាមិនអាចចៀសផុតនោះគឺ ដោយសារសេដ្ឋកិច្ចមានមូលដ្ឋានតូចចង្អៀតនៅឡើយ រដ្ឋាភិបាលបានកំណត់លើឥទ្ធិពលនយោបាយក្នុងការដោះស្រាយបញ្ហាប្រឈម ដែលបណ្ដាលមកពីការប្រែប្រួលសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក (Hall និង Menon ឆ្នាំ ២០១៣ និង ឆ្នាំ ២០១៤)។

រដ្ឋាភិបាលទទួលស្គាល់ ពីសារៈសំខាន់ លើការអភិវឌ្ឍវិស័យឧស្សាហកម្ម ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់ ក៏ដូចជា សាកលភាវូបនីយកម្ម។ ជាក់ស្ដែង ក្នុងការអភិវឌ្ឍគោលនយោបាយឧស្សហកម្មជាលើកដំបូង គឺផ្ដោតសំខាន់លើការពង្រឹង និងការលើកកម្ពស់ការវិនិយោគក្នុងស្រុក តាមរយៈការពង្រឹងអនុវិស័យផ្នែកសហគ្រាសធុនតូច និងមធ្យមរបស់ខ្លួន និងការលើកទឹកចិត្តឱ្យការវិនិយោគផ្ទាល់ពីបរទេស មានការរីកចម្រើន (RGC ឆ្នាំ ២០១៥)[19] ។ លទ្ធភាពដែលអាចសម្រេចបាននូវគោលនយោបាយនេះ គឺអាស្រ័យទៅលើលក្ខខណ្ឌនៃការបង្កើនសមត្ថភាពវិស័យសាធារណៈ ការដោះស្រាយបញ្ហាប្រឈមក្នុងការសម្របសម្រួលវិស័យសាធារណៈ និងអភិបាលកិច្ច[20] នៅគ្រប់លំដាប់ថ្នាក់។

គោលនយោបាយអភិវឌ្ឍផ្នែកឧស្សាហកម្ម ក៏លើកឡើងអំពីតួនាទីរបស់ផ្នែកសហគ្រាសធុនតូច និងមធ្យមក្នុងការរួមចំណែកចំពោះកំណើន និងការបង្កើតការងារ (RGC ឆ្នាំ ២០១៥)[21]។ ផ្នែកសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដើរតួនាទីដ៏សំខាន់នៅសម្រាប់កំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងការអភិវឌ្ឍសង្គម។ វិស័យ សហគ្រាសធុនតូច និងមធ្យមបានបង្កើតការងារពី ៤០-៥០ កន្លែង និងគ្របដណ្ដប់ក្នុងចំនួនដ៏ច្រើនលើសលប់លើវិស័យឯកជននៅកម្ពុជា ក្នុងអត្រា ៩៩% នៃវិស័យឯកជនទាំងមូល និង៤៥% នៃការងារ។ យោងតាមតួលេខរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានពន្ធដារ នៅក្នុងឆ្នាំ ១៩៩៩ បង្ហាញថា មានសហគ្រាសធុនតូច និងមធ្យមចំនួន ៥៥.៤៦៦ ទោះជាយ៉ាងណា នៅត្រឹមឆ្នាំ ២០០៧ មានប្រហែល ១៤.៣២៤ គ្រឹះស្ថានប៉ុណ្ណោះ ដែលបានចុះបញ្ជីស្របច្បាប់ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត (នៅក្រសួងពាណិជ្ជកម្ម)។ ផ្នែកសហគ្រាសធុនតូច និងមធ្យម ភាគច្រើននៅតែមិនទាន់បានចុះបញ្ជីជាមួយក្រសួង និងធ្វើ

[19] មន្ត្រីរដ្ឋាភិបាល ត្រូវបានសម្ភាសនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៥

[20] មន្ត្រីរដ្ឋាភិបាល ត្រូវបានសម្ភាសនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែសីហា វិស័យអភិវឌ្ឍន៍ រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែសីហា វិស័យអភិវឌ្ឍន៍ រាជធានីភ្នពេញ ថ្ងៃទី ២៧ ខែសីហា និងវិស័យអភវិឌ្ឍន៍ Skype ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៥។

[21] មន្ត្រីរដ្ឋាភិបាល ត្រូវបានសម្ភាសនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៥។

ប្រតិបត្តិការក្រោមអាជ្ញាប័ណ្ណប្រតិបត្តិការ ដែលចេញពីក្រសួងផ្សេងៗ ឬ នាយកដ្ឋានក្នុងស្រុកនានា (ក្រុង ឬ ខេត្ត) (IFC ឆ្នាំ ២០១០)។

ទោះបីជាកំណើននេះ រឹងមាំ និងមានស្ថេរភាព ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ក៏ដោយ បរិបទធុរកិច្ចនៅកម្ពុជាមិនសូវមានការផ្លាស់ប្តូរនោះទេ។ ការសិក្សារបស់ធនាគារពិភពលោកស្តីពីភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មជុំវិញពិភពលោក រួមមានប្រទេសកម្ពុជា បង្ហាញថា តាមការវាយតម្លៃរបស់ការសិក្សាទៅលើតំបន់មួយចំនួន គឺមានការផ្លាស់ប្តូរជាវិជ្ជមានតិចតួច ខណៈដែលនៅតំបន់ផ្សេងៗ មានចលនាដើរថយក្រោយ (WB ឆ្នាំ២០១៥)។ ដូចបានបង្ហាញនៅក្នុងការសិក្សារួចមកហើយ ក្នុងចំណោម ១៨៩ ប្រទេស កម្ពុជាស្ថិតនៅលំដាប់លេខរៀងទី ១៣៥ នៃភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម ក្នុងឆ្នាំ២០១៥ ដែលនេះជាការកើនឡើង ១ លេខ បើធៀបនឹងឆ្នាំមុន (ចំណាត់ថ្នាក់លេខ ១៣៤) (ពិន្ទុសម្រាប់ឆ្នាំ២០១៥ គឺ ៥៥,៣៣ និងឆ្នាំ ២០១៤ គឺ ៥៥,០៤ ក្នុងលំដាប់ពិន្ទុពី 0-១០០)។

**រូបភាពទី ៤ ៖ ចំណាត់ថ្នាក់កម្ពុជាលើភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម និងដៃគូ ប្រៀបធៀបសម្រាប់ឆ្នាំ ២០១៤**



**រូបភាពទី ៥ ៖ តើកម្ពុជាបានធ្វើច្រើនប៉ុណ្ណាទាក់ទងនឹងផ្នែកមួយចំនួន ដែលត្រូវបានវាយតម្លៃសម្រាប់ភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម (ឆ្នាំ ២០១០  ២០១៣ និង ២០១៤)?**




ប្រភព ៖ WB ឆ្នាំ ២០១៤

ទោះជាយ៉ាងណា អ្នកផ្តល់បទសម្ភាសមួយចំនួនបានលើកឡើងអំពីព័ត៌មានលម្អិតមួយចំនួន ដែលបង្ហាញថា បរិបទពាណិជ្ជកម្មនៅកម្ពុជា គឺមានទិដ្ឋភាពខុសៗគ្នា។ រដ្ឋាភិបាលមិនបានឆ្លើយតបគ្រប់គ្រាន់ចំពោះតម្រូវការវិស័យឯកជន (ដូចមានបង្ហាញតារាងខាងលើ)[22] ប៉ុន្តែ រដ្ឋាភិបាលស្តាប់តាម និងធ្វើកំណែទម្រង់យឺតៗ បើទោះជាមិនបានលឿនដូចការរំពឹងទុកក៏ដោយ ប៉ុន្តែគឺធ្វើទៅតាមល្បឿននៃការគណនាសេដ្ឋកិច្ចនយោបាយរបស់រដ្ឋាភិបាល[23]។

ក្របខ័ណ្ឌច្បាប់គាំទ្រពាណិជ្ជកម្មរបស់កម្ពុជា បានធ្វើឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព នៅក្នុងរយៈពេលជាងមួយទស្សវត្សចុងក្រោយនេះ។ អតីតឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា លោក William Todd (ឆ្នាំ ២០១៥) បានសរសេរថា "... មិនដូចជាប្រទេសផ្សេងទៀតនៅក្នុងតំបន់ ក្រុមហ៊ុនបរទេសនៅកម្ពុជា អាចធ្វើជាម្ចាស់ក្រុមហ៊ុនរបស់ខ្លួន ១០០% មានភាពងាយស្រួលក្នុងការផ្ទេរប្រាក់ចំណេញទៅប្រទេសកំណើតរបស់ខ្លួន បង់ពន្ធក្រុមហ៊ុនទាបបំផុតក្នុងចំណោមបណ្តាប្រទេសនៅសហគមអាស៊ាន និងទទួលបាននូវការលើកលែង ពន្ធក្នុងរយៈពេលវែងជាងបណ្តាប្រទេសនានា ក្នុងសហគមន៍អាស៊ាន ព្រមជាមួយនឹងការលើកទឹកចិត្តសារពើពន្ធ

[22] បុគ្គលិកវិស័យឯកជន ០១ ត្រូវបានសម្ភាស នៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥ នៅរាជធានីភ្នំពេញ។

[23] បុគ្គលិកវិស័យឯកជន ០៣ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥។

សប្បុរស (សប្បុរសខ្លាំង) (Hill និង Menon ឆ្នាំ២០១៣)។ កម្ពុជាត្រូវបន្តអប់រំវិនិយោគិនអំពីឱកាសនានានៅក្នុងប្រទេសនេះ៉។ លោកក៏បានលើកឡើងអំពីកិច្ចប្រឹងប្រែងបច្ចុប្បន្នរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់អំពើពុករលួយក្នុងវិស័យធុរកិច្ច តាមរយៈការចុះបញ្ជីពាណិជ្ជកម្មស្វ័យប្រវត្តិ និងការជ្រើសរើសបុគ្គលិកបើកចំហររបស់រដ្ឋនៅក្រសួងពាណិជ្ជកម្ម។

សរុបមក ទស្សនវិស័យនៃការអភិវឌ្ឍវិស័យឯកជន មិនសូវមានលក្ខណៈប្រសើរប៉ុន្មានទេ។ ទោះជាយ៉ាងណា ប្រសិនបើនៅតែមានស្ថេរភាព និងផ្អែកលើតួនាទី និងការប្តេជ្ញាចិត្តគាំទ្ររបស់រដ្ឋាភិបាល ទស្សនវិស័យនេះ អាចមានផលវិជ្ជមាន ដោយរួមចំណែកដល់កំណើនជាមធ្យម។ ដូច្នេះកំណើននេះនឹងសម្របសម្រួលឱ្យកម្ពុជាសម្រេចបាននូវ SDGs។

## ជំនួយអភិវឌ្ឍផ្លូវការ (ODA)

កម្ពុជាត្រូវបានចាត់ទុកជាក្រុមប្រទេសពឹងផ្អែកច្រើនលើជំនួយ ទន្ទឹមនឹងនេះ ក៏ជាប្រទេសត្រូវបានផ្តល់ជំនួយច្រើនផងដែរ[24]។ កម្ពុជាទទួលបានថវិកាពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ចំនួន ៨០% ក្នុងនោះជិត ១៥% ត្រូវបានអនុវត្តដោយ NGOs (CDC ឆ្នាំ២០១៤)។ ទាក់ទងនឹងនិន្នាការជំនួយអភិវឌ្ឍន៍ផ្លូវការ CDC (ឆ្នាំ ២០១៤) ផ្តល់នូវការបកស្រាយដូចខាងក្រោម។ ការចំណាយផ្នែកជំនួយសម្រាប់អភិវឌ្ឍ បានកើនឡើងពី ១,៤៦ ប៊ីលានដុល្លារ នៅក្នុងឆ្នាំ ២០១៣ (សូមមើលលេខក្នុងតារាងខាងក្រោម)។ រវាងឆ្នាំ ២០០៤ និងឆ្នាំ២០១៣ សមាសភាពកំណើនពីមួយឆ្នាំទៅមួយឆ្នាំក្នុងអត្រា ១១,៤%[25]។ ប្រការគួរឱ្យកត់សម្គាល់គឺជំនួយឥតសំណងខាងក្រៅ (ការបញ្ចូលគ្នារវាង ODA និងNGO) នៅតែមិនមានការផ្លាស់ប្តូរនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ សម្រាប់ហិរញ្ញប្បទានកម្ចីផ្តល់សម្បទាន។ ជាលើកដំបូងនៅឆ្នាំ ២០១៣ កម្ចីផ្តល់សម្បទានមានទំហំធំជាងជំនួយឥតសំណងសម្រាប់អភិវឌ្ឍ។ នេះគឺជានិន្នាការដែលត្រូវបានទស្សន៍ទាយថា នឹងបន្តកើតមាននៅក្នុងឆ្នាំ ២០១៤ និងឆ្នាំបន្តបន្ទាប់។ នេះដោយសារតែ កម្ពុជាកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាបប្រភពឥណទានធំៗ ដែលជាជំនួយសម្រាប់អភិវឌ្ឍ បានផ្លាស់ប្តូរពីជំនួយឥតសំណងទៅជាកម្ចីផ្តល់សម្បទាន។

---

[24] ជំនួយក្នុងមនុស្សម្នាក់បានកើនឡើងពី ៣១$ ក្នុងឆ្នាំ ២០០០ ដល់ ៣៨ដុល្លារ ក្នុងឆ្នាំ ២០០៥ ដែលចំនួននេះច្រើនជាងចំនួនមធ្យមទ្វេដងសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាបត្រឹម១៧$ ក្នុងឆ្នាំ ២០០៥។ ជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលជាផ្នែកមួយនៃចំណូលជាតិសរុប ក៏បានធ្លាក់ចុះពី ១១,២% ក្នុងឆ្នាំ២០០០ ដល់ ៩,១% ក្នុងឆ្នាំ២០០៥ នៅកម្ពុជា ពីព្រោះកំណើនសេដ្ឋកិច្ចកើនឡើងខ្ពស់។ ទោះជាយ៉ាងណា តួលេខនេះ នៅតែខ្ពស់ជាមធ្យមភាគនៃប្រទេសដែលមានប្រាក់ចំណូលទាបត្រឹម ២,៩% នៅក្នុងឆ្នាំ ២០០៥ (Ek & Sok ឆ្នាំ ២០០៨) ។

[25] ទោះជាយ៉ាងណា នៅឆ្នាំ ២០១៣ មានការធ្លាក់ចុះចំណាយប្រចាំឆ្នាំជាលើកដំបូង។

### រូបភាព ៦ ៖ ចំណាយ និងការទស្សន៍ទាយ ឆ្នាំ ២០០៤-២០០៦ (ទី១) និងនិន្នាការសំខាន់ៗ (ទី២)




*(Note that all data reported in this paper was extracted from the ODA and NGO Databases on 7 March 2014)*

ប្រភព ៖ (CDC ឆ្នាំ ២០១៤)

ពេលកម្ពុជាទទួលបានឈ្មោះជាប្រទេសចំណូលមធ្យមកម្រិតទាប ដែលធនាគារពិភពលោកនឹងប្រកាសជាផ្លូវការនៅខែកក្កដា ឆ្នាំ២០១៦ (WB ឆ្នាំ២០១៥ មើលឧបសម្ព័ន្ធ៣) មានការព្រួយបារម្ភអំពីការធ្លាក់ចុះហិរញ្ញប្បទានខាងក្រៅសម្រាប់កម្ពុជា ជាលទ្ធផលនឹងប៉ះពាល់ដល់ទស្សនវិស័យរបស់កម្ពុជាក្នុងការសម្រេចបាន SDG។ ផ្អែកលើការពិភាក្សាខាងលើ និងការទស្សន៍ទាយខាងក្រោមនិន្នាការនេះ គឺមិនសូវគួរឱ្យមានការព្រួយបារម្ភប៉ុន្មានទេ[26]។

ទី១ របៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ នឹងគិតគូរច្រើនទៅលើសមត្ថភាពក្នុងស្រុក ដើម្បីបង្កើតចំណូលផ្ទាល់ខ្លួន។ ដូចបានរៀបរាប់ខាងលើ សមត្ថភាពផ្នែកពន្ធដាររបស់កម្ពុជា មានភាពប្រសើរឡើង ហើយចំណូលពន្ធក្នុងស្រុកធៀបនឹង ផសស បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយនឹងទំនងជាកើនឡើងជាលំដាប់។

ទី២ ខណៈដែលម្ចាស់ជំនួយមួយចំនួនដូចជា Danida និងDFID បានដកខ្លួនចេញម្ចាស់ជំនួយផ្សេងទៀតដូចជា EU នឹងនៅតែបន្តផ្តល់ជំនួយ ពីព្រោះប្រទេសមួយចំនួនរួមមាន កម្ពុជា ជាករណីពិសេស ដែលជំនួយអភិវឌ្ឍន៍ផ្លូវការនៅតែបន្តផ្តល់ ឧទាហរណ៍ ដោយសារភាពក្រីក្រ និងជំងឺនានា នៅតែកើតមាន ហើយការគាំទ្រខាងក្រៅនៅតែផ្តោតលើតំបន់ទាំងនេះ។ មជ្ឈមណ្ឌល

[26] បុគ្គលិកធនាគារអភិវឌ្ឍន៍ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៥ បុគ្គលិកអង្គការសហប្រជាជាតិម្នាក់ ត្រូវបានសម្ភាសនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ នៅរាជធានីភ្នំពេញ។

អភិវឌ្ឍន៍ជាសាកល ជាវិទ្យាស្ថានស្រាវជ្រាវដ៏ធំ ដែលធ្វើការស្រាវជ្រាវលើការអភិវឌ្ឍ ទស្សន៍ទាយថា ចំនួនប្រទេសចំណូលទាប (LICs) នឹងធ្លាក់ចុះច្រើន។ ត្រឹមឆ្នាំ ២០២៥ ប្រទេសចំណូលទាបនឹងនៅសល់ប្រហែលជា ២០ ប្រទេសប៉ុណ្ណោះ (ភាគច្រើនជាប្រទេសដែលមានវិបត្តិសេដ្ឋកិច្ច និងនយោបាយ) (Sumner & Glassman ឆ្នាំ២០១២)។ កម្ពុជានឹងមិនស្ថិតនៅក្នុងចំណោមប្រទេសទាំង ២០ នេះទេ ពីព្រោះកម្ពុជានឹងឈានទៅ ១ កម្រិតទៀត នៅឆ្នាំក្រោយនេះ (WB ឆ្នាំ ២០១៥)។ ម្ចាស់ជំនួយនៅក្នុងអន្តរកាលអភិវឌ្ឍន៍នឹងគាំទ្រទាំង ប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យម (MICs) ប៉ុន្តែ ប្រើប្រាស់វិធីសាស្ត្រប្រកបដោយភាពជាក់លាក់ (Sumner & Glassman ឆ្នាំ ២០១២)។ សម្រាប់ ប្រទេសចំណូលមធ្យម នឹងផ្តល់បានការគាំទ្រពីរប្រភេទ។ ទី១ គឺការគាំទ្រដែលផ្តោតលើតំបន់ចំណូលទាប (មានន័យថា ប្រទេសដែលមានភាពក្រីក្រថ្មី និងខ្វះអាហារូបត្ថម្ភ គឺជាគោលដៅនៃការគាំទ្រ) នៅក្នុងប្រទេសចំណូលមធ្យមទាំងនោះ (ibid)។ ទី២ គឺការផ្តល់ការគាំទ្រដើម្បីប្រយុទ្ធប្រឆាំងជំងឺ និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសចំណូលមធ្យមទាំងនោះ។ ទាំងនេះ បង្ហាញពីមូលហេតុដែលចិន និងឥណ្ឌានៅតែទទួលបានជំនួយ ពីព្រោះប្រជាជនដែលរស់នៅក្នុងភាពក្រីក្រត្រូវការជំនួយខាងក្រៅ។ ម្ចាស់ជំនួយដ៏មានសក្តានុពល (នៅក្នុងក្រុមនេះ) គឺ EU។ EU ដែលនឹង/បានបិទការិយាល័យរបស់ខ្លួននៅប្រទេសឥណ្ឌូនេស៊ី ថៃ និងឥណ្ឌា បានលើកឡើងថា ខ្លួនអាចបង្កើនជំនួយដល់កម្ពុជាច្រើនជាងនេះ ពីរដង ឬបីដង អាស្រ័យលើការអនុវត្តរបស់កម្ពុជាដូចជា ការបង្កើនប្រជាធិបតេយ្យ និងអភិបាលកិច្ច នោះជំនួយនឹងមានកាន់តែច្រើន[27]។ ដូចបានរៀបរាប់ខាងលើ គេរំពឹងថា អភិបាលកិច្ចប្រកបដោយគុណភាព នឹងមានភាពប្រសើរឡើងជាបន្តបន្ទាប់ ដូច្នេះកម្ពុជាអាចឆ្លើយតបនឹងលក្ខខណ្ឌនានា របស់ម្ចាស់ជំនួយដូចជា EU។

ទី៣ នៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល បានដើរតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍទាក់ទងនឹងការបញ្ជូនសេវាកម្ម និងការប្រមូលធនធាន ជាពិសេសចាប់តាំងពីដើមទស្សវត្សរ៍ឆ្នាំ ១៩៩០។ ជំរឿនអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០១២ បានបង្ហាញថា មានអង្គការមិនមែនរដ្ឋាភិបាល ដែលសកម្មចំនួន ១.៣១៥ (៦៧០ អង្គការក្នុងស្រុក និង ៣២១ អង្គការអន្តរជាតិ និង ៣២៥ ជាសមាគម)។ ចំនួន ៨៥,៩% នៃអង្គការដែលបានចុះបញ្ជីទាំងអស់ បានទទួលមូលនិធិជាក់ឱ្យដំណើរការ [យ៉ាងហោចណាស់] គម្រោងមួយ នៅក្នុងឆ្នាំ ២០១២ (CCC ឆ្នាំ២០១៣) ដោយដំណើរការជាង ៤.០០០ គម្រោង និងផ្តល់អត្ថប្រយោជន៍ឱ្យមនុស្សជាង ១,៣ លាននាក់ នៅក្នុងវិស័យអប់រំ សុខាភិបាល និងកសិកម្ម ដោយប្រើប្រាស់ថវិកា ៦០០-៧០០ លានដុល្លារ និងផ្តល់ការងារផ្ទាល់ដល់មនុស្សយ៉ាងហោចណាស់ ៤៣.០០០ នាក់ (CCC ឆ្នាំ២០១៣)។

---

[27] អ្នកសិក្សាស្រាវជ្រាវម្នាក់ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥។ បើទោះជាគេកំពុងតែរង់ចាំមើលថាតើ EU នឹងធ្វើសកម្មភាពដូចអ្នករាយការណ៍បង្កើបប្រាប់ឬអត់នោះ ជាទូទៅដូចបានលើកឡើងរួចមកហើយ ដៃគូអភិវឌ្ឍន៍ នឹងមិនទំនងជាបោះបង់ចោលកម្ពុជាទាំងស្រុង និងភ្លាមៗបែបនេះទេ។

មូលនិធិសរុបរបស់ អង្គការមិនមែនរដ្ឋាភិបាល បានកើនឡើងបួនដងរវាងឆ្នាំ២០០៦ និងឆ្នាំ ២០១៣ ចាប់ពី ៥០ លានដុល្លារអាមេរិក រហូតដល់ ២០០ លានដុល្លារអាមេរិក។ អំឡុងរយៈពេល បីឆ្នាំ រវាងឆ្នាំ ២០១១-២០១៣ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៣៨ បានចុះបញ្ជីគម្រោងអនុវត្ត។ ទាក់ទងនឹងមូលនិធិផ្ទាល់ខ្លួនវិញ អង្គការ ២៤ ក្នុងចំណោម អង្គការទាំងនេះ មានសកម្មភាពផ្នែក ហិរញ្ញវត្ថុ ៥០% សម្រាប់អង្គការសរុប រីឯ ៥០% ផ្សេងទៀត គឺជាត្រូវបានបែងចែកក្នុងចំណោម អង្គការ ៥១៥ ផ្សេងទៀត (CDC ឆ្នាំ២០១៤)។ ការគាំទ្រពីដៃគូអភិវឌ្ឍ សម្រាប់អង្គការ ដែលបន្ថែម ពីលើមូលនិធិផ្ទាល់ខ្លួនរបស់ពួកគេ មានចំនួនទឹកប្រាក់ប្រហែល ៩០ លានដុល្លារ ក្នុងមួយឆ្នាំ អំឡុង ឆ្នាំ ២០១១-២០១៣ ភាគច្រើនគឺធ្វើការសំដៅ វិស័យសុខាភិបាល/HIV អភិបាលកិច្ច បរិស្ថាន និង កសិកម្ម។ សហរដ្ឋអាមេរិក និងសហគមអឺរ៉ុប ជាម្ចាស់ជំនួយធំបំផុតរបស់អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងនឹងប្រាក់ដុល្លារ និងភាគរយនៃហិរញ្ញប្បទាន។ ចំណាយប្រចាំឆ្នាំជាមធ្យមរបស់អាមេរិក ស្មើនឹង ៦០ លានដុល្លារ ឬ ៨៦% នៃមូលនិធិសរុប និងសហគមអឺរ៉ុប ស្មើនឹង ១១,៥ ដុល្លារ ឬ២២% នៃឥណទានសរុបនៅកម្ពុជា អំឡុងឆ្នាំ ២០១១-២០១៣។ ម្ចាស់ជំនួយធំៗ ផ្សេងទៀតរបស់ NGO គឺ ជប៉ុន ដែលផ្តល់ ៤,២ លានដុល្លារជារៀងរាល់ឆ្នាំ ឬ ៣% នៃមូលនិធិសរុប និងទីភ្នាក់ងារអង្គការ សហប្រជាជាតិ ៣,៥ លានដុល្លារ ឬ៦% នៃមូលនិធិសរុប (CDC ឆ្នាំ២០១៤) ។

ទោះបីជាមានការព្រួយបារម្ភថា មូលនិធិខាងក្រៅដែលផ្តល់ឱ្យកម្ពុជា និង NGO អាចនឹងថយ ចុះក្តី នៅពេលកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប ការកាត់បន្ថយមូលនិធិរបស់ NGO អាចនឹងមិនមានចំនួនច្រើនក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមទេ ដោយសារមូលហេតុមួយចំនួន។ ទី១ កិច្ចពិភាក្សាកន្លងមក បានស្នើថា ម្ចាស់ជំនួយមួយចំនួន ដូចជា EU នឹងត្រូវនៅប្រទេសកម្ពុជា។ ទី២ និន្នាការពិភពលោកជាទូទៅ ចង្អុលបង្ហាញថា NGOs និងជំនួយ នឹងនៅតែមានសារៈសំខាន់ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ប្រយុទ្ធប្រឆាំងជំងឺ និងការបញ្ជូនសេវាកម្ម នៅក្នុងតំបន់ និង ប្រជាជនគោលដៅ។ ទី៣ ដូចបានរៀបរាប់ខាងលើ បើទោះជាភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាង ខ្លាំង នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រជាជនជាច្រើននឹងរស់នៅជិតខ្សែបន្ទាត់ ភាពក្រីក្រ និងស្ថិតនៅក្នុងភាពងាយរងគ្រោះ។ ទី៤ ខណៈដែលប្រឈមនឹងការធ្លាក់ចុះមូលនិធិ អង្គការមិនមែនរដ្ឋាភិបាលអាចពុះពារធ្វើការសម្របសម្រួលកាន់តែប្រសើរ និងកាត់បន្ថយគម្រោង ឬ កម្មវិធីដែលជាន់គ្នា ដែលជាតថភាពនៅក្នុងប្រតិបត្តិការជាសាកលរបស់អង្គការមិនមែនរដ្ឋាភិបាល។

**រូបភាព ៧ ៖ (ខាងឆ្វេង) ការគាំទ្ររបស់វិស័យ NGO ឆ្នាំ ២០១៣ និង (ខាងស្តាំ) មូលនិធិដែលពាក់ព័ន្ធនៃការងាររបស់ NGOs ឆ្នាំ ២០១១-២០១៣**




ប្រភព ៖ CDC ឆ្នាំ ២០១៤ ទំព័រ ៧

ទី៤ (ទាក់ទងនឹងកម្ចីផ្តល់សម្បទានជាច្រើន) ហិរញ្ញប្បទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិគឺជាប្រភពដ៏ប្រសើរសម្រាប់ប្រទេសចំណូលមធ្យមកម្រិតទាប ជាមួយនឹងសមត្ថភាពចំណាយកាន់តែច្រើន[28]។ ខណៈដែលកម្ពុជាកំពុងមានសមត្ថភាពកើនឡើង និន្នាការជំនួយអភិវឌ្ឍន៍ផ្លូវការបានផ្លាស់ប្តូរពីជំនួយឥតសំណង ទៅជាឥណទាន ហើយនិន្នាការនេះ នឹងនៅតែបន្ត ដូច្នេះ កម្ចីនឹងមានកំណើន។ លើសពីនេះ ទំនាក់ទំនងរវាងដៃគូអភិវឌ្ឍន៍មួយចំនួន និងកម្ពុជា នឹងផ្លាស់ប្តូរពីម្ចាស់ជំនួយទ្វេភាគីទៅជាដៃគូធុរកិច្ច/ដៃគូពាណិជ្ជកម្ម ក្រោមលក្ខខណ្ឌដូចគ្នា ហើយការវិនិយោគផ្ទាល់ពីបរទេស នឹងកាន់តែមានសារៈសំខាន់នៅក្នុងដំណើរការនេះ[29]។ ដូចគ្នានេះដែរ ធនាគារអភិវឌ្ឍន៍វិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីបច្ចុប្បន្នកំពុងដំណើរការ (ចូលរួមដោយបណ្តាប្រទេសធំៗទាំងអស់លើកលែងសហរដ្ឋអាមេរិក និងជប៉ុន)។ ដូច្នេះ មានកម្ចីជាសម្បទានមានច្រើនសម្រាប់ប្រទេសដូចកម្ពុជា។ លើសពីនេះ ដំណើរដ៏សកម្មនៅក្នុងតំបន់នេះអាចរក្សាការគាំទ្រប្រទេសកម្ពុជា។ តថភាពដែលចិន និងជប៉ុនកំពុងប្រកួតប្រជែងគ្នានៅក្នុងតំបន់ (សម្រាប់ឥទ្ធិពល) ផ្តល់ឱ្យកម្ពុជានូវអានុភាពក្នុងការទាក់ទាញជំនួយបន្ថែម។ ជាមួយគ្នានេះផងដែរ ខណៈដែលកម្ពុជាងាកទៅរកចិនច្រើនជាងវៀតណាមនោះ (ដូចបានបង្ហាញចាប់ពីពេលកម្ពុជាធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ានកាលពីពីរបីឆ្នាំមុន និងមានគោលជំហរលម្អៀង ដោយគាំទ្រចិនទាក់ទងនឹងបញ្ហាប្រជុំកោះស្ប្រាតលី ចិនបានផ្តល់ជំនួយឱ្យកម្ពុជាកាន់តែច្រើន ហើយនិន្នាការនេះ អាចនៅតែបន្ត។

[28] បុគ្គលិកធានាគារអភិវឌ្ឍន៍ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៥។

[29] វិស័យអភិវឌ្ឍន៍ ត្រូវបានសម្ភាសនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ រាជធានីភ្នំពេញ។

## SDGs កម្ពុជា (CSDGs) ៖ សមាសភាពសំខាន់ៗ និងអនុសាសន៍

SDGs គឺជាគោលដៅមហិច្ឆតាខ្ពស់ ដោយមានភាពតានតឹង និងចំរូងចំរាស់គ្នា ប្រសិនបើមើលពីទស្សនវិស័យរបស់កម្ពុជា ដូចមានបង្ហាញនៅក្នុងការវិភាគខាងលើ។ ដូច្នេះ ចំពោះកម្ពុជា សម្រាប់អ្វីដែលធ្លាប់ធ្វើលើ CMDGs អាចជាការត្រួសត្រាយផ្លូវសម្រាប់ធ្វើមូលដ្ឋានីយកម្មក្នុងបរិបទប្រទេសរបស់ខ្លួន។ សេណារីយ៉ូខាងក្រោម ដែលបានស្នើឡើង អាចយកមកពិចារណាយ៉ាងម៉ត់ចត់។

ទី ១ **គោលដៅដែលមិនសម្រេចបានតាមការគ្រោងទុក ចាំបាច់ត្រូវតែសម្រេចឱ្យទាល់តែបានដោយប្រើប្រាស់ការណែនាំប្រៀបធៀបរបស់ SDGs** ក្នុងនោះរួមមាន ៖

គោលដៅ ១ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ ទាំងអស់នៅគ្រប់ទីកន្លែង។

គោលដៅ ២ បញ្ចប់ការស្រេកឃ្លាន សម្រេចបាននូវសុវត្ថិភាពចំណីអាហារ បង្កើនអាហារបំប៉ន និងលើកកម្ពស់និរន្តរភាពកសិកម្ម។

គោលដៅ ៣ ធានាបាននូវសុខភាពល្អ និងលើកកម្ពស់សុខមាលភាពសម្រាប់ទាំងអស់គ្នា និងគ្រប់វ័យទាំងអស់។

គោលដៅ ៤ ធានាបាននូវការអប់រំប្រកបដោយគុណភាព សមភាព និងមានការចូលរួម ក៏ដូចជាលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

គោលដៅ ៥ សម្រេចបាននូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីទាំងអស់។

គោលដៅ ១០ កាត់បន្ថយវិសមភាពនៅក្នុង និងក្នុងចំណោមប្រទេសនានា។

គោលដៅ ១៧ ពង្រឹងវិធីអនុវត្ត និងលើកកម្ពស់ភាពជាដៃគូជាសកលសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

ទោះបីជាគោលដៅ ១៧ របស់ SDG ស្រដៀងគ្នានឹងគោលដៅទី៨ របស់ CMDG ដែលរដ្ឋាភិបាលលើកឡើងថា ខ្លួនបានអនុវត្តហើយនោះ **ច្បាស់ណាស់ប្រទេសកម្ពុជាត្រូវការខំប្រឹងបន្ថែមទៀតសម្រាប់ភាពជាដៃគូនេះ ពីព្រោះកម្ពុជាត្រូវការធនធានខាងក្រៅច្រើនដើម្បីផ្ដល់មូលនិធិដល់ SDGs ដ៏មានមហិច្ឆតានេះ ។ ដូច្នេះ ប្រការសំខាន់នោះ គឺថា គោលដៅនេះត្រូវរាប់បញ្ចូល និងគូសបញ្ជាក់ឱ្យបានច្បាស់លាស់។ ក្រៅពីនេះ CMDG នៃការដោះមីន គឺមានសារៈសំខាន់ណាស់ ពីព្រោះវាបង្ហាញអំពីបញ្ហានៃការកាត់បន្ថយភាពក្រីក្រ និងការចូលរួម។**

ទី ២ គោលដៅ ១៦ នៃ SDGs ស្តីពី "ការលើកកម្ពស់សង្គមដែលមានសន្តិភាព និងការចូលរួម សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ផ្តល់នូវលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងកសាងស្ថាប័ន ដែលមានការបោះឆ្នោត គណនេយ្យភាព និងការចូលរួមនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ នឹងជាបញ្ហាប្រឈមសម្រាប់កម្ពុជា។ **ដូច្នេះ គោលដៅនេះ គួរតែមានការស្នើសុំបន្ធូរបន្ថយ។ ដូចបានរៀបរាប់យ៉ាងច្បាស់នៅក្នុងបញ្ហាប្រឈមខាងលើនេះ ការកសាងស្ថាប័នរឹងមាំ និងមិនមែនសម្រាប់បុគ្គលណាមួយ នៅក្នុងបរិបទកម្ពុជា (ក្នុងលក្ខណៈឆាប់រហ័ស) គឺនៅពុំទាន់មានការត្រៀមខ្លួនជាស្រេចក្នុងការប្រឈមនឹងហានិភ័យនៅឡើយទេ ហើយកម្ពុជាអាចធ្លាក់ខ្លួនទៅក្នុងអស្ថិរភាព ដែលជាលទ្ធផលនឹងបំផ្លាញសមិទ្ធផលដ៏កម្ររបស់ CMDGS និង SDGs ផ្សេងទៀត។ ការពន្យល់បន្ថែម គឺថាប្រសិទ្ធភាពក្នុងស្ថាប័ន គឺជាចំណុចសំខាន់សម្រាប់សន្តិភាព និងការភិវឌ្ឍប្រកបដោយនិរន្តរភាព។ ដូច្នេះ រដ្ឋាភិបាលត្រូវពន្លឿនការពង្រឹងស្ថាប័នតាមដែលអាចធ្វើទៅបាន ខណៈដែលស្វែងរកការយោគយល់ពីសហគមន៍អន្តរជាតិ ដែលល្បឿននៃដំណើរការនេះក៏មិនមានភាពប្រាកដប្រជាដូចគ្នា។**

១- ទី ៣ **កម្ពុជាត្រូវធ្វើការសិក្សាអំពីទំនាក់ទំនងរវាង SGDs ដទៃទៀត ដែលលើកឡើងផ្សេងៗគ្នា អំពីទំនាក់ទំនងរវាងនិរន្តរភាពបរិស្ថាន ទំនើបនីយកម្ម និងកំណើន។** កំណើនរបស់កម្ពុជាកន្លងមកនេះ បានពឹងផ្អែកលើវិស័យឧស្សាហកម្ម (ភាគច្រើន វាយនភណ្ឌ) សំណង់ និងទេសចរណ៍។ ឧទាហរណ៍ ទោះបីជាការពិភាក្សាមុននេះ លើកឡើងអំពីទំនាក់ទំនងរវាងការកាប់បំផ្លាញព្រៃឈើ (សម្រាប់សម្បទានដីសេដ្ឋកិច្ច នៅតំបន់ជាច្រើន) និងការអភិវឌ្ឍកសិកម្ម និងកំណើនសេដ្ឋកិច្ច ទំហំនៃការវិនាសហិនហោចនេះតម្រូវឱ្យមានការស៊ើបអង្កេតបែបវិទ្យាសាស្ត្រ។ លើសពីនេះ មិនមានការសិក្សាម៉ត់ចត់លើទំនាក់ទំនងរវាងសរសេរស្តម្ភផ្សេងទៀត នៃកំណើនដូចជា ឧស្សាហកម្ម សំណង់ និងទេសចរណ៍ ក៏ដូចជាការបំពុលបរិស្ថាននៅឡើយទេ។ **ប្រសិនបើគ្មានការរកឃើញបែបវិទ្យាសាស្ត្រទេនោះ កម្ពុជាប្រឈមនឹងការយល់ស្របនឹងចក្ខុវិស័យរបស់ SDGs ដែលធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត ដូចបានលើកឡើងពីខាងដើមនៃរបាយការណ៍នេះ SDG គឺធំទូលាយ និងមានគោលដៅច្រើន ដែលគោលដៅមួយចំនួនគឺមិនសូវមានភាពពាក់ព័ន្ធទេ ហើយក៏មិនមែនជាអាទិភាពបន្ទាន់ឡើយ។ តាមការស្រាវជ្រាវ នៅថ្ងៃអនាគត កម្ពុជាអាចធ្វើឱ្យ SDGs មានលក្ខណៈសមស្របតាមបរិបទក្នុងប្រទេស ដោយត្រូវបោះបង់ចោលគោលដៅមិនពាក់ព័ន្ធមួយចំនួន[30]។**

[30] ការណែនាំនេះ ត្រូវបានគាំទ្រដោយអ្នកចូលរួមមួយចំនួននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់។

គោលដៅ ៦ ធានាវត្តមានទឹក និងការគ្រប់គ្រងទឹក និងអនាម័យដោយនិរន្តរភាពសម្រាប់មនុស្សគ្រប់រូប។

គោលដៅ ៧ ធានាឲ្យមានការទទួលបានថាមពល ក្នុងតម្លៃដែលអាចជាវបាន ជឿទុកចិត្តបាន មាននិរន្តរភាព និងទំនើបសម្រាប់មនុស្សគ្រប់រូប។

គោលដៅ ៨ លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព មុខរបរពេញលេញ និងដែលផ្តល់ផល និងការងារសមរម្យសម្រាប់មនុស្សគ្រប់រូប។

គោលដៅ ៩ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ លើកម្ពស់ឧស្សាហូបនីយកម្មជាបរិយាប័ន្ន និងដែលមាននិរន្តរភាព និងលើកស្ទួយនវានុវត្តន៍

គោលដៅ ១១ ធ្វើឱ្យទីក្រុង និងកន្លែងតាំងលំនៅដ្ឋានរបស់មនុស្សមានលក្ខណៈបរិយាប័ន្នសុវត្ថិភាព ធន់ និងមាននិរន្តរភាព។

គោលដៅ ១២ ធានាឲ្យមានការប្រើប្រាស់ និងផលិតកម្មតាមទម្រង់ដែលមាននិរន្តរភាព។

គោលដៅ ១៣ ចាត់វិធានការជាបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ *

គោលដៅ ១៤ អភិរក្ស និងប្រើប្រាស់មហាសាគរ សមុទ្រ និងធនធានសមុទ្រដោយនិរន្តរភាពសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាព

គោលដៅ ១៥ ការពារ ស្តារ និងជម្រុញការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីផែនដីដោយនិរន្តរភាព គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការប្រយុទ្ធប្រឆាំងនឹងឱនភាពដី និងបញ្ឈប់ ព្រមទាំងបង្វែរទិសនៃការរិចរឹលគុណភាពដី និងបញ្ឈប់ការបាត់បង់ជីវៈចម្រុះ។

**អនុសាសន៍ដែលអាចអនុវត្តផ្សេងទៀត រួមមានដូចខាងក្រោម៖**

២- ការផ្តល់ហិរញ្ញប្បទានដល់ SDG គឺជាអាទិភាពចម្បង។ ឧទាហរណ៍ ទោះបីជា រដ្ឋាភិបាលកំពុងធ្វើការយ៉ាងសស្រាក់សស្រាំ ក្នុងការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស តាមរយៈការបង្កើតគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម និងគោលនយោបាយផ្សេងទៀត ដើម្បីជួយសហគ្រាសខ្នាតតូច និងមធ្យមក៏ដោយ តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការកៀរគរជំនួយដើម្បីសម្រេចបាននូវគោលដៅ ០,៧% នៃសន្ទស្សន៍កំណើនផលទុនជាតិ គឺត្រូវបានលើកទឹកចិត្ត ដើម្បីឱ្យប្រទេសកម្ពុជាអាចមានមូលដ្ឋានហិរញ្ញវត្ថុរឹងមាំក្នុងការអនុវត្ត និងសម្រេចបាននូវ SDGs។

៣- រដ្ឋាភិបាលបានបញ្ជ្រាប CMDGs ទៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងបានធ្វើការប្តេជ្ញាចិត្តគួរឱ្យកត់សម្គាល់ក្នុងការសម្រេចគោលដៅសហសវត្សរ៍។ រដ្ឋាភិបាលអាច

អនុវត្តបានយ៉ាងល្អ នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបន្ទាប់។ ចំណុចកន្លងមក ដែលរដ្ឋាភិបាល មិនបានអនុវត្តដើម្បីសម្រេច CMDGs ហើយក៏អាចអនុវត្តនោះ គឺការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធ ដែលទីភ្នាក់ងាររដ្ឋាភិបាលសំខាន់ៗ ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងមហាផ្ទៃ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងតំណាងប្រជាពលរដ្ឋ អាចធ្វើការរួមគ្នាជាទៀងទាត់ ដើម្បីពិភាក្សា និងស្រាវជ្រាវពីវិធីដ៏មានសក្តានុពលក្នុងការសម្រេចបាននូវ SDGs។ វេទិកានេះ អាចមានសារៈសំខាន់ក្នុងការណែនាំអំពីការអនុវត្ត SDG ក៏ដូចជាការបន្តគណនេយ្យភាព។ ក្រៅពីវេទិកានេះគេក៏ចង់ (ជាពិសេសភាគីសង្គមស៊ីវិល) ឱ្យរដ្ឋាភិបាល ផ្តល់នូវបរិយាកាសអំណោយផល និងមានការលើកទឹកចិត្តដល់ភាគីអភិវឌ្ឍន៍ទាំងអស់ដើម្បីចូលរួមក្នុងការអនុវត្ត ការតាមដាន និងការវាយតម្លៃ SDGs។

៤- SDGs ដែលពាក់ព័ន្ធ អាចត្រូវបានបញ្ជ្រាបចូលទៅក្នុងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីអាជ្ញាធរថ្នាក់ក្រោមជាតិអាចប្រតិបត្តិតាម ដោយរួមចំណែកក្នុងការសម្រេចបាននូវ SGDs។

៥- រដ្ឋាភិបាលអាចបញ្ចូល SGDs ទៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្សេងៗ ដើម្បីភាគីពាក់ព័ន្ធអភិវឌ្ឍន៍សំខាន់ៗ ត្រូវបានរំឭកអំពី SDGs ដែលមានស្រាប់ និងអាចសម្រេចបាននូវគោលដៅទាំងអស់គ្នា។

៦- ដូចបានរៀបរាប់ខាងលើ SDGs និងគោលដៅនានា គឺមានលក្ខណៈធំធេង និងមហិច្ឆតាខ្ពស់។ ដូច្នេះ ការកសាងសមត្ថភាពពាក់ព័ន្ធនឹងការធ្វើការប្រកបដោយគុណភាព គឺត្រូវតែពង្រឹងបន្ថែម ជាពិសេសសម្រាប់មន្ត្រីពាក់ព័ន្ធនៅក្រសួងផែនការ។ ប្រការនេះ អាចនឹងជួយការងារតាមដាន និងវាយតម្លៃ។

៧- ទាក់ទងនឹង SGDs ដែលកំពុងលេចឡើង ច្បាប់ស្តីពីការគ្រប់គ្រងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងតថភាពដែលរដ្ឋាភិបាលខ្វះជំនឿចិត្ត និងឆន្ទៈក្នុងការបញ្ចូលអង្គការសង្គមស៊ីវិលនិងការខ្វះមូលនិធិសម្រាប់វិស័យនេះ CSOs គួរតែវាយតម្លៃឡើងវិញលើតួនាទីរបស់ខ្លួន និងបែបបទការងារនៅក្នុងការផ្លាស់ប្តូរបរិយាកាសថ្មី ដែលរដ្ឋាភិបាលផ្តល់ឱកាសនយោបាយតិចតួចសម្រាប់ CSOs។ អ្នកឆ្លើយតបតាមលក្ខណៈផ្តល់ប្រឹក្សាមួយរូប បានលើកឡើងថាជាធម្មតា CSOs បានវាយប្រហាររដ្ឋាភិបាល ជាជាងការស្នើឡើងនូវដំណោះស្រាយដែលអាចអនុវត្តទៅបាន និងដែលមានលក្ខណៈវិជ្ជមានសម្រាប់ការផ្លាស់ប្តូរ។ អាកប្បកិរិយា និងឥរិយាបថបែបនេះ អាចត្រូវបានផ្លាស់ប្តូរ ដែលការតស៊ូមតិក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ អាចបញ្ចូលទៅក្នុងការងារអភិវឌ្ឍន៍ (សម្រាប់សំណើលម្អិតស្តីពីបញ្ហានេះ សូមមើល Ou ឆ្នាំ

២០១៣ ឆ្នាំ២០១៥)។ វិធីសាស្រ្តដែលមានការសហការ និងការប្រឈមមុខតិចតួច ដោយ CSOs អាចនាំទៅរកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាង CSOs និង រដ្ឋាភិបាលនៅក្នុងក្រុមការងារបច្ចេកទេស (TWGs) និងលើសពីនេះទៅទៀត។ ផល វិជ្ជមាននេះបានកើតមានឡើងនៅប្រទេសវៀតណាម ក្នុងរយៈពេលពីរបីទសវត្សរ៍កន្លង មកនេះ (សូមមើល Wells-Dang ឆ្នាំ ២០១៤ នៅក្នុងកំណត់សម្គាល់)។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះ ព្យាយាមឆ្លើយតបនឹងសំណួរដ៏សំខាន់ថា តើកម្ពុជាត្រៀមខ្លួនជាស្រេចប៉ុណ្ណា ក្នុងការអនុវត្ត SDGs។ សេចក្តីសន្និដ្ឋានដ៏សំខាន់របស់យើង គឺកម្ពុជាបានបង្ហាញថា ខ្លួនមាន សមត្ថភាពជាច្រើន ដូចជា ការកៀរគរធនធាន មានចំណេះដឹងអំពីអ្វីដែលអាចទៅរួច និងអ្វីដែល មិនអាចទៅរួច (អាទិភាពត្រូវបានផ្តល់ឱ្យច្រើនទៅលើកំណើន និងតិចតួចលើអភិបាលកិច្ច) និងភាព ជាម្ចាស់កម្មសិទ្ធិលើរបៀបវារៈអភិវឌ្ឍន៍នៅក្នុងបរិបទនៃដៃគូអភិវឌ្ឍន៍ ដែលមានការប្រកួតប្រជែង និងមិនសូវមានការសម្របសម្រួល។ ដូច្នេះ កម្ពុជាមានជំហររឹងមាំ ក្នុងការអនុវត្ត SDGs ជាងកាលពី ១៥ ឆ្នាំមុន ដែលនៅពេលនោះ កម្ពុជាបានអនុវត្ត CMDGs។ បញ្ហាប្រឈមដ៏ចម្បងសម្រាប់កម្ពុជា គឺការចរចាជាមួយភាគីអន្តរជាតិ ដើម្បីស្វែងរកឱកាសនយោបាយ ដែលអនុញ្ញាតឱ្យរដ្ឋាភិបាល ប្រើប្រាស់ SDGs របស់កម្ពុជា សម្រាប់ការអនុវត្តនៅក្នុងបរិបទប្រទេសរបស់ខ្លួន ដែលមិនធ្វើឱ្យរាំង ខ្លាំងដល់កំណើន។

# ឯកសារយោង


ADB. (2013). Cambodia *Asian Development Outlook 2013 Asia's Energy Challenge*. The Philippines: The Asian Development Bank.

Aun, P. (2015) Remarks by Dr. AunPornmonirath, Minister of Economy and Finance, at 3rdInternational Conference on Financing for Development, "Time for Global Action", Addis Ababa, Ethiopia, 13-16 July 2015

Bailey, Peter( 2010?), Cambodia investment clime: macroeconomic environment and perceptions of manufacturing firm, pp. 43-68, available at http://www.ide.go.jp/English/Publish/Download/Brc/pdf/02_ch2.pdf

Biddulph, R. (2014). Can elite corruption be a legitimate Machiavellian tool in an unruly world? The case of post-conflict Cambodia. *Third World Quarterly, 35*(5), 872–887.

CCC. (2013). CSO Contributions to the Development of Cambodia 2012: Opportunities and Challenges. Phnom Penh: Cooperation Committee for Cambodia.

CDC. (2014). Development Cooperation Trends in Cambodia: Using Evidence to Promote Partnerships and Development Effectiveness. Phnom Penh: The Cambodian Rehabilitation and Development Board of the Council for the Development of Cambodia.

CDRI. (2013). Cambodia's Development Dynamics: Past Performance and Emerging Priorities Phnom Penh: Cambodia Development Resource Institute.

Dahles, Heidi, ASEAN Economic Community offers Cambodia a leg up, 11 February 2015, http://www.eastasiaforum.org/2015/02/11/asean-economic-community-offers-cambodia-a-leg-up/

Ek, C., & Sok, H. (2008). Aid Effectiveness in Cambodia (Vol. Working Paper 7): Wolfensohn Center for Development at Brookings.

Eyben, R., & Savage, L. (2013). Emerging and Submerging Powers: Imagined Geographies in the New Development Partnership at the Busan Fourth High Level Forum. *The Journal of Development Studies, 49*(4), 457-469.

Fukuyama, F. (2014). *Political order and political decay: from the industrial revolution to the globalization of democracy*. London: Profile Books.

Geoghegan, T. (2013). Post-2015: framing a new approach to sustainable development: 2015 Independent Research Forum.

Giry, S. (2015). Autopsy of a Cambodian Election: How Hun Sen Rules, *Essay September/October 2015 Issue AsiaSoutheast Asia* Retrieved from https://www.foreignaffairs.com/articles/asia/autopsy-cambodian-election

Gore, C. D., & Stoett, P. J. (2009). *Environmental Challenges and Opportunities: Local-Global perspectives on Canadian Issues*. Toronto: Emond Montgomery Publications Ltd.

Green, D., Hale, S., & Lockwood, M. (2012). How can a post-2015 agreement drive real change? *Oxfam Discussion Papers*: OXFAM.

Harfenist, E. (2015). Cambodia logs top spot, *The Phnom Penh Post*. Retrieved from http://www.phnompenhpost.com/national/cambodia-logs-top-spot

Hill, H., & Menon, J. (2013). Cambodia: Rapid Growth with Institutional Constraints *ADB Economics Working Paper Series*. Manila, Philippines: The Asian Development Bank.

Hing, Vutha.(2015) Cambodia Preparedness for ASEAN Economic Community 2015 and *Beyond*, CDRI, available at http://www.cdri.org.kh/webdata/policybrief/drf/SynthesisReport7.pdf

Hing, Vutha and Strange, Larry. (2015). "ASEAN Economic Community 2015: What Does it *Mean* for Cambodia's Economy and for Business?" *Cambodia Development Review* 19(1): 1-5

Hughes, C. (2009). *Dependent Communities: Aid and Politics in Cambodia and East Timor*. New York: Cornnell Southeast Asia Program.

NGOF. (2012). Guide to NGO Engagement in Aid Coordination in Cambodia. Phnom Penh: NGO Forum on Cambodia.

Nowaczyk, M. (2011) "Cambodia:  Implementing and Monitoring the Paris Declaration", in Brian Tomlinson (ed) *Democratic Ownership and Development Effectiveness: Civil Society Perspectives on Progress since Paris*, Quezon: Ibon Books (134-141)

OECD. (2012). *Aid Effectiveness 2011: Progress in Implementation the Paris Declaration, Better Aid*: OECD.

Ou, S. (2015). A Rights-Based Approach to Development: A Cambodian Perspective *Working Paper Series No. 101*. Phnom Penh: Cambodia Development Resource Institute.

Ou, S. (2013). Subnational Civil Society in Cambodia: A Gramscian Perspective *Working Paper Series No. 84*. Phnom Penh: Cambodia Development Resource Institute.

Pak, K. (2011). Accountability in Cambodia: Relevant Concepts and Their Application *Cambodia Development ReviewCAMBODIA DEVELOPMENT REVIEW VOLUME 15, ISSUE 1, JANUARY-MARCH 2011* (Vol. 15, Issue 1, January-March 2011). Phnom Penh: Cambodia Development Resource Institute.

Phy, S. (Producer). (2015, August 26, 2015). Interview with Sarah Milne, Co-Editor of "Conservation and Development in Cambodia: Exploring Frontiers of Change in Nature, State and Society". Retrieved from http://www.ncseas.com/interview-with-sarah-milne-co-editor-of-conservation-and-development-in-cambodia-exploring-frontiers-of-change-in-nature-state-and-society/

Pich, Rithi, AEC 2015: Benefits and Challenges for Cambodia, t the Seminar on "ASEAN Economic Community 2015", 16 September 2014, Phnom Penh, Cambodia, available at https://www.moc.gov.kh/tradeswap/userfiles/file/uploadedfiles/Gallery/4.%20Benefits%20and%20Challenges%20for%20Cambodia%20on%20AEC%2020159_16_2014_10_40_5.pdf

Ponce, A. (2015). World Justice Project Rule of Law Index. Washington: World Justice Project

RGC. (2013). Development Cooperation & Partnerships Strategy 2014 - 2018: Cambodian Rehabilitation and Development Board Council for the Development of Cambodia.

RGC. (2014a). Annual Progress Report 2013: Achieving Cambodia's Millenium Development Goals. Phnom Penh: Ministry of Planning, Royal Government of Cambodia.

RGC. (2014b). Cambodia Committed to Attain the Millennium Development Goals (MDGs). *Weekly Publication of the Royal Embassy of Cambodia to UK, Denmark, Finland, Ireland, Norway, Sweden, Ethiopia and African Union*.

Roberts, D. (2009). The Superficiality of Statebuilding in Cambodia: Patronage and Clientelism as Enduring Forms of Politics. In R. Paris & T. D. Sisk (Eds.), *The Dilemmas of Statebuilding: Confronting the Contradictions of Postwar Peace Operations*. London: Routledge.

Sachs, J. D. (2012). From Millennium Development Goals to Sustainable Development Goals. *Lancet, 379*, 2206-2211.

Saith, A. (2006). From universal values to millennium development goals: Lost in translation. *Development and change, 37*(6), 1167-1199.

Sato, J., Shiga, H., Kobayashi, T., & Kondoh, H. (2011). "Emerging Donors" from a Recipient Perspective: An Institutional Analysis of Foreign Aid in Cambodia. *World Development, 39*(12), 2091–2104.

Slocomb, M. (2010). *An Economic History of Cambodia in the Twentieth Century*. Singapore: NUS Press.

Sumner, A., & Glassman, A. (2012). Aid cuts to middle income countries worsen poverty and ill health, *The Guardian (UK)*. Retrieved from http://www.guardian.co.uk/global-development/povertymatters/2012/jan/02/aid-cuts-middle-income-countries

Todd, William E., ASEAN Integration: An Opportunity for Business in Cambodia, -11-Jan-15, http://www.thecambodiaherald.com/opinion/asean-integration:-an-opportunity-for-business-in-cambodia-1265

UN. (2015a). *The Millennium Development Goals Report 2015*. New York: The United Nations.

UN. (2015b). Transformation Our World: The 2030 Agenda for Sustainable Development, Outcome Document for the UN Summit to Adopt the Post-2015 Development Agenda: The United Nations.

Un, K., & Hughes, C. (2011). The Polical Economy of "Good Governance" Reform. In C. Hughes & K. Un (Eds.), *Cambodia's Economic Transformation*. Copenhagen: NIAS.

Vandemoortele, J. (2011). A fresh look at the MDGs. *Journal of the Asia Pacific Economy, 16*(4), 520-528.

WB. (2015). Maintaining High Growth: Cambodia Economic Update: Washington, DC.: The World Bank.

Zaum, D. (2013). Corruption and State-Building In D. Chandler & T. D. Sisk (Eds.), *Routledge Handbook of International Statebuilding*. London and New York: Routledge.

WB. (2014) *Doing business 2015: Go Beyond Efficiency, Economy Profile 2015 Cambodia*, 12th edition, Washington: World Bank Group.

WB. (2011) *Cambodia, More efficient Government Spending for Strong and Inclusive Growth, Integrated Fiduciary Assessment and Public Expenditure Review* (IFAPER), Washington, DC.: World Bank Group.

Wells-Dang, A. (2014). Civil Society Networks in Cambodia and Vietnam: A Comparative Analysis. In G. Waibel, J. Ehlert& H. N. Feuer (Eds.), *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*. London: Routledge.

## បញ្ជីឧបសម្ព័ន្ធ

### *ឧបសម្ព័ន្ធ ០១ ៖ បញ្ជីរាយឈ្មោះអ្នកផ្តល់បទសម្ភាសន៍*

សម្គាល់ ៖ ឈ្មោះ និងស្ថាប័ន ដែលពាក់ព័ន្ធនឹងអ្នកផ្តល់បទសម្ភាសគឺមិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះឡើយ ដើម្បីធានាបាននូវភាពអនាមិក។

១- មន្ត្រីរដ្ឋាភិបាលម្នាក់ ត្រូវបានសម្ភាសនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
២- បុគ្គលិកវិស័យឯកជនម្នាក់ ត្រូវបានសម្ភាសនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
៣- បុគ្គលិកវិស័យឯកជនពីរនាក់ ត្រូវបានសម្ភាសនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
៤- បុគ្គលិកវិស័យឯកជន បីនាក់ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១៥។
៥- បុគ្គលិកអង្គការសហប្រជាជាតិម្នាក់ ត្រូវបានសម្ភាសនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ រាជធានីភ្នំពេញ។
៦- បុគ្គលិកអង្គការសហប្រជាជាតិពីរនាក់ ត្រូវបានសម្ភាសនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
៧- បុគ្គលិកធានាគារអភិវឌ្ឍន៍ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៥។
៨- បុគ្គលិក NGO ម្នាក់ ត្រូវបានសម្ភាសនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
៩- បុគ្គលិក NGO (ទីប្រឹក្សា)ពីរនាក់ ត្រូវបានសម្ភាសនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
១០- បុគ្គលិក NGO បីនាក់ ត្រូវបានសម្ភាសនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
១១- អ្នកស្រាវជ្រាវ ម្នាក់ ត្រូវបានសម្ភាសតាម Skype នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។
១២- មន្ត្រីរដ្ឋាភិបាល ត្រូវបានសម្ភាសនៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១១ រាជធានីភ្នំពេញ[31]។

[31] យើងមានការលំបាកក្នុងការទទួលបានការអនុញ្ញាតសម្ភាសមន្ត្រីរដ្ឋាភិបាល ដោយសារអ្នកស្រាវជ្រាវ និងអ្នកផ្តល់បទសម្ភាសមានពេលវេលាតិចតួចពេក។ ដូច្នេះ ការសម្ភាសដែលពាក់ព័ន្ធសម្រាប់គម្រោងលើកមុនមួយផ្សេងទៀតត្រូវបានប្រើប្រាស់ជំនួស។

## ឧបសម្ព័ន្ធ ០២ ៖ សហគមសេដ្ឋកិច្ចអាស៊ាន និងការជាប់ទាក់ទងសម្រាប់កម្ពុជា

ប្រទេសក្រីក្រទាំងបួននៅក្នុងតំបន់នេះ (CLMV) នឹងទទួលបានផលប្រយោជន៍ពីការដាក់សម្ពាធលើកិច្ចប្រឹងប្រែងកំណែទម្រង់ និងសេរីភាព ដើម្បីបង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែង ហើយ សហគ្រាសធុនតូច និងមធ្យម នឹងក្រោកឈរឡើងដើម្បីទាញយកប្រយោជន៍ពីការចូលទៅកាន់ទីផ្សារកាន់តែធំជាងមុន ចំណាយទៅលើប្រតិបត្តិការ និងធាតុចូលកាន់តែតិច តាមរយៈការលុបបំបាត់របាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ ការសម្របសម្រួលពាណិជ្ជកម្ម និងការបង្កើនតំណរភ្ជាប់មធ្យោបាយដឹកជញ្ជូន (Pich ឆ្នាំ ២០១៤)។ ការពង្រឹងស្ថាប័ន ត្រូវតែមានល្បឿនស្របជាមួយការធ្វើសមាហរណកម្ម ជាពិសេសទាក់ទងនឹង បរិយាកាសវិនិយោគ ភ័ស្តុភារ និងនីតិវិធីពន្ធគយ ធនធានមនុស្ស ការបង្កើត និងការអនុវត្តគោលនយោបាយឧស្សាហកម្ម និងការចាត់ទុកកម្ពុជាជាប្រទេសគោលដៅសម្រាប់ការវិនិយោគ (Hing និង Strange ឆ្នាំ២០១៥ )។ បន្ថែមពីលើកិច្ចប្រឹងប្រែងកំណែទម្រង់ ក្នុងការកសាងមុខមាត់របស់កម្ពុជាក្នុងចំណោមវិនិយោគិនបរទេស កម្ពុជាគួរតែយល់ដឹងអំពីបរិយាកាសពាណិជ្ជកម្ម ដែលវិនិយោគិនចង់បាន (Todd ឆ្នាំ២០១៥)។ សេរីភាពពាណិជ្ជកម្ម ដែលត្រូវបានលើកកម្ពស់ដោយការធ្វើសមាហរណកម្ម អាចត្រូវបានមើលឃើញថាជាការគំរាមកំហែង និងកាលានុវត្តភាពស្របពេញជាមួយគ្នា។ ការភ័យខ្លាចក្នុងជួររដ្ឋាភិបាល មានដូចជា តាមរយៈកិច្ចព្រមព្រៀងជួញដូរទំនិញរបស់អាស៊ាន (ATGA) រដ្ឋជាសមាជិកអាស៊ានថ្មី (អាស៊ាន-៤) រួមមាន កម្ពុជា ពួកគេបានកាត់បន្ថយពន្ធគយឱ្យមកនៅត្រឹមកម្រិតខ្ពស់បំផុត ៥% និងបានប្តេជ្ញាចិត្តលុបបំបាត់ពន្ធនាំចូលត្រឹមឆ្នាំ ២០១៥ ដោយមានភាពបត់បែនមួយចំនួន រហូតដល់ឆ្នាំ ២០១៨ (Pich ឆ្នាំ២០១៤) ដែលមានន័យថា ជាការបាត់បង់ចំណូលសម្រាប់ប្រទេសនេះ។ ទន្ទឹមនឹងនេះ វាក៏ជាឱកាសផងដែរ ពីព្រោះការចូលដល់ទីផ្សារក្នុងតំបន់កាន់តែច្រើន នឹងធ្វើឱ្យកម្ពុជាដែលមានទីផ្សារក្នុងស្រុកតូច ប៉ុន្តែមានកម្លាំងពលកម្មថោក និងមានធនធានច្រើន ស្ថិតនៅក្នុងបញ្ជីប្រទេសគោលដៅសម្រាប់ការវិនិយោគ ដើម្បីចូលទៅកាន់ទីផ្សារក្នុងតំបន់ (Bailey ឆ្នាំ ២០១០)។

សម្រាប់កម្ពុជា ដើម្បីទាញយកផលចំណេញពីសមាហរណកម្មក្នុងតំបន់ ការពង្រឹងវិនិយោគក្នុងស្រុកដើម្បីរក្សាកំណើន ដែលខ្លួនសម្រេចបាននោះ គឺតម្រូវឱ្យមានកិច្ចប្រឹងប្រែងបន្ថែមទៀត ជាពិសេស ដើម្បីសម្រេចបាននូវកំណែទម្រង់ស្ថាប័ន។ ដើម្បីផ្លាស់ប្តូរកម្ពុជាឱ្យស្ថិតនៅក្នុងសង្វាក់តម្លៃនៅក្នុងតំបន់ និងជាសាកល កម្លាំងពលកម្មជំនាញដែលមានគុណភាព គឺត្រូវការជាចាំបាច់ និងពឹងផ្អែកទៅលើកំណែទម្រង់វិស័យអប់រំ ទាំងការអប់រំចំណេះដឹងទូទៅ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ (Pich ឆ្នាំ ២០១៤ Todd ឆ្នាំ ២០១៥ ADB & ILO ឆ្នាំ ២០១៤)។ គេគួរតែផ្តោតការយកចិត្តទុកដាក់លើស្តង់ដារប្រាក់ឈ្នួលនៅទូទាំងតំបន់ ការការពារសង្គមសម្រាប់កម្មករអន្តោប្រវេសន៍ និងអ្នកដែលធ្វើការងារងាយរងគ្រោះ កម្មករនៅក្នុងវិស័យអន់ថយ និងការគាំទ្រឧស្សាហកម្មធុនតូចទាំងអស់ (ADB & ILO ឆ្នាំ ២០១៤) ហេដ្ឋារចនាសម្ព័ន្ធ និងការគោរពស្តង់ដារពលកម្មអន្តរជាតិ ជាកត្តា

ដែលវិនិយោគិនជឿជាក់ថា នឹងរួមចំណែកដល់បរិយាកាសលំនឹងធុរកិច្ច (Todd ឆ្នាំ២០១៥)។ ទោះបីជាកំណែទម្រង់ស្ថាប័ននឹងទំនងជាប៉ះពាល់ដល់ការគ្រប់គ្រង និងរបៀបនៃការធ្វើជំនួញ ក្រុមអភិជនទាំងនោះក៏ទំនងជាត្រូវចំណាយច្រើនជាងមុន ប្រសិនបើមិនអនុវត្តតាម។ កំណែទម្រង់ស្ថាប័ននេះរួមមានការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការបែងចែកទ្រព្យសម្បត្តិ និងការកាន់កាប់កម្មសិទ្ធិដីធ្លី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកំណែទម្រង់ការអប់រំ។ ប្រវត្តិនៃការផ្តោតសំខាន់លើការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានអនុវត្ត ដែលបង្កឡើងអោយមានការខាតបង់លើពាណិជ្ជកម្មក្នុងស្រុក (Dahles ឆ្នាំ ២០១៥) ។

ស្របគ្នានេះ វិស័យពាណិជ្ជកម្មក្នុងស្រុកក៏ជួបប្រទះបញ្ហាប្រឈមជាច្រើន នៅក្នុងដំណើរការលូតលាស់ និងទាញយកប្រយោជន៍ពីសមាហរណកម្មក្នុងតំបន់។ បញ្ហាប្រឈមសំខាន់ៗ សម្រាប់វិស័យ SMEs ដែលរដ្ឋាភិបាលបានកត់សម្គាល់រួមមាន ៖ (១) ចំណាយកាតព្វកិច្ចប្បញ្ញត្តិកម្មខ្ពស់បណ្តាលមកពីច្បាប់ និងបទប្បញ្ញត្តិរបស់កម្ពុជានៅទន់ខ្សោយ ដែលបង្កើតជាភាពមិនច្បាស់លាស់ និងហានិភ័យ សម្រាប់ការចូលសមាហរណកម្ម (២) ខ្វះក្របខ័ណ្ឌច្បាស់លាស់ដែលផ្តោតលើទីផ្សារសម្រាប់ការអភិវឌ្ឍន៍ SME បើទោះបីត្រូវបានចាត់ទុកជាក្បាលម៉ាស៊ីនសម្រាប់កំណើនក្តី រដ្ឋាភិបាលមិនអាចបង្កើតក្របខ័ណ្ឌច្បាស់លាស់សម្រាប់កំណើនរបស់ខ្លួនបានទេ ដូច្នេះ ក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាល បង្កើតយុទ្ធសាស្រ្តផ្ទាល់ខ្លួនសម្រាប់ SMEs ដែលពេលខ្លះ ធ្វើឱ្យមានការជម្រុះបុគ្គលិក ហើយពេលខ្លះ ថែមទាំងមានជម្លោះទៀតផង (៣) លទ្ធភាពទទួលបានហិរញ្ញប្បទាននៅមានកម្រិត ធនាគារពាណិជ្ជក្នុងស្រុក ផ្តល់ឱ្យតែ ១% នៃទុនបង្វិល និង ១,៧% នៃទុនវិនិយោគ ទៅកាន់វិស័យ SME។ ធនាគារមានការលំបាកក្នុងការផ្តល់កម្ចីទៅឱ្យ SMEs ដោយសារហេដ្ឋារចនាសម្ព័ន្ធធនាគារទន់ខ្សោយ ដោយធ្វើឱ្យការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការទូទាត់ប្រាតិភោគ កាន់តែមិនប្រាកដប្រជា ខ្វះប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ និងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីវាយតម្លៃលើភាពគួរទទួលបានឥណទាន SME (IFC ឆ្នាំ ២០១០)។

### *ឧបសម្ព័ន្ធ ០៣ ៖ កម្ពុជាកំពុងប្រែក្លាយជាប្រទេសដែលមានចំណូលសេដ្ឋកិច្ចមធ្យមកម្រិតទាប ត្រឹមឆ្នាំ២០១៥*

**ធនាគារពិភពលោក ធ្វើការបែងចែកសេដ្ឋកិច្ច ដោយផ្អែកលើចំណូលជាតិសរុប (GNI) ក្នុងមនុស្សម្នាក់ នៃប្រទេសនីមួយៗ។** ចំណូលជាតិសរុប គឺជាតម្លៃទំនិញ និងសេវាសរុប ដែលបានផលិតក្នុងប្រទេសមួយ (ឧទាហរណ៍ ផលិតផលក្នុងស្រុកសរុប “GDP”) រួមទាំង ចំណូលបានមកពីប្រទេសដទៃទៀត (ជាពិសេស ចំណូលបានមកពីការយកមកវិញនូវផលចំណេញ និងប្រាក់ឈ្នួល) ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងចំណាយក្នុងប្រទេសដទៃទៀត ដែលរកបានក្នុងសេដ្ឋកិច្ចក្នុងស្រុក។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនកម្ពុជា ដែលមានប្រតិបត្តិការនៅបរទេស បញ្ជូនផលចំណេញមួយចំនួនរបស់ខ្លួនមកប្រទេសកម្ពុជា នោះនឹងធ្វើឱ្យ ចំណូលជាតិសរុប របស់កម្ពុជាកើនឡើង។ ចំណូលជាតិសរុប ត្រូវបានចាត់ទុកជាសូចនាករល្អបំផុតតែមួយនៃសមត្ថភាព និងកំណើនសេដ្ឋកិច្ច ទោះបីជាមានការទទួលស្គាល់ថា ចំណូលជាតិសរុប មិនអាចប្រើសម្រាប់វាយតម្លៃអំពីសុខុមាលភាព ឬ ភាពជោគជ័យក្នុងការអភិវឌ្ឍបានឡើយ។ ដូច្នេះ ចំណូលជាតិសរុប ក្នុងមនុស្សម្នាក់ គឺជាលក្ខណវិនិច្ឆ័យចម្បងរបស់ធនាគារពិភពលោក ប្រើប្រាស់សម្រាប់បែងចែក ប្រទេសនីមួយៗ ទៅក្នុងប្រភេទក្រុមចំណូលខុសៗគ្នា។

**សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ធនាគារពិភពលោកបានបង្កើតមាត្រដ្ឋាននៃប្រភេទក្រុមចំណូល** (តារាង ឧ១.១)។ ប្រទេសដែលមានចំណូលសេដ្ឋកិច្ចទាប គឺបណ្ដាប្រទេសដែលមាន GNI ក្នុងមនុស្សម្នាក់ (គណនាតាមវិធីសាស្រ្ត Atlas) ចំនួន ១.០៤៥ ដុល្លារអាមេរិក ឬ តិចជាងនេះ ក្នុងឆ្នាំ២០១៣ ប្រទេសដែលមានចំណូលសេដ្ឋកិច្ចទាបមធ្យម គឺបណ្ដាប្រទេសដែលមាន GNI ក្នុងមនុស្សម្នាក់ ច្រើនជាង ១.០៤៥ ដុល្លារអាមេរិក ប៉ុន្តែតិចជាង ៤.១២៥ ដុល្លារអាមេរិក ប្រទេសដែលមានចំណូលសេដ្ឋកិច្ចខ្ពស់មធ្យម គឺបណ្ដាប្រទេសដែលមាន GNI ក្នុងមនុស្សម្នាក់ច្រើនជាង ៤.១២៥ ដុល្លារអាមេរិក ប៉ុន្តែតិចជាង ១២.៧៤៦ ដុល្លារអាមេរិក ហើយប្រទេសដែលមានចំណូលសេដ្ឋកិច្ចខ្ពស់ គឺបណ្ដាប្រទេសដែលមាន GNI ក្នុងមនុស្សម្នាក់ ចំនួន ១២.៧៤៦ ដុល្លារអាមេរិក ឬ ច្រើនជាងនេះ។ មាត្រដ្ឋាននៃចំណូលក្នុងមនុស្សម្នាក់ ត្រូវបានធ្វើបច្ចុប្បន្នភាពនៅដើមខែ កក្កដាជារៀងរាល់ឆ្នាំ ដើម្បីរួមបញ្ចូលនូវឥទ្ធិពលនៃអតិផរណាអន្តរជាតិ។

**តារាង ខ១.១ មាត្រដ្ឋាននៃចំណូលជាតិសរុបក្នុងមនុស្សម្នាក់សម្រាប់ការបែងចែកប្រភេទក្រុមចំណូល ត្រឹមខែកក្កដា ឆ្នាំ២០១៤ (គិតជា ដុល្លារអាមេរិក ឆ្នាំ២០១៣) ៖**

| | | |
|---|---|---|
| | **ចំណូលទាប** | < $1,045 |
| $1,045 < | **ចំណូលទាបមធ្យម** | < $4,125 |
| $4,125 < | **ចំណូលខ្ពស់មធ្យម** | < $12,746 |
| $12,746 < | **ចំណូលខ្ពស់** | |

ប្រភព : http://data.worldbank.org/news/2015-country-classifications?print

សម្គាល់ :មាត្រដ្ឋាននេះ ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ខែកក្កដា។ សម្រាប់ព័ត៌មានស្តីពីមាត្រដ្ឋានចុងក្រោយ សូមចូលទៅកាន់ http://data.worldbank.org/about/country-and-lending-groups

ដោយសារកន្លងមក មាត្រដ្ឋាននេះ នៅតែរក្សាកម្រិតចំណូលដដែលក្នុងរយៈពេលជាក់ស្តែង ដូច្នេះ ចាំបាច់ត្រូវរក្សាកំណើនក្នុងកម្រិតដូចគ្នាដដែលគិតជាដុល្លារអាមេរិកក្នុងឆ្នាំ២០១៣។ ដើម្បីវាយតម្លៃដឹងថា កម្ពុជាស្ថិតនៅក្នុងក្រុមចំណូលមួយណានាពេលអនាគត គេបានធ្វើការព្យាករណ៍កំណើនសេដ្ឋកិច្ចថេរកម្ពុជាក្នុងឆ្នាំ២០១៣ គិតជាដុល្លារអាមេរិក ហើយជាលទ្ធផល ចំណូលជាតិសរុប ក្នុងមនុស្សម្នាក់ៗ ត្រូវបានយកមកប្រៀបធៀបនឹងមាត្រដ្ឋានដូចបង្ហាញក្នុងតារាង ខ៣.១ ។

សេដ្ឋកិច្ចកម្ពុជា ទំនងជាប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ហើយការព្យាករណ៍នេះនឹងត្រូវកត់ត្រាទុកជាផ្លូវការក្នុងខែកក្កដា ឆ្នាំ២០១៦។ តាមរយៈការព្យាករណ៍កំណើន DGP ៦.៩ ភាគរយ ក្នុងរយៈពេលថេរ ឆ្នាំ២០១៥ និងកំណើនប្រជាជនប្រចាំឆ្នាំ ១.៤ ភាគរយ កម្ពុជា ទំនងនឹងមាន ចំណូលជាតិសរុប ក្នុងមនុស្សម្នាក់ ១.០៩៦ ដុល្លារអាមេរិក (គិតជាដុល្លាអាមេរិក ឆ្នាំ២០១៣) ក្នុងឆ្នាំ២០១៥ ដែលលើសពីកម្រិតមាត្រដ្ឋាន ១.០៤៥ ដុល្លារអាមេរិក (តារាង ខ១.១ និងខ១.២)។ ដោយសារធនាគារពិភពលោក ធ្វើបច្ចុប្បន្នភាពសមាជិកភាពនៃការបែងចែកក្រុមចំណូលក្នុងខែកក្កដា ស្ថានភាពកម្ពុជាដែលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ទំនងជាត្រូវបានកត់ត្រាជាផ្លូវការក្នុងខែកក្កដា ឆ្នាំ២០១៦។

**តារាង ខ១.២ កាលបរិច្ឆេទ និងអត្រាកំណើនដែលកម្ពុជានឹងផ្លាស់ប្តូរស្ថានភាពអភិវឌ្ឍន៍របស់ខ្លួន**

| **កំណើន GDP ថេរ គិតជា ដុល្លារអាមេរិក** | **GNI ក្នុងមនុស្សម្នាក់ថេរ គិតជា ដុល្លារអាមេរិក ឆ្នាំ២០១៣** | | | |
|---|---|---|---|---|
| | 2014 | 2015 | 2030 | 2050 |
| 4.9% | 1,035 | 1,075 | 1,908 | 4,101 |
| 6.9% | 1,035 | 1,096 | 2,589 | 8,148 |
| 9% | 1,035 | 1,117 | 3,544 | 16,521 |

ប្រភព:ការគណនារបស់បុគ្គលិកពិភពលោកផ្អែកលើទិន្នន័យរបស់ WDI, Atlas និង MEF

សម្គាល់:ការវាយតម្លៃគឺផ្អែកលើចំណូលជាតិសរុប ៩៥០ ដុល្លារអាមេរិក ឆ្នាំ២០១៣។ កំណើន GDP សរុប ដែលបានព្យាករណ៍ ត្រូវបានចាត់ទុកជាកំណើនតំណាងសម្រាប់កំណើន GNI ។ តាមការប៉ាន់ស្មាន កំណើនប្រជាជនប្រចាំឆ្នាំ គឺ ១% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៥ តទៅ។

**តាមរយៈសេណារីយ៉ូកំណើនមូលដ្ឋាន នៃកំណើន GDP ប្រចាំឆ្នាំពិតប្រាកដ កម្រិត ៦.៩ ភាគរយ កម្ពុជានឹងប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣៩។** ការប្រែក្លាយជាប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ នឹងទាមទារឱ្យមានកម្រិតកំណើន GDP ៩ ភាគរយ (តារាង ខ១.២) ដែលនឹងស្មើនឹងកម្រិតកំណើនចំណូល ៨ ភាគរយ ក្នុងមនុស្សម្នាក់។ តាមរយៈការវិនិច្ឆ័យលើបទពិសោធន៍កំណើនកន្លងមករបស់ប្រទេសនានាចាប់ពីឆ្នាំ១៩៥០ ការរក្សាអត្រាកំណើនបែបនេះ ទាមទារនូវកិច្ចប្រឹងប្រែងពិសេស។ ប្រទេសដែលមានការលូតលាស់លឿនបំផុតក្នុងរយៈពេលពីរទស្សវត្សរ៍ មានអត្រាកំណើនចំណូលក្នុងមនុស្សម្នាក់ប្រចាំឆ្នាំជាមធ្យម ៨.៩ ភាគរយ (ចិន) និង ៦.១ ភាគរយ (អាមេនៀរ)។ ទោះបីយ៉ាងណា ការសម្រេចបានចំណូលខ្ពស់មធ្យមមុនឆ្នាំ២០៥០ គឺជារឿងល្អក្នុងចំណោមប្រទេសអ្នកមាន ប្រសិនបើកំណើន GDP មានកម្រិតលើសសេណារីយ៉ូដែលមានករណីចំណូលទាប ៤.៩ ភាគរយ។ ស្ថិតក្រោមខ្សែបន្ទាត់មូលដ្ឋាននៃកំណើន GDP ៦.៩ កម្ពុជា នឹងសម្រេចបានកំណើននេះត្រឹមឆ្នាំ២០៣៩។

សូមមើល http://data.worldbank.org/indicator/NY.GNP.PCAP.CD និង http://www.investordictionary.com/definition/gross-national-income

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែមេសា ឆ្នាំ២០១៥--២

**ទស្សនវិស័យ:**
ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា

**បេសកកម្ម:**
យើងផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គមស៊ីវិល និងបង្កលក្ខណ:អោយមានឥទ្ធិពលទៅដល់តួអង្គអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា

**គុណតម្លៃ:**

- សុចរិតភាព
- ភាពឆ្លើយតប
- កិច្ចសហប្រតិបត្តិការ
- គុណភាព
- បរិយាប័ន្ន

**គោលដៅ:**
សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតប ទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា




House #9-11, Street 476, Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia
T : +855 (0)23 214 152
F : +855 (0)23 216 009
E : info@ccc-cambodia.org

www.ccc-cambodia.org
www.facebook.com/CCCsince1990
www.youtube.com/CCCambodia